ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Nov-2016, 15:55
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៣៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា អេវេលីន ខាំផូស សង់ចេស

*(Ms. Evelyn CAMPOS SANCHEZ*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d’ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក យន់ ប៊ីន (2-TCCP-233) | ខ្មែរ |
| លោកស្រី កាន់ សុន្ទរ៉ា (2-TCCP-1051) | ខ្មែរ |
| លោក ចៅ ឃឹម (2-TCCP-1050) | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោក យន់ ប៊ិន (2-TCCP-233)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣

សួរដោយលោក ឡោ ជុនធី ផ្តើមពី ........ ទំព័រ ៤

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ១១

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ........ ទំព័រ ១៨

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........ ទំព័រ ២០

សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........ ទំព័រ ២៤

សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្តើមពី ........ ទំព័រ ២៧


## ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោកស្រី កាន់ សុន្ធារ៉ា (2-TCCP-1051)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣៣

សួរដោយលោក ហុង គឹមសួន ផ្តើមពី ........ ទំព័រ ៣៤

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ........ ទំព័រ ៤៥


## ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោក ចៅ ឃឹម (2-TCCP-1050)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៥០

សួរដោយលោក គឹម ម៉េងឃី ផ្តើមពី ........ ទំព័រ ៥២

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ........ ទំព័រ ៦០

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៦៧

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........ ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបបញ្ចប់ ដែលមានរហស្សនាម 2-TCCP-233, 2-TCCP-1051 និង 2-TCCP-1050។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន ដោយឡែកលោក ពេជ អង្គ មេធាវីនាំមុខជាតិតំណាងឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងមកអង្គជំនុំជម្រះថា លោកនឹងមកយឺតបន្តិចនៅពេលព្រឹកនេះ។ ហើយលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ ហើយលិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មនៅថ្ងៃនេះមានចំនួនបីរូប គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-233, 2-TCCP-1051 និង 2-TCCP-1050។ ហើយនៅក្នុងអំឡុងពេលនៃការថ្លែងរៀបរាប់អំពីទុក្ខសោក និងស្ថានភាពព្យសនកម្ម គឺមានបុគ្គលិកអង្គការ ធី.ភី.អូ លោក ប៊ុន លីមហ្គរ នៅអង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណី។ ហើយដើមបណ្តឹងរដ្ឋប្បវេណីនិងបុគ្គលិកអង្គការ ធី.ភី.អូ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជំនុំជម្រះបាបនទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខ-ភាពឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃសិទ្ធិនៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៤:១០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់លោក នួន ជា ថាមានអាការៈឈឺចង្កេះរ៉ាំរ៉ៃ ឈឺខ្លាំងពេលអង្គុយយូរ និងផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននិងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-233 រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ លោក ប៊ុន លីមហួរ ចូលមកកាន់កន្លែងថ្លែងរៀបរាប់សុខទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការ។

[០៩:០៦:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី! តើលោកឈ្មោះអី?

**លោក យន់ ប៊ីន៖៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ យន់ ប៊ីន។

**ស៖** លោកកើតនៅថ្ងៃណា ឆ្នាំណាដែរ លោកចាំហ៎?

**ឆ៖** បាទ ខ្ញុំកើតថ្ងៃ០៧ ខែ១០ ឆ្នាំ១៩៥៥។

**ស៖** លោករស់នៅកន្លែងណាដែរសព្វថ្ងៃ?

**ឆ៖** ស្រុកអង្គរវាំងខ៏ ខេត្តត្បូងឃ្មុំ។

**ស៖** តើលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃ?

**ឆ៖** បាទ ធ្វើស្រែចម្ការ។

**ស៖** តើឪពុកម្តាយបង្កើតរបស់លោកឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ ញែម យន់ (ឪពុក), ម្តាយឈ្មោះ ចាយ អេន។

**ស៖** ប្រពន្ធលោកឈ្មោះអីដែរ ហើយលោកមានកូនប៉ុន្មាននាក់?

[០៩:០៧:៥៩]

**ឆ៖** ប្រពន្ធខ្ញុំឈ្មោះ ខាន់ សាវី។ កូនបួននាក់។ ប្រុសពីរ ស្រីពីរ។

**ស៖** អរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោក យន់ ប៊ីន ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការនេះ លោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ ស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពជាជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោក ជាអាទិ៍ ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់បច្ចុប្បន្នប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

ជាដំបូងអង្គជំនុំជម្រះសូមសួរទៅសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ថាតើដំណើរការនៃការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងបីនេះ រៀបចំដូចម្ដេច ថាតើគាត់ថ្លែងរៀបរាប់ដោយខ្លួនឯងផ្ទាល់ ឬមួយក៏ឆ្លើយតបទៅនឹងសំណួររបស់មេធាវី។ សូមអញ្ជើញលោកមេធាវី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ គឺលោកមេធាវី ឡោ ជុនធី គាត់នឹងសួរសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីលោកប្រធាន។ សូមមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[០៩:១០:០០]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំបាទសូមគោរពអង្គជំនុំជម្រះទាំងមូល។ សូមគោរពភាគីដែលចូលរួមនៅទីនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរ លោក យន់ ប៊ីន។ ថ្ងៃនេះ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសូមជម្រាបសួរសំណួរមួយចំនួនដែលពាក់ព័ន្ធទៅនឹងអ្វីដែលជាបទពិសោធន៍របស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ទៅដល់ថ្ងៃ០៦ មករា ឆ្នាំ១៩៧៩។ ជាដំបូងខ្ញុំបាទសូមជម្រាបសួរទៅលោក យន់ ប៊ីន ថាតើនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹងលោករស់នៅភូមិឃុំណាដែរបាទ?

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ ខ្ញុំរស់នៅភូមិទួលមានជ័យ ឃុំប្រធាតុ។

**ស៖** បាទ អរគុណ។ នៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោករស់នៅកន្លែងណាដែរ

បាទ?

**ឆ៖** ខ្ញុំរស់នៅភូមិទួលមានជ័យ ឃុំប្រធាតុ។

**ស៖** បាទ អរគុណ។ ថាតើមានន័យថា លោកបានរស់នៅភូមិឃុំដដែល ហើយថាតើនៅពេលនោះ គេមានបញ្ជូនលោកទៅធ្វើការនៅកន្លែងណាដែរអត់ទេ ដែលពេលក្រោយបែកឆ្នាំ១៩៧៥ ១៧ មេសាហ្នឹង?

**ឆ៖** បាទ គេប្រមូលកងចល័តហ្នឹង ឲ្យទៅរស់នៅ នៅកោះទន្សាយ។

**ស៖** នៅពេលដែលលោកបានទៅដល់កោះទន្សាយនោះ តើគេឲ្យធ្វើការអ្វីខ្លះដែរ?

**ឆ៖** បាទ គេឲ្យធ្វើស្រែចម្ការ ជីកប្រឡាយ លើកភ្លឺស្រែ បាទ។

**ស៖** តើនៅពេលដែលលោកកំពុងតែធ្វើការងារនៅការដ្ឋាននោះមាននូវព្រឹត្តិការណ៍អ្វីដែលកើតឡើងចំពោះលោកដែរឬទេ?

**ឆ៖** បាទ ពេលនោះ គេឲ្យខ្ញុំធ្វើទៅកាប់ព្រៃ ទៅស្ទូងស្រែ១ហិកតា ឲ្យបាន ៣តោន បាទ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមជម្រាបសួរលោកថា នៅពេលនោះ នៅពេលដែលលោកកំពុងតែធ្វើនោះ តើមាននរណាហ្នឹងទៅហៅលោកទៅណាដែរឬទេបាទ?

[០៩:១៥:00]

**ឆ៖** បាទ គេហៅខ្ញុំហ្នឹង ទៅ -- ខ្ញុំនៅកំពុងតែដកស្នៀសណ្ដែកដី គេហៅខ្ញុំឲ្យទៅរៀនសូត្រ។

**ស៖** បាទ អរគុណ។ ថាតើលោកមានស្គាល់ទេ នរណាជាអ្នកទៅហៅលោកនុ៎ង?

**ឆ៖** បាទ ឈ្មោះ ពក អាយុ១៦ឆ្នាំ ដែលជាឈ្លប។

**ស៖** ថាតើឈ្មោះ ពក ហ្នឹង ហៅតែលោកម្នាក់ ឬមួយគាត់ហៅនរណាខ្លះ?

**ឆ៖** បាទ ក្នុងឃុំខ្ញុំ គាត់ហៅបីនាក់ ខ្ញុំ, មិត្ត សាន បាន, មិត្ត សាត ឌឹប។

**ស៖** បាទ អរគុណ។ ថាតើនៅនុ៎ង គាត់បានបញ្ជាក់ប្រាប់លោកថាយ៉ាងដូចម្ដេច ថាគាត់មកហៅនេះ តាមការបញ្ជារបស់នរណាដែរឬទេ?

**ឆ៖** បាទ គាត់ហៅនេះ គួរតែមកពីមេឃុំឈ្មោះ ឈាវ ហើយប្រាប់ថាមិនបាច់យកអីវ៉ាន់អីទៅទេ។

**ស៖** បន្ទាប់មក លោកបានត្រឡប់ទៅផ្ទះវិញ ឬមួយ -- ថាតើគេហៅហ្នឹង គេហៅលោកទៅខាងណា? ទៅកន្លែងណា?

ឆ៖ បាទ គេហៅទៅ នៅកន្លែងមន្ទីរឃុំព្រះធាតុ ហើយនៅមេឃុំនោះឈ្មោះ លាវ។

ស៖ នៅពេលដែលលោកទៅដល់មន្ទីរឃុំនោះ តើលោកសង្កេតឃើញថា នៅកន្លែងមន្ទីរឃុំនោះមានមនុស្សនៅទីនោះប៉ុន្មាននាក់?

ឆ៖ បាទ ទៅដល់មន្ទីរឃុំនោះ គឺមានមិត្តជាយុទ្ធជននោះ វាប្រាំមួយនាក់ទៀត មកពីភូមិស្រែមាន ភូមិថ្មីលើ ភូមិថ្មីកណ្ដាល ភូមិភ្នំ។

ស៖ បាទ អរគុណ។ មានន័យថា ពេលដែលលោកទៅដល់ គឺមានពួកគាត់នៅទីនោះហើយ។ ចាតើនៅកន្លែងនុ៎ង ទាំងខាងពួកលោក ហើយនិងខាងពួកគាត់ហ្នឹង មានសរុបទាំងអស់ប៉ុន្មាននាក់?

ឆ៖ បាទ សរុបទាំងអស់ប្រាំបួននាក់។

ស៖ ពេលនោះ គេក្រុមពួករបស់លោកហ្នឹង រង់ចាំនរណានៅទីនោះ?

ឆ៖ បាទ គេយករទេះសេះដឹកទៅពាមជាំង។

[០៩:២០:០៩]

ស៖ បាទ អរគុណ។ នៅពេលដែលគេដឹករទេះសេះទៅពាមជាំងហ្នឹង តើគេដឹកមួយរទេះសេះតែម្ដង ឬមួយដឹកប៉ុន្មានរទេះសេះ?

ឆ៖ បាទ ដឹកតែរទេះសេះមួយទាំងអស់គ្នា។

ស៖ នៅពេលដែលទៅដល់ពាមជាំង លោកបានដឹងថាទៅដល់ពាមជាំងហ្នឹងប្រហែលម៉ោងប៉ុន្មានដែរពេលហ្នឹង?

ឆ៖ បាទ ទៅដល់ពាមជាំងប្រហែលម៉ោងដប់ បាទ។

ស៖ តើនៅពេលដែលលោកទៅដល់ លោកបានសង្កេតឃើញថានៅជុំវិញហ្នឹងមាននរណាខ្លះ ហើយលោកអាចរៀបរាប់កន្លែងហ្នឹងបានទេ?

ឆ៖ បាទ ខ្ញុំឃើញពួក សុទ្ធតែពួកនិរតី ស្លៀកអាវ ពាក់ខោអាវខ្មៅបង់កក្រមាស-ខៀវ បួនទៅប្រាំនាក់បាទ។

ស៖ អរគុណ។ ចាតើនៅពេលដែលទៅដល់ភ្លាម ខាងអម្បាញ់មិញលោកថាខាងនិរតី។ ចាតើពួកគាត់បានធ្វើអ្វីនៅពេលនោះ បាទពេលដែលលោកទៅដល់ភ្លាម?

ឆ៖ បាទ គេកត់ឈ្មោះ ជាតួនាទីអីនៅភូមិណា ឃុំណាក្នុងសៀវភៅគេ បាទ។

ស៖ បន្ទាប់មកទៀត ចាតើគេឲ្យលោកចាំនៅទីនោះ ចាំអ្វីដែរបាទ?

**ឆ៖** បាទ ពួកគេនិយាយថា "យកមកនេះ បងប្អូនកុំភ័យឲ្យសោះ ព្រោះយកមករៀនសូត្រតែបួនប្រាំថ្ងៃនឹងវិលត្រឡប់ទៅផ្ទះវិញហើយ រួចកន្លែងនោះសប្បាយណាស់ ដី១គីឡូដីប្អូនជ្រុងបាទ ហើយមានមេក្រូប្អូន បក្សយើងមិនដែលយកមនុស្សទៅសម្លាប់ចោលទេ"។

**ស៖** បាទ អរគុណ។ អំមិញហ្នឹង លោកអត់ទាន់បានឆ្លើយថាតើគេប្រាប់ឲ្យក្រុមលោកហ្នឹងនៅចាំអ្វីទេ នៅចាំអ្វីនៅទីនោះ?

**ឆ៖** បាទ គេឲ្យនៅចាំឡាន នឹងដឹកបញ្ជូនទៅរៀនសូត្របាទ។

**ស៖** តើលោកនៅចាំនៅទីនោះដល់ម៉ោងប៉ុន្មានបានឡានមកដល់?

**ឆ៖** បាទ ខ្ញុំនៅចាំទាល់ប្រហែលម៉ោងជិតប្រាំពីរយប់ ហើយពួកវាក៏ថា "យី!ឡានក៏ក្រមកម្ល៉េះ!"។

[០៩:២៤:២២]

**ស៖** ដល់ពេលឡានមកដល់ តើក្រុមលោកឡើងឡានភ្លាម ឬមួយមានសភាពយ៉ាងដូចម្ដេចពេលនោះ?

**ឆ៖** បាទ ពួកវាថាមិនទាន់ចងទេ រួចបានពួកវាសូមចង ថាបងៗកុំមានសតិអារម្មណ៍អី អង្គការយើងមិនទុកចិត្តខ្លាចបងមានកាំបិត ឬគ្រាប់បែកសុំចង។

**ស៖** នៅពេលដែលគេចងហើយ តើគេធ្វើដូចម្ដេចទៀតទៅលើក្រុមពួកលោកបាទ?

**ឆ៖** បាទ គេចងស្លាបសេកទាំងអស់គ្នា ហើយគេបញ្ជូនទៅនៅឡាននៅខាងមុខប្រហែលជាង ២០ម៉ែត្រ គេក៏ទើសដៃទើសជើងដែលចងហ្នឹង គេក៏បោះទៅលើឡាន។

**ស៖** នៅពេលដែលគេបោះលោកឡើងទៅលើឡាន តើលោកបានឃើញអ្វីខ្លះនៅក្នុងឡាននោះ?

**ឆ៖** បាទ ទៅដល់លើឡាន ខ្ញុំឃើញថា គេមនុស្សនៅជាងកន្លះឡាននៅក្នុងនុំងស្លៀកសុទ្ធតែខោខ្លី ហើយបែកឈាមហូរ បែកភ្នែក បែកក្បាល ឈាមហូរ ហើយខ្លួនទទេទាំងអស់។

**ស៖** តើនៅពេលនោះ លោកទទួលអារម្មណ៍យ៉ាងដូចម្ដេច? លោកអាចរៀបរាប់ឲ្យបានលម្អិតជាងនេះបន្តិចមើល?

**ឆ៖** បាទ នៅពេលនោះ ខ្ញុំហាក់បីដូចភ័យ ព្រោះថាឃើញគេ "អូ! ពួកវាប្រាកដជាយកទៅសម្លាប់ហើយ"។ ដល់នោះ ខ្ញុំភ័យយ៉ាងខ្លាំង ញ័រទ្រូងភឹបៗ ហើយខ្ញុំជាប់ចំណងនៅទល់មុខហ្នឹង ខ្ញុំក៏បែកទៅជិតឡានអារីនខាងហ្នឹង ក៏ខ្ញុំរុះដៃ ភ័យណាស់ ខ្ញុំដឹងថាខ្លួនខ្ញុំប្រាកដជាពួកវាយកទៅសម្លាប់

ហើយ។

[០៩:២៧:៤៧]

**សៈ** បាទ នៅពេលដែលលោកភ័យខ្លាំង ហើយលោករុះដៃហ្នឹង តើមាននរណាមកធ្វើអ្វីលើលោកបន្ថែមទៀតដែរឬទេ?

**ផះ** បាទ ពេលនោះពួកវាក៏ទាញខ្ញុំទៅ យកអាកាស្វ័យបត់មួយប្រុងវ៉ៃខ្ញុំក្បាលហ្នឹង ទាញខ្ញុំឈរតែអាម្នាក់ទៀតវាថា យើស! វាគង់តែងាប់ទេ។ ពួកវាក៏យកខ្សែក្រចៅមកចងខ្ញុំ ដៃចងដៃមួយជាន់ទៀតទាំងអស់គ្នា អ្នកដែលថ្មីទៅពីភូមិឃុំខ្ញុំទៅ បាទ។

**សៈ** បានន័យថា គេចងលោកបន្ថែមមួយចំណងទៀត។ ចាតើការចងហ្នឹង ចងប៉ុន្មាននាក់ដែលបន្ថែមទៀតហ្នឹង?

**ផះ** បាទ ចងទាំងប្រាបួននាក់ ទាំងស្រីដែរបាទ ទាំងអស់ដែលនៅហ្នឹង។

**សៈ** តើនៅក្នុងឡានដែលលោកបានឡើងទៅហ្នឹង មើលទៅថាមានមនុស្សប៉ុន្មាននាក់ដែរ? ហើយដែលជាស្ត្រីហ្នឹងអាចប៉ុន្មាននាក់ដែរ?

**ផះ** បាទ ជាស្ត្រី ចាមានបួននាក់ បាទ។

**សៈ** តើក្នុងឡានហ្នឹងមានមនុស្សប្រហែលប៉ុន្មាននាក់ដែរ បាទ?

**ផះ** បាទ ក្នុងឡាននោះ មានមនុស្សប្រហែល តាមខ្ញុំស្មានមក ប្រហែលជា៤០នាក់។

**សៈ** បាទ អរគុណ។ ចាតើនៅពេលដែលគេដឹកឡានចេញទៅ តើគេដឹកចេញទៅកន្លែងណាលោក បើលោកអាចសម្គាល់បាន សូមមេត្តាប្រាប់ ប៉ុន្តែបើមិនសម្គាល់បានគ្រាន់តែថា តើគេដឹកឡានហ្នឹងទៅក្នុងរយៈពេលប៉ុន្មានគេបញ្ឈប់ឡាននោះ?

**ផះ** បាទ គេដឹកទៅប្រហែលចំនួន១៥នាទី បានទៅដល់កន្លែងពួកវាយកទៅសម្លាប់។

[០៩:៣០:៥៣]

**សៈ** បាទ អរគុណ។ ចាតើពេល នៅពេលដែលឡានទៅដល់នោះ គេធ្វើយ៉ាងម៉េច គេឲ្យមនុស្សចុះ ហើយគេបណ្តើរទៅ ឬមួយគេធ្វើយ៉ាងម៉េច លោកអាចរៀបរាប់ចំណុចហ្នឹងបានដែរឬទេ?

**ផះ** បាទ នារីៗគេឲ្យជិះពីក្រោយឡាន គេឲ្យទៅមុនគេ យកទៅបាត់ម្តងមួយៗ។

**សៈ** តើដល់ពេលវេនលោក គេធ្វើយ៉ាងដូចម្តេចដែរ?

**ផះ** បាទ ពួកវាផាក់ខ្ញុំទម្លាក់ទៅ ហើយចាប់ខ្ញុំបណ្តើរទៅ ដោយមានគ្នាវាបួនប្រាំនាក់ បញ្ឈា

ទៅ។

**ស៖** បាទ អរគុណ។ តើគេបណ្ដើរលោកទៅដល់កន្លែងណា ហើយមានគេធ្វើយ៉ាងម៉េចទៅលើលោក សូមលោករៀបរាប់ចំណុចហ្នឹងតែម្ដងមើល ថាតើវាមានបញ្ហាអីនៅពេលនោះ?

**ឆ៖** បាទ គេបណ្ដើរខ្ញុំទៅ មានអាយាមតាមផ្លូវ ស្រែកថា "អ្នែងទៅត្បូង!" ទៅដល់ពួកវា -- អាបណ្ដើរខ្ញុំនេះ វាថា "អ្នែងអង្គុយចុះ!" ខ្ញុំអង្គុយចោងហោងចុះ ក៏វាដាក់ក្បាលខ្ញុំមួយពូថៅ ដួលសន្លប់លោតទៅ ព្រោះមានទឹកផ្កុកឈាមមួយនៅពីមុខហ្នឹង ក៏ផុតនុំងទៅ ក៏ខ្ញុំក៏សន្លប់ទៅ។ ពេលដែលសន្លប់នោះ បាទ ខ្ញុំហាក់បីដូចជារត់ទៅប្រាប់ឪពុកម្ដាយខ្ញុំនៅឯផ្ទះ គេថា វាមិនយកមករៀនសូត្រទេ វាយកមកនេះ វាសម្លាប់ទេ។ ដល់ពេលនោះហើយ ដែលខ្ញុំធ្លាក់ធ្ងន់ខ្លួនពេកនៅបីប្អូននាក់លើខ្នង បានទើបខ្ញុំដឹងខ្លួនថា ដូចជាខ្ញុំរត់មកដល់វិញបាទ។ ហើយពេលនោះ ខ្ញុំក៏ដឹងខ្លួនសុទ្ធតែខ្មោចស្អុយដង្កូវនៅក្នុង -- ខ្ញុំអត់ដឹងថានៅក្នុងរណ្ដៅអី ព្រោះយប់ខ្ញុំមើលឥតដឹងដែរបាទ។ ដឹងខ្លួនហើយ ខ្ញុំក៏ចាំ -- ខ្ញុំក៏ហែលរួតដៃ ដៃជាប់ចំណងទាំងពីរ ដោយសារឈាម និងខ្លាញ់ផងបានរអិលរបូត ហើយខ្ញុំក៏នៅចាំស្ដាប់វាបន្តទៀត វ៉ៃនៅពេលនោះបាទ។ ហើយពេលនោះ ពួកវាក៏ស្រែកដូចនេះហ្នឹង ប្រាប់ដូចខ្ញុំដែរ "អង្គុយចុះ!" ហើយក្បាលមនុស្សពេលនោះ ឮតែសូរភូស ដូចជាវ៉ៃដូងទុំអ៊ីចឹង ភូស ព្រឹសៗ ហើយទម្លាក់មក មកលើខ្ញុំឈាមហូរមកលើខ្ញុំនៅក្នុងរណ្ដៅនោះ វ៉ៃៗអស់ប្រុសៗ ស្រាប់តែវ៉ៃស្រីៗចុងក្រោយ។ ស្រីឲ្យអង្គុយចុះពេលនោះ ក៏ស្រែក ហើយខ្ញុំចេះតែឮល់ថា ចុះខាងនារីៗវាចុះទៅមុនគេ នៅលើឡាន នៅពីក្រោយស្រាប់ហេតុអ្វីបានវាវ៉ៃក្រោយគេវិញ។

[០៩:៣៤:៣៩]

ដល់ពេលខ្ញុំ -- វ៉ៃៗនារីអស់ទៀត ក៏ពួកខ្ញុំទាំងអស់គ្នាដែលពួកអ្នកស្លាប់ គេវ៉ៃស្លាប់ទាំងអស់គ្នាមួយឡានជិត៤០នាក់ហ្នឹង។ ខ្លះក៏ស្រែកថា "ម៉ែជួយកូនផង! ម៉ែជួយកូន!" ទ្រហឹងចង់បែកត្រចៀក។

រួចពួក -- ហើយពួកវាក៏ ខ្ញុំក៏នៅតែចាំស្ដាប់មើលវ៉ៃនារីៗហើយបន្តិច ស្រែរកតែម៉ែ ពួកខ្ញុំជនរងគ្រោះទាំងអស់នោះ ដែលខ្លះរស់ ខ្លះស្លាប់នោះ ខ្លះមានដល់តែថ្នាក់អារកទៀត ចុះទៅដោយខក់ៗ ខ្ញុំរួចពីចំណង ខ្ញុំស្ទាបមើលត្រូវអារក ដែលស្លាប់ទៅ ដែលខ្លះនៅរស់ស្រែរកតែម៉ែ "ម៉ែៗៗជួយផង!"។ ពេលនោះហើយ វាវ៉ៃអស់ វាក៏ស្រែកថា "អ្នែងថូរអីៗ"។ ដូច្នេះ ខ្ញុំនឹកសន្និដ្ឋានថា អាហ្នឹងបែបមានផែនការបាញ់ ឬចោលគ្រាប់បែក ខ្ញុំក៏ផ្ទៀងខ្លួនរាងទាបជាងអ្នកខ្មោចអ៊ីចឹងទៅកៀនដល់ជ្រៅបន្តិច ស្រាប់តែគ្រាប់បែកមួយគ្រាប់ផ្ទុះឡើង "ភឹង!" ឡើងស្រាប់តែបាត់ស្ងាត់នៅសល់តែបីប្អូននាក់ ឮស្រែកបន្តទៀត

ស្រែក "ម៉ែៗៗជួយផងម៉ែ!"។ ក៏វាថែមគ្រាប់បែកមួយគ្រាប់ទៀតស្ងាត់សូន្យ គិតទៅស្លាប់អស់ទាំងអស់គ្នា នៅរស់តែខ្ញុំមួយ។ ពេលនោះ ខ្ញុំក៏នៅចាំស្ដាប់វា ព្រោះខ្ញុំដាក់ត្រចៀកពិតនៅនឹងដីអាចឮសូរអ្វីៗទាំងអស់ ក៏ឮស្នូរស្ងាត់បន្តិច ក៏ឮសូរឡានវាវិលត្រឡប់ទៅកន្លែងវាវិញ។ ពេលនោះហើយដែលខ្ញុំ ធ្វើឲ្យខ្ញុំប្រឹងប្រែងហែលកាត់ខ្មោច ដើរសួរពួកមិត្តៗថា "មិត្តណាមាននៅរស់ទេ?" ពេលនោះ មិត្តទាំងអស់ស្លាប់អស់រលីងនៅតែខ្ញុំម្នាក់ ធ្វើឲ្យខ្ញុំហែលកាត់ខ្មោចហើយ វារឡើងតាមជញ្ជាំងក៏ខ្ញុំអត់ដឹងថា វារើដាក់បង្គន់ ឬដាក់អណ្ដូងដែរ ព្រោះនៅកន្លែងនោះគឺជ្រៅ ជួនកាលខ្ញុំជាន់ទៅដោយមានដង្កូវ ក្លិនឆ្អាប ក្លិនស្អុយ ជាន់ទៅមួយជើងជួនកាលចំខ្មោចរលួងនៅក្រោម មួយជើងដល់ក្រលៀន ក៏ឃើញៗតែខ្មោចរលួយហើយងាប់អស់ ឮសូរតែ "ស្រេត ព្រូសៗ"។ ខ្ញុំក៏សួរថា "មានមិត្តណារស់ដែរ?" ពេលនោះហើយគ្មានអ្នកណាមួយរស់សោះ ព្រោះបែបជាត្រូវគ្រាប់បែកធ្លាយពោះ ធ្លាយអី បាទ។ ដូចប៉ុណ្ណោះ ខ្ញុំគ្រាន់តែ ខ្ញុំគិតថា អូ៎! ខ្ញុំត្រូវតែឡើងធ្វើម៉េចឡើងឲ្យរួច។

[០៩:៣៨:០៧]

ពេលខ្ញុំឡើង ៗធ្លាក់ៗមួយយប់ទល់ជិតភ្លឺ ឡើងៗហើយ ខ្ញុំក៏លើកដាក់ខ្មោចម្នាក់ម្ដងៗលើកបានបីនាក់លើកលែងរួច។ រួចស្រាប់តែខ្ញុំស្ទាបក្បាលខ្ញុំ ក្បាលខ្ញុំត្រូវបីកន្លែងទៀត ពីរកន្លែងទៀត ព្រោះមុនដំបូងខ្ញុំដឹងតែមួយកន្លែងដែលខ្ញុំសន្លប់នោះ។ លើកមិនរួចក៏ខ្ញុំឡើងស្រវេស្រវាឲ្យរកគុណាបុណ្យម៉ែឪជួយដើម្បីឡើងឲ្យរួច ពេលនោះឡើងមិនរួចសោះ។ ដល់ជិតភ្លឺមាន់រងាវ ខ្ញុំក៏លើកម្នាក់រាងរឹងឈរខ្ពស់បែរមុខទៅខាងលិចនឹងជាន់ឡើង ខ្ញុំក៏ជាន់ខ្សែ ជាន់តាមចំណងជាន់ក្បាលឡើង ស្រុតបន្តិចៗក៏ឡើងមិនរួចដែរ។ រហូតដល់ខ្ញុំនៅពិតជញ្ជាំងស្ដាប់មើល ភ្លឺហើយ ក៏ឮជើងស្រឹបៗមក ខ្ញុំដឹងថាពួកវាប្រាកដជាមកមើលវិញហើយពេលភ្លឺ ព្រោះខ្ញុំឡើងមួយយប់ទល់ភ្លឺឡើងអត់រួច។

ពេលនោះខ្ញុំក៏ទាញខ្មោចនោះដាក់កាត់ពីលើទទឹងខ្នង ហើយខ្ញុំធ្វើពុតជាងាប់ បែរមុខទៅលិច វាមកដល់ខ្ញុំក៏បិទភ្នែកជិតទៅសម្ងំ ក៏ឮពួកវា អាម្នាក់ថា "ចុញ! ដូចមាននៅរស់" ម្នាក់ទៀតថា "ដឹងអី"។ ដល់ពេលនោះក៏វាគប់គ្រាប់បែកមួយគ្រាប់ទៀត-- *(ដើមបណ្ដឹងរដ្ឋប្បវេណីយំ)* --

[០៩:៤១:០០]

--ពេលវាគប់គ្រាប់បែក ព្រលឹមឡើងមួយគ្រាប់ទៀត ត្រូវអ្នកនៅពីលើខ្ញុំ ហើយខ្ញុំឡើង ហាក់បីដូចខ្ញុំ ដូចជាមិនត្រូវអីសោះ បាទ។ ហើយខ្ញុំក៏នៅសម្ងំ វាក៏កាយដី លុបស្ដើងៗពីលើខ្ញុំហ្នឹង រួចឮជើងតែពីរបីជំហាន ព្រោះខ្ញុំជិតដាច់ខ្យល់ហើយ បាទ។ សូម ខ្ញុំក្រោកឡើងមើលវា បើឃើញវា ខ្ញុំឲ្យចោលគ្រាប់បែក

ឲ្យបាញ់សម្លាប់ខ្ញុំ។ ដល់មិនឃើញវា ខ្ញុំក៏មើលកន្លែងឡើង ព្រោះឡើងមួយយប់ទល់ភ្លឺ ឡើងមិនរួច។ ដល់មើលទៅ ដីនុំង គឺថាមួយកាងដៃបួនជ្រុង រអិលសុទ្ធតែឈាម នៅពីខ្ញុំៗទៅលើ នៅប្រហែលជា៦ ទៅ៧ម៉ែត្រទៀត។ ហើយក៏ខ្ញុំសូមស្បថ និងឲ្យពួកមិត្តៗដែលស្លាប់ទៅ ជួយធ្វើម៉េចឲ្យខ្ញុំ ឲ្យតែបានខ្ញុំរស់ ធ្វើម៉េចជួយខ្ញុំឡើងរួច ខ្ញុំនឹងធ្វើបុណ្យ ហើយនិងរកយុត្តិធម៌ឲ្យដែលពួកវាប្រាប់យកមករៀនសូត្រ។ តើខ្ញុំមានទោសអី បានជាវាប្រាប់ថាយកមករៀនសូត្រ បែរជាយកទៅសម្លាប់។ ខ្ញុំប្រាប់ពួកមិត្តដែលស្លាប់ទាំងអស់នៅក្នុងរណ្ដៅនោះ ឲ្យតែខ្ញុំឡើងរួច ខ្ញុំនឹងរកយុត្តិធម៌ និងប្ដឹងរកយុត្តិធម៌ ព្រោះយើងស្លាប់ដោយអយុត្តិធម៌។ ពេលនោះហើយខ្ញុំកំណត់ឡើងតែបីដងទេ បើបីដងមិនរួច ខ្ញុំជេរវា ខ្ញុំហៅវាឈរឲ្យវាបាញ់ ឲ្យវាចោលគ្រាប់បែកសម្លាប់ចុះ ព្រោះនៅនុះ ទីកន្លែងនោះ រស់តែខ្ញុំម្នាក់ឯង។ ក៏សន្សាអ៊ីចឹងមើលទៅខ្ញុំថាបើឡើងកាងដៃវាផុតៗដៃ។ ដូច្នេះខ្ញុំក៏សម្រេចចិត្តឡើងដៃពីរទៅមុខ ជើងពីរទៅក្រោយផ្កាប់មុខ ហើយខ្លួនបិតនឹងអាវនឹងជញ្ជាំងដៃឲ្យជាប់ខ្លាំង។ ពេលឡើងទី១ ឡើងទៅដល់ប្រហែលជា៤ ទៅ ៥ម៉ែត្រ ក៏បានធ្លាក់ទៅវិញ។ ខ្ញុំនឹកថា ខ្ញុំអស់សង្ឃឹមហើយ។ ខ្ញុំ--

[០៩:៤៥:១៩]

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរចុងក្រោយមួយដើម្បីសួរលោក ដើម្បីបញ្ចប់សក្ខីកម្មរបស់លោក។ តើលោកអាចឆ្លើយបានទេនៅពេលនេះ លោកអាចពន្យល់បានទេ ថាតើលោកទទួលរងនូវផលប៉ះពាល់លើផ្លូវកាយនិងផ្លូវចិត្តយ៉ាងម៉េចខ្លះ ចំពោះហេតុការណ៍ដែលលោកបានរៀបរាប់នោះ? ហើយលោកមាននៅសល់ស្លាកស្នាមផ្លូវកាយ និងផ្លូវចិត្តទេ ក្រោយពីមានការហេតុការណ៍ហ្នឹងកើតឡើងមកដល់សព្វថ្ងៃហ្នឹង?

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ ខ្ញុំនិយាយបន្តមកបន្តិចទៀតចុះ។ ដល់ឡើងលើកទី២ ពួកហាក់បីដូចជាពួកមិត្តៗហ្នឹងខ្លះជ្រោងក្បាលជង្គង់ ជ្រោងដៃខ្ញុំ ស្រាប់តែទៅដល់លើ គឺថាឃើញដៃខ្វែងអ៊ីចឹង បានខ្ញុំនឹកថា "អ៊ូ! ខ្ញុំស្រវាដៃជាប់"។ ខ្ញុំនឹកថា "អ៊ូ! ពួកអាដែងនេះវាវៃដាក់ក្នុងបង្គន់បារាំង"។ ខ្ញុំអើតមើលទៅឃើញរោងចក្រពាមជាំងនៅខាងមុខ។ ហើយក៏ខ្ញុំលឺបទៅមើលវា បន្តិចអើតទៅ មើលវានៅយាមប្រហែលជាពីរនាក់បាទ នៅពីរនាក់ ឃើញវានៅប្រហែលជា ១០០ម៉ែត្រ។ ពេលនោះខ្ញុំក៏ទាញដែក ខ្ញុំធាក់ជញ្ជាំងឡើងផុត ខ្ញុំភ្នែកមើលវា ដើរឈានជើងដើរទៅក្រោយ។ ហើយស្លាកស្នាមខ្ញុំនៅនឹងក្បាលបីកន្លែង នៅដើរទៅ

-- ពេលនោះខ្ញុំដើរផុតទៅប្រហែលជាបាំងព្រៃចេកមួយគុម្ពខ្ញុំក៏រត់ទៅ ប្រុងតែឆ្លងទៅផ្ទះ ពេលនោះ ក៏ថ្ងៃមើលទៅឃើញ គឺសុទ្ធតែមនុស្ស ហើយនិងពួកវាដើរចុះដើរឡើង។ ដោយឃើញខ្ញុំសុទ្ធតែឈាម ត្រូវរបួសសុទ្ធតែដីអីចឹង ប្រាកដជាពួកវាចាប់ទៅឲ្យពួកវាវិញហើយ។ ក៏ខ្ញុំនៅសំងំនៅគល់ទ្រាសមួយ ហើយៗខ្ញុំក៏ឃ្លានបាយ ឃ្លានៗបាទ រួចហេវ ឈាមក៏នៅតែប្រឹងឡើងនៅតែហូរ ខ្ញុំក៏បូតស្លឹកទ្រាសនោះ ហាមាត់ ហាបាន ប៉ុន្តែថ្គាមហារឹងទាំងអស់ ដាក់ស្លឹកទ្រាសគ្រាន់តែលេប ហើយខ្ញុំនឹងចាំជិតផ្លូវពួន ចាំមើលខ្ញុំនឹងឆ្ពោលរត់ទៅផ្ទះ ប្រាប់អ្នកផ្ទះថា ពួកវាយកមកខ្ញុំសម្លាប់ទេបាទ វាមិនមែនយកមករៀនសូត្រទេបាទ។ រួចខ្ញុំចាំៗដល់ជិត ប្រហែលជាម៉ោងជិតបួនល្ងាច ស្រាប់តែឃើញ យុវ័នមួយ ជំទង់ប្រហែលជា ១៤ ទៅ ១៥ឆ្នាំ មើលគោ ដើរមកចំខ្ញុំ ខ្ញុំសួរថា យុវ័នឯងមកធ្វើអី? ពេលនោះ ពួកយុវ័ននោះក៏មើលខ្ញុំឃើញថាដីឈាមនៅពេញក្បាល។ វាថា "មកមើលគោ"។ ហើយខ្ញុំថា ដល់ពេលនោះខ្ញុំដើរចេញទៅថ្នល់ក៏គ្មានមនុស្ស ឃើញអី រួច -- សូមទោសខ្ញុំសូមកាត់ត្រង់នេះបន្តិច ដោយនៅថ្ងៃហ្នឹងឃើញពួកវាដឹកមនុស្សចងស្លាបសេកមួយរទេះសេះថែមទៅទៀត ដោយអមដោយកាំភ្លើងសុទ្ធ ពួកវាសុទ្ធតែពួករដើនហ្នឹង។ ហើយខ្ញុំនៅចាំៗទាល់តែក្មេងគោហ្នឹងឃើញ បានខ្ញុំដើរទៅផ្លូវ អត់ឃើញមនុស្សអត់ឃើញពួកវាខ្ញុំក៏រត់ឆ្លងផ្លូវ ទម្រាំ គិតថាមករត់ទៅផ្ទះ។ ពេលនោះពួកដែលក្មេងមើលគោពួកវាទៅប្រាប់ ក៏ដេញខ្ញុំប្រហែលដីជាង១គីឡូម៉ែត្រ រត់ទៅ ខ្ញុំរត់។ វាចេះតែមកជិតៗដល់ ក៏ខ្ញុំរត់ឈាមហូរអត់បាយផង ហូរឈាមផង។ ក៏ខ្ញុំសម្រេចចិត្តដល់ព្រៃចេកខ្ញុំរត់ឈានទៅជើង ពេលនោះវារត់ពីក្រោយមក វារត់កាត់មុខខ្ញុំទៅដល់ព្រៃចេក ចូលព្រៃចេកពីរគុម្ពខ្ញុំបែរទៅត្បូងត្រង់ភ្លឹង។ ដូច្នេះវាស្មាក់ទៅជើង វារកមិនឃើញឡានម៉ូតូពួកវាក៏រុករក ខ្ញុំធ្លាក់រត់ទៅពួនដល់ព្រៃភ្នំបាទ។

[០៩:៥០:០០]

ដល់ទៅពួននៅនោះ ខ្ញុំចាំទាល់តែព្រលប់យប់ដោយហេវពេក ឃ្លានបាយពេក ខ្ញុំទៅដល់ ឃើញសណ្តែកក្ជួរគេដាំផ្លែច្រើនណាស់ ខ្ញុំថា ខ្ញុំសម្រេចថា យកដៃខ្ញុំទៅបេះសណ្តែកយកមកហូប។ ពេលនោះក៏ឃើញខ្មោចម្តាយខ្ញុំ គាត់នៅមុខថា "កូនឯងឲ្យតែស៊ីរបស់គេ គឺរត់មិនរួច"។ ហើយខ្ញុំក៏ហាមាត់ទៅហើយ ក៏ខាំសណ្តែកក្ជួរមួយកំណាត់ក៏ទំពារពុំកើត លេបទៅ។ រហូតដល់ពេលយប់ ក៏ខ្ញុំដើរយ៉ាងត្រដាបត្រដួស ដើររុកព្រៃ កាត់តែព្រៃ អត់ដើរតាមផ្លូវ ព្រោះខ្លាចវាឃើញ ព្រោះវាចាំម៉ូតូឡាន អត់មានឮសូរថាឡានទៅវិញសោះ។ ខ្ញុំក៏ដើរ ដើរមកដល់រោង គាត់ចាក់(ឮមិនច្បាស់) គេចាំដូង ចាំស្លា។ ពេលនោះ នៅយប់ហើយខ្ញុំដើរដល់មិនរួចសោះ ក៏ខ្ញុំសុំថា តាៗឲ្យខ្ញុំ -- ព្រោះសុំម្ចាស់គាត់នៅទីនោះ ព្រោះខ្ញុំស្អុយឆ្អាប

ឈាមច្រើនណាស់ ក៏ដួង -- គាត់ធ្វើខ្មើយដួងកាប់សំពាធនោះ ខ្ញុំដាក់កើយចំហៀង កើយមិនបាន ព្រោះក្បាលខ្ញុំហើមទាំងអស់។ ក៏ខ្ញុំដេកផ្កាប់មុខ បានមួយបន្តិចស្រាប់តែឮសូរដូច ពួកគេហៅថា “ក្រោកឡើងៗ ពួកវាមកទៀតហើយ” ខ្ញុំក៏លោតចុះទៅដី។ លោតចុះទៅអត់ឃើញអីសោះ។ ខ្ញុំក៏នឹកថា អ៊ូ! ស្រាប់តែខ្ញុំមើលទៅកើត ឃើញដូចពន្លឺព្រៀងៗ។ ខ្ញុំថា អ៊ូ! ខ្ញុំតែទៅដល់ផ្ទះថ្ងៃប្រាកដគេចាប់យកមកឲ្យវាសម្លាប់វិញហើយ។ ខ្ញុំក៏ដើរកាត់មកកន្លែងទឹកចេញដោយឆ្លាបស្អុយពេក ឈាមពេក ខ្ញុំក៏ដោះអាវគ្រវីៗទឹកហ្នឹង ហើយដាក់លើក្បាលដើរបន្តមក។ ផុតជាង១០០ដី ដូចមើលទៅ ដូចឃើញជាយប់ នៅយប់។ ប៉ុន្តែខ្ញុំថា នឹកថា ខ្ញុំសម្រេចចិត្តទៅផ្ទះហើយ ដើរបន្តិចមកក៏ក្បាលខ្ញុំហ្នឹង ដង្កូវវារុក វើកៗ ខ្ញុំចេះឆ្ងល់ រួចចុះក្បាលខ្ញុំម៉េចក៏រុកអីច្រើនម្ល៉េះ ក៏លូកដៃស្ទាប។ ស្ទាបទៅ ចាប់មក អត់ដឹងថាដង្កូវទៀត ព្រោះយប់ ខ្ញុំច្របាច់ទន់ៗ វែងៗបានខ្ញុំថា អ៊ូ! នេះពិតជាដង្កូវហើយ។ ដូច្នេះ ខ្ញុំក៏ប្រឹងដើរ ដឹងថា ខ្ញុំបើយប់នេះ មិនទៅដល់ផ្ទះទេ ប្រាកដជាខ្ញុំងាប់តាមផ្លូវហើយ។ ដើរទៅដល់ផ្លាក់ប្រឡាយ។ អស់ហើយ ខ្ញុំឡើងប្រហែលជាកន្លះម៉ោងជាង ប្រឡាយត្រឹមទ្រូង។ ឡើងល្មមតែរួច រួចហើយក៏ខ្ញុំដើរបន្តបន្តិចៗទៅ រហូតទៅដល់ផ្ទះខ្ញុំ។ ក៏ខ្ញុំគោះទ្វារហៅពុកខ្ញុំថា “ពុកៗ ពុកឯងជួយបេះដង្កូវខ្ញុំបន្តិច”។ រួចឪពុកខ្ញុំគាត់សួរថា “ហ្អេ! អ្អែងក្រែងអ្អែងទៅរៀនសូត្រ អ្អែងម៉េចក៏ឯងមកថ្មើហ្នឹង?” ខ្ញុំក៏ថា “វាយក ពួកវាយកទៅសម្លាប់ទេ គ្មានយកទៅរៀនសូត្រទេ”។ ពេលនោះ ឪពុកខ្ញុំក៏យកសាំងមកចាក់លើក្បាល។ ផ្សាខ្លោចខ្លាំង ដង្កូវក៏ជ្រុះអស់ ហើយគាត់ក៏រៀបកន្លែងប្អូនៗស្រីខ្ញុំ ដាក់ពួនទៅក្នុងៗចងមុង ពួននៅក្នុងសំងំ នៅក្នុងផ្ទះនោះ។ ហើយពេលដែលបានបាយហូបម្តងៗ គឺមិនដែលបានហូបរាងនេះ ម្តាយគាត់ ខ្ញុំមានម្តាយចុង។ បាទ ប្អូនគាត់ដែលគេយកទៅសម្លាប់ជាមួយនឹងខ្ញុំ បងគាត់ក៏គេយកទៅសម្លាប់។ ហើយខ្ញុំប្រាប់ថា ឲ្យគាត់ទៅប្រាប់ថា មិនបាច់ឲ្យទៅទេ ព្រោះគេយកទៅសម្លាប់ហើយ។ គាត់ទៅប្រាប់ ហើយបងគាត់ ៗក៏ថា បក្សយើងមិនដែលយកមនុស្សទៅសម្លាប់ចោលទេបាទ។ ក៏គាត់យកទៅ ឥឡូវបាត់ទល់សព្វថ្ងៃ ងាប់បាត់ហើយគេយកទៅសម្លាប់។ ហើយខ្ញុំក៏សុខចិត្តពួននៅលើផ្ទះ ហូបបាយ។ ជួនកាលបានបាយតែរាងនេះបន្តិចម្តាយខ្ញុំគាត់ទៅធ្វើការប្រមូលបាយសល់ពីគេ ដាក់ក្រមា ពូតមក។ គេសួរថា យកបាយទៅធ្វើអី? គឺថាយកទៅឲ្យឆ្កែស៊ី។ ពេលនោះ ខ្ញុំបានបាយខ្លះ ហើយជួនកាលរាល់ថ្ងៃ ខ្ញុំបានបាយតែរបបក្តួយៗពីរនាក់ពីរចាន់ចង្កឹះ ហូបតែមួយអំបិល។ ហើយឪពុកខ្ញុំក៏គាត់ភ័យខ្លាំង ភ័យដើរទៅចេញពីធ្វើការម្តងៗ គាត់ដើរយំពីរគ្រឡប់ជុំវិញផ្ទះ។ គាត់ប្រាប់ថា “កូន បើកូនឯងគេរកឃើញ គឺគេសម្លាប់អស់ទាំងមួយផ្ទះ”។ ហើយពេលនោះ គាត់ក៏បានយកឆ្កៃស្រែង ហើយនិងល្ពុងខ្ទងកោសស្តើងៗ យកមកដាក់ក្នុងបំពងឫស្សី

ដាក់រងើកភ្លើងហាលឱ្យស្ងួត ផ្តុំខ្ញុំមួយថ្ងៃ ព្រឹកម្តង ល្ងាចម្តង។ ផ្តុំប្រហើរៗ។ គាត់ក៏ធ្លាក់ខ្លួនឈឺទៅ កន្លងទៅ ដល់ខ្ញុំ បើខ្ញុំទៅតាំងពីថ្ងៃទី -- វិលត្រឡប់ពីកន្លែងរំចោល តាំងពីថ្ងៃ២៥ ខែ៥ ១៩៧៨ ជិតដល់ ១៩៧៩។ នៅចុងឆ្នាំ៧៨ ពួកគេក៏ជម្លៀសក្នុងភូមិខ្ញុំហ្នឹង ទៅ -- ក្នុងភូមិខ្ញុំហ្នឹង ជម្លៀសទៅកំពង់ធំទាំងអស់។ ពួកខ្ញុំ ភូមិខ្ញុំ ភាគច្រើន គេរត់ចូលព្រៃរនាមទាំងអស់ នៅសល់ខ្លះដែលទៅកំពង់ធំនោះ ហើយខ្ញុំក៏ទៅនៅជាមួយគាត់នៅក្នុងព្រៃ។ ពេលនោះ គាត់ឈឺផងអីផង គាត់ក៏ស្លាប់នៅក្នុងព្រៃ។

[០៩:៥៧:៥៦]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបញ្ចប់វគ្គដំបូងនៃសក្ខីកម្មរបស់លោក ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក នៅចម្លើយទី៦ គឺឯកសារ E3/4802 លោកបានឆ្លើយថា ពេលដែលលោកចងចាំហេតុការណ៍ទាំងអស់នុំងឡើងវិញ គឺថាធ្វើឱ្យលោកនៅតែមានការឈឺចាប់ ហើយនៅពេលដែលលោកដើរកាត់កន្លែងដែលគេធ្វើទារុណកម្មលោកនោះ គឺថាលោកឈឺចាប់ លោករន្ធត់ លោកចង់សន្លប់ ហើយលោកមិនហ៊ានដើរកាត់កន្លែងហ្នឹងទេ។ តើលោកអាចពន្យល់ជូនតុលាការបានទេ ថាតើលោកទទួលរងការឈឺចាប់ហ្នឹងយ៉ាងម៉េចខ្លះ បានរហូតមកដល់សព្វថ្ងៃហ្នឹង ពេលដែលលោកនឹកឃើញដល់ហេតុការណ៍ដែលលោករៀបរាប់ជូនតុលាការកាលពីព្រឹកមិញនេះ?

**ឆ៖** បាទ ពេលដែលខ្ញុំរួច នៅក្នុងភូមិហើយ ពេលនោះ ដល់គេស្រុក ១៩៧៩រួចហើយ គេក៏ឱ្យខ្ញុំថាទៅមើលរណ្តៅកន្លែងសម្លាប់ ខ្ញុំពុំហ៊ានដើរទៅមើលទេ។ រួចដើរឃើញ កន្លែងខ្ញុំជ្រកដើមទ្រាស គ្រាន់តែខ្ញុំទៅជិះពីក្រោយពីលើម៉ូតូគេ មួយឆ្នាំពីរឆ្នាំហើយ ក៏ខ្ញុំចង់ដួលសន្លប់នៅលើនោះដែរ ព្រោះជាហេតុការណ៍របស់ខ្ញុំ។ ឃើញថា ខ្ញុំទៅមើលមិនអាច ព្រោះអារម្មណ៍ខ្ញុំទប់មិនបាន ព្រោះខ្ញុំគេសម្លាប់ទាំងអស់ នៅរស់តែខ្ញុំម្នាក់។ ដោយអារម្មណ៍ក្តុកក្តួល ហើយវារន្ធត់យ៉ាងខ្លាំង ពេលដែលខ្ញុំត្រូវការភ័យ។ ដល់កន្លែងហ្នឹង ខ្ញុំនឹកថា ខ្ញុំបានរស់រានមានជីវិតមកវិញនេះ ដោយខ្ញុំឆ្លងកាត់កន្លែងសម្លាប់ កន្លែងជ្រក ព្រោះខ្ញុំមិនអាចទៅមើលបានទេ ព្រោះខ្ញុំនៅភ័យនៅតែខ្លាចរហូត។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន សូមសួរសំណួរចុងក្រោយ។ លោកបាននិយាយអំពីរបួសនៅលើក្បាលរបស់លោក តើមកដល់សព្វថ្ងៃហ្នឹង មានលោកនៅមានសល់ស្លាកស្នាមរបួសហ្នឹងនៅលើក្បាលលោកហ្នឹងទេ?

**ឆ៖** បាទ នៅរបួសទាល់សព្វថ្ងៃនេះនៅបីកន្លែង មួយកន្លែងចង់បែកលលាដ៍ហ្នឹងបាទ នៅពីលើក្បាលខ្ញុំបាទ។

[១០:០១:១០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណ លោកប្រធាន សូមអនុញ្ញាតប្រគល់វេទិកាជូនដល់ភាគីផ្សេងទៀត។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី! ខ្ញុំដឹងថាវាជាការលំបាកណាស់សម្រាប់លោកក្នុងការនឹកឃើញហេតុការណ៍ដែលបានកើតឡើងៗវិញ។ ដូច្នេះ ខ្ញុំនឹងសំណួរដែលវាមិនជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការត្រដររស់របស់លោកនៅពេលនោះទេ។ ជាដំបូង ខ្ញុំចង់ដឹងថានៅក្នុងឃុំព្រះធាតុ ស្រុកអូរាំងឪ នៅក្នុងអំឡុងរបបខ្មែរក្រហម តើមានអ្នកណាជាប្រជាជនថ្មី ក៏ដូចជាជនជាតិចាម<ដែលគេបញ្ជូនឲ្យ>ទៅរស់នៅទីហ្នឹងទេ? លោកមានឃើញប្រជាជនថ្មី ឬក៏ជនជាតិចាមរស់នៅក្នុងឃុំរបស់លោកហ្នឹងទេ?

[១០:០២:៣៥]

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ ប្រជាជនថ្មី គេរស់នៅតែក្នុងភូមិគេ ភូមិខ្ញុំអត់មានទេបាទ ហើយជនជាតិអ៊ីស្លាម ក៏គ្មានដែរ។

**ស៖** តើលោកដឹងអ្វីខ្លះពាក់ព័ន្ធទៅនឹងប្រជាជនថ្មីដែលនៅតាមភូមិផ្សេងៗនោះ? ខ្មែរក្រហមគេប្រព្រឹត្តយ៉ាងម៉េចដែរចំពោះប្រជាជនថ្មីទាំងអស់នោះ?

**ឆ៖** បាទ ប្រជាជនថ្មីពេលនោះ គេយកទៅសម្លាប់នៅក្នុងអណ្ដូងដង្កៅសៀនទាំងអស់បាទ នៅក្នុងឃុំព្រះធាតុតែម្ដងបាទ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សះ** តើគេប្រព្រឹត្តអ៊ីចឹងចំពោះប្រជាជនថ្មីទាំងអស់តែម្តង ឬក៏តែចំពោះប្រជាជនប្រភេទណាមួយ ឬក៏ក្រុមណាមួយទេ?

**ឆះ** បាទ ជាប្រជាជនថ្មី ហើយនិងមានគ្រូពេទ្យដែលនៅជំនាន់ៗនេះហ្នឹង គេក៏ចាប់មក កងចល័តក៏ចាប់មក យកទៅសម្លាប់ រួចខ្ញុំឮតែតាមគេ ព្រោះខ្ញុំមិនឃើញដែរបាទ ប៉ុន្តែឃើញថាសម្លាប់ក្នុងរណ្តៅនោះ តាមខ្ញុំដឹងហៀររណ្តៅនៅអណ្តូងដង្កោសៀនខ្លះ ដោយមានស្រីស្អាតៗគេរំលោភស្រោត នៅស្រោតននល ព្រោះគេអ្នកឃើញ គេមកប្រាប់ខ្ញុំបាទ។

**សះ** តើអតីតទាហាន និងអតីតមន្ត្រីរដ្ឋការនៃរបប លន់ នល់ ហ្នឹងត្រូវបានគេកំណត់គោលដៅទុកដោយខ្មែរក្រហមទេ?

**ឆះ** បាទ ខ្ញុំអត់ដឹងដែរ ព្រោះទាហានអត់ឃើញផង នៅកន្លែងហ្នឹង បាទ។

**សះ** នៅក្នុងទម្រង់ព័ត៌មានបន្ថែមគឺឯកសារ E3/6147a លោកបាននិយាយថា លោកបានជួបដឹកនាំខ្មែរក្រហមឈ្មោះ សោ ភឹម គឺជាភាសាខ្មែរ 00581460, ជាភាសាបារាំងគឺ 01139790, និងជាភាសាអង់គ្លេស 01069283។ តើលោកអាចប្រាប់បានទេ លោកជួប សោ ភឹម ក្នុងកាលៈទេសៈណាដែរ? លោកជួបក្នុងពេលប្រជុំ ក្នុងមីទ្ទិង ឬក៏ក្នុងឱកាលណាផ្សេង?

**ឆះ** បាទ ជួបយូរហើយ តាំងពីមុនរបបហ្នឹងចូលមកម្ល៉េះ ព្រោះតាំងពីគាត់ឆ្នាំ -- តាំងពី៧៤, ៧៥។

[១០:០៦:៣១]

**សះ** ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ក្នុងពេលប្រជុំ តើលោកធ្លាប់ជួបមេស្រុក ឬក៏មេតំបន់២២ទេ?

**ឆះ** បាទ មិនដែលជួបទេ ព្រោះខ្ញុំនៅពួនតែក្នុងផ្ទះមិនចេញទៅក្រៅឲ្យគេដឹង។

**សះ** ក៏ប៉ុន្តែខ្ញុំចង់និយាយអំពីពេលដែលលោកជាអនុប្រធានកងចល័តនៅក្នុងឃុំព្រះធាតុ។ លោកជាអនុប្រធាន<កងចល័ត>នៅកោះទន្សាយហ្នឹង អ៊ីចឹងពេលហ្នឹង លោកមានធ្លាប់បានជួបជាមួយប្រធាន -- មេស្រុក ឬក៏ប្រធានតំបន់អីទេ?

**ឆះ** បាទ មិនដែលជួបទេ។

**សះ** តើលោកអាចជម្រាបបានទេថាមានរឿងអ្វីកើតឡើងចំពោះមេកងចល័ត គឺជាអ្នកដែលតែងតាំងលោកឲ្យ -- ចាត់តាំងលោកឲ្យធ្វើជាអនុប្រធានកងហ្នឹង? ខ្ញុំចាំឈ្មោះដូចជា សាម៉េត។ តើមាន

រឿងហេតុអ្វីកើតឡើងចំពោះគាត់ដែរ?

**ឆ៖** បាទ គាត់ឥឡូវគេយកទៅវ៉ៃ សម្លាប់មុនខ្ញុំផង បាត់ឈឹង។

**ស៖** លោកដឹងទេថា ក្រុមណាដែរ ដែលគេនាំគាត់ទៅហ្នឹង ក្នុងចំណោមក្រុមណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ដឹងក្រុមណាដែរ ព្រោះវត់ទៅផ្ទះរៀងខ្លួន គេហៅទៅ។ ខ្ញុំអត់ដឹង។

**ស៖** មុននេះលោកបាននិយាយថា នៅកន្លែងដែលគេសម្លាប់មិត្តភក្តិរបស់លោក ហើយពេលដែលគេរុញឲ្យលោកធ្លាក់ទៅក្នុងរណ្តៅហ្នឹង លោកថាមានអ្នកនិរតី។ អ៊ីចឹងខ្ញុំចង់ដឹងថា តើកម្មាភិបាលនិរតីហ្នឹងចូលមកនៅក្នុងភូមិភាគបូព៌ាហ្នឹង នៅពេលណាដែរ?

**ឆ៖** បាទ ចូលមកហ្នឹងមុនដែលសម្លាប់ខ្ញុំប្រហែលជាបីបួនខែ បាទ។

**ស៖** ក្នុងទម្រង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកគឺ E3/4802, ជាភាសាខ្មែរ 00516888, ជាភាសាបារាំង 00950201, ជាភាសាអង់គ្លេស 00916885 លោកបានផ្តល់ឆ្នាំច្បាស់លាស់ណាស់ គឺលោកថា៖ "នៅឆ្នាំ១៩៧៧ ខ្ញុំឃើញពួកនិរតីចូលមក។ ពួកហ្នឹង<និយាយរដឹន>។ <តាំងពីពេលដែល>ពួកគេ<បានមកដល់ ពួកគេបានចាប់ផ្តើម>តាមដាន<ពិនិត្យមើលប្រវត្តិរូប>របស់ពួកយើង <ដូចជាតួនាទី និង>ឋានៈ<ពីមុនមក។ អ្នកដែលធ្លាប់ជា>អភិបាលស្រុក <សមាជិកគណៈ> តំបន់ ប្រធានយោធា ហើយពួកហ្នឹង គឺគេហៅយកទៅរៀនសូត្រ ប៉ុន្តែក្រោយមកទៀតហ្នឹង គឺថាមិនដែលឃើញត្រឡប់មកវិញទេ។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះតាមរយៈចម្លើយរបស់លោកនៅក្នុងពាក្យសុំរបស់លោកនេះ គឺមុនពេលដែលគេនាំលោកទៅ គឺនៅ<ថ្ងៃទី២៥> ខែឧសភា ឆ្នាំ១៩៧៨ហ្នឹង តើលោកមានឃើញគេបោសសម្អាតអ្នកមូលដ្ឋានរបស់លោកហ្នឹង ដោយខាងបូព៌ា -- ខាងនិរតីទេ?

**ឆ៖** បាទ ពិតជាពួកនិរតីហើយ បាទ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះ ប្រកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកដល់ដើមបណ្តឹងរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិក ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ មុនពេលចាប់ផ្តើមសវនាការ។

អញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:២៧ នាទី)*

[១០:២៧:៤១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តអង្គជំនុំជម្រះ សូមប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាបន្ត។ លោកព្រះរាជអាជ្ញា នៅពេលតែ១០នាទីទៀតទេ សម្រាប់ពេល រយៈពេលរបស់លោក។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន ខ្ញុំត្រូវការតែប្រាំប្រាំមួយនាទីហ្នឹងពេកទៅហើយ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកបានឆ្លើយអម្បាញ់មិញថា ពេលដែលគេឲ្យលោកឡើងឡាន គេមិនមែននាំលោកទៅរៀនសូត្រទេ គេយកទៅសម្លាប់ចោល ហើយពេលនុំងគេចងដៃលោក។ លោកក៏បាននិយាយអំពីកំហុសដែលគេស្ដីបន្ទោសឲ្យលោក ហើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកគឺ<ឯកសារភាសាខ្មែរលេខ> 00516889, ជាភាសាអង់គ្លេស 00916885, ជាភាសាបារាំង 00950202។ លោកបាននិយាយដូចតទៅ ពាក់ព័ន្ធនឹងថ្ងៃទី២៥ ឧសភា ឆ្នាំ១៩៧៨ "អ្នក<មកពីខាង>និរតីបាននិយាយ<មកយើង>ថា <ដោយសារ>ពួកអ្នកឯង<មានកំហុសទាំងអស់គ្នា> អ៊ីចឹងយើងត្រូវតែចងដៃ ព្រោះអ្នកឯងមានកាំបិតគ្រាប់បែក អង្គការមិនទុកចិត្តទេ"។ លោកដឹងថា គេបន្ទោសលោកថា តើបានប្រព្រឹត្តកំហុសអ្វីខ្លះទេ គឺក្នុងចំណោមអ្នកទាំងប្រាំបួនដែលគេចាប់ខ្លួនហ្នឹង? ហើយហេតុអីបានជាអង្គការហ្នឹងគេលែងទុកចិត្តពួកលោកនោះ?

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ ដែលគេ -- ព្រោះខ្ញុំអង្កាល់នុំង ខ្ញុំនេះខ្លួនឯងតែម្ដងបាទ អត់មានថាគេចោទប្រកាន់អីនេះទេព្រោះ ពួកនិរតីហ្នឹងគេសុទ្ធតែពួកនិរតីហ្នឹង គឺគេមកសួរថា "បងៗសុំចង ព្រោះអង្គការយើងមិនទុកចិត្ត" គ្រាន់គេថាមិនទុកចិត្តប៉ុណ្ណឹងទេបាទ។

**ស៖** តើលោកធ្លាប់ឮកម្មាភិបាលភូមិភាគនិរតី ឬក៏ពួកកងទ័ពនិយាយថា សោ ភឹម និងមេដឹកនាំ

ភូមិភាគបូព៌ាក្បត់ប្រទេស ឬក្បត់បក្សទេ?

**ឆ៖** បាទ ឮខ្លះដែរ ប៉ុនមានឮតែគេនិយាយតៗគ្នា។

**ស៖** លោកត្រូវបានគេនាំយកជាមួយអ្នកភូមិពីរនាក់ផ្សេងទៀត គឺ <សាន បាន> ហើយនិង <សាត ឌីប> ហើយនិងមនុស្ស<ប្រាំមួយនាក់>ទៀតដែលលោកបានប្រាប់ឈ្មោះផងដែរ គឺមកពីភូមិផ្សេង ប៉ុន្តែនៅឃុំតែមួយ។ តើអ្នកទាំង<ប្រាំបីនាក់ផ្សេងទៀត>ហ្នឹងគ្រាន់តែជាអ្នកភូមិធម្មតា ឬក៏ជាកម្មាភិបាលវ័យក្មេងដូចជាលោកហ្នឹងជាអនុប្រធានកងចល័តហ្នឹង អ៊ីចឹងខ្ញុំចង់ដឹងថាអ្នកផ្សេងហ្នឹងគាត់ពួកគាត់គ្រាន់តែជាប្រជាជនធម្មតាទេ ឬក៏គាត់មានតួនាទីអ្វីដែរ?

**ឆ៖** បាទ គាត់មានតួនាទី ជាអនុ "គ" ឬប្រធាន "គ" ដែរ។

[១០:៣២:១១]

**ស៖** ក្រោយពីរត់រួច លោកបានទៅលាក់ខ្លួននៅក្នុងផ្ទះឪពុករបស់លោក។ អ៊ីចឹងលោកដឹងទេថា តើការចាប់ខ្លួន និងការបោសសម្អាតហ្នឹងនៅតែបន្តទេក្នុងអំឡុងរយៈពេលប៉ុន្មានក្រោយ -- ប៉ុន្មានខែក្រោយពីខែឧសភា ឆ្នាំ៧៨ នៅភូមិភាគបូព៌ានោះ?

**ឆ៖** បាទ ឮតែតៗតាមគេប្រាប់ ព្រោះខ្ញុំនៅពួនអត់ឲ្យគេដឹងបាទ អត់ឲ្យជួបគេសោះ នៅតែក្នុងមុងបាទ។

**ស៖** សំណួរចុងក្រោយ ពីព្រោះថាខ្ញុំមិនសូវយល់ច្បាស់ នៅពេលដែលខ្ញុំអានទម្រង់ព័ត៌មានបន្ថែមរបស់លោកគឺ E3/6147a វាមានតែមួយទំព័រទេ។ អ៊ីចឹងខ្ញុំមិនបាច់ផ្តល់លេខ ERN ទេ។ ខ្ញុំចង់ដឹងថា លោករៀបការនៅពេលណាដែរ គឺនៅចន្លោះថ្ងៃ១៧ មេសា ៧៥ ឬទៅដល់ ០៧ មករា ៧៩ ឬក៏នៅរយៈពេលណាផ្សេង?

**ឆ៖** បាទ ខ្ញុំរៀបការក្រោយពីខ្ញុំដែលគេយកទៅសម្លាប់ហ្នឹង ជិតៗចូល៧៩ ហើយ។

**ស៖** អ៊ីចឹងលោកនិយាយថា ចុងឆ្នាំ៧៨ហ្នឹង លោករត់ទៅលាក់ខ្លួននៅក្នុងព្រៃ ហើយឪពុកលោកប្រហែលជាស្លាប់នៅពេលហ្នឹង។ អ៊ីចឹងកាលការរៀបការហ្នឹងប្រព្រឹត្តទៅយ៉ាងម៉េចនៅក្នុងព្រៃ ឬក៏នៅកន្លែងណា លោកអាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាលោករៀបការហ្នឹងនៅពេលណាឲ្យបានច្បាស់ដែរ ហើយនៅកន្លែងណា?

**ឆ៖** បាទ ការនៅផ្ទះ។ ព្រោះថាស្ងាត់ៗ ដូចថា ដូចជា ដូចខ្ញុំអ៊ីចឹង គឺមានគូដណ្តឹងហ្នឹងយូរហើយ ប៉ុនកាលហ្នឹងគេមិនទាន់ដល់អាយុ ហើយខ្ញុំដល់ខ្ញុំការហ្នឹង មកវិញខ្ញុំឲ្យម្តាយខ្ញុំទៅសួរគេថា គេ

ព្រមរៀបការជាមួយខ្ញុំដែរ ព្រោះខ្ញុំបែកក្បាលអស់ហើយ ធ្វើការអីមិនកើត។ គេក៏សុខចិត្តថានៅរៀបការជាមួយខ្ញុំ ហើយខ្ញុំក៏រៀបការទៅទាំងខ្ញុំងើបពី បែររស់បានទៀត មកពីគេវៃវិញ បីបួនខែ បាទ។

[១០:៣៥:២៦]

**ស៖** ដូច្នេះ ការរៀបការហ្នឹងជាការរៀបការជាផ្លូវការ ខ្មែរក្រហម មានវត្តមានខ្មែរក្រហម ឬក៏លោកគ្រាន់តែរៀបការនៅក្នុងផ្ទះរបស់លោកជាលក្ខណៈគ្រួសារ អត់មានខាងខ្មែរក្រហមអីណាគេចូលរួមទេ?

**ឆ៖** បាទ អត់មានទេ ការស្ងាត់ៗ បាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកព្រះរាជអាជ្ញា។ ជាបន្តសូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា ឡើងមានសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះ។ លោកមានរយៈពេល១៥នាទី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់លោកនៅព្រឹកនេះ។ ខ្ញុំសូមចាប់ផ្តើមសួរដំបូងថា ធ្វើម៉េចបានលោកដឹងប្រាកដប្រជាម្ល៉េះថា ព្រឹត្តិការណ៍ដែលលោកបានរៀបរាប់ព្រឹកមិញ គឺនៅថ្ងៃទី២៥ ឧសភា ១៩៧៨? ម៉េចបានលោកចាំព្រឹត្តិការណ៍នេះ ចាំថ្ងៃខែឆ្នាំពិតប្រាកដម្ល៉េះ?

[១០:៣៦:៥៧]

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ ព្រោះតែចាំ ថ្ងៃនោះនាឡិកាខ្ញុំ មាននាឡិកាពាក់បាទ។ នៅថ្ងៃ២៥ ហើយខ្ញុំកំណត់សរសេរទុក ដៅតាំងពីខ្ញុំមកវិញ ថាថ្ងៃ២៥ ខែ៥ បាទ។

**ស៖** តើលោកដឹងថា នៅថ្ងៃទី២៥ ឧសភា ១៩៧៨ នោះមានព្រឹត្តិការណ៍អ្វីផ្សេងទៀត ក្រៅពី

នេះ កើតឡើងទេ?

**ឆ៖** បាទ ថ្ងៃ-- ក្រៅពីហ្នឹង ខ្ញុំអត់ដឹងដែរ ដឹងតែថ្ងៃនោះដែរ គេហៅខ្ញុំទៅរៀនសូត្រ។

**ស៖** តើលោកដឹងថា ថ្ងៃទី២៥ ឧសភា ១៩៧៨ ចាត់ទុកថា ជាថ្ងៃមួយដ៏សំខាន់សម្រាប់ភូមិភាគបូព៌ាឬ?

**ឆ៖** បាទ ខ្ញុំមិនដឹងដែរ ព្រោះថ្ងៃនោះ ព្រោះខ្ញុំដឹងបាន ចាំតែថ្ងៃដែលនាឡិកាខ្ញុំវាលោត ថ្ងៃ២៥ ព្រោះខ្ញុំចាំ ខ្ញុំកត់ត្រាទុក ខែ៥ ហ្នឹងតែម្ដង ឆ្នាំ១៩៧៨។

**ស៖** នៅថ្ងៃនោះ តើលោកដឹងថាមានការប្រយុទ្ធគ្នាក្នុងទ្រង់ទ្រាយធំដែរទេ រវាងកងទ័ពភូមិភាគបូព៌ា និងកងទ័ពមជ្ឈិម?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** តើលោក<មិន>បានឮទេ<ថា> នៅថ្ងៃនោះ នៅថ្ងៃទី២៥ ឧសភា ៧៨ ឬនៅថ្ងៃណាផ្សេងនោះ <នូវ>សូរគ្រាប់កាំភ្លើង<បាញ់គ្នា>ក្នុងទ្រង់ទ្រាយធំ<>?

**ឆ៖** បាទ ឮតែជិតៗនោះ គ្រាប់របេះរបោះ វាបាញ់ កាលនោះវាចេះតែបាញ់តាពីសតាពាសទៅ អត់ដឹងថាគេប្រយុទ្ធឯណាធំ ទ្រង់ទ្រាយធំទេ។

[១០:៣៩:៥១]

**ស៖** ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្ដាប់។ គឺជាសម្រង់ដែលចេញពីកិច្ចសម្ភាសន៍ថ្នាក់ដឹកនាំស្រុកមកពីភូមិភាគបូព៌ាមួយរូប ដែលបានឆ្លើយជាមួយនឹង ស្ទីវ ហេដឌ័រ គឺឯកសារ E3/387, អង់គ្លេស 00350224, ខ្មែរ00379509 និងបារាំង 00441443។ សូមដកស្រង់៖ "ប៉ុន្តែយើងបានវាយប្រយុទ្ធដើម្បីរំដោះ<អ្នកដែល>ទ័ពរបស់ ប៉ុល ពត <បានចាប់> ប៉ុន្តែយើងបរាជ័យ។ នៅថ្ងៃទី២៥ ឧសភា ការវាយប្រយុទ្ធនេះ គឺថាបានកើតមានឡើងនៅថ្នល់ទទឹង គឺថាមានផ្លូវខ្វែងឆ្លងកាត់គ្នា ផ្លូវមួយគឺទៅ<អូររាំងឪ ទៅទន្លេបិទ និងទៅ>សួង។ ការវាយប្រយុទ្ធកើតមានឡើង <ដែលត្រូវបានដឹកនាំដោយ> កងទ័ព<>ពិការ<នៅក្នុងកន្លែង>ដែលគេត្រូវចាប់ខ្លួននោះ។ ហើយនៅព្រឹកនេះដដែលនេះ គឺថាមានការវាយប្រយុទ្ធមួយទៀតនៅឯទន្លេបិទ<ដែលដឹកនាំដោយកងកម្លាំងរបស់មន្ទីរពាណិជ្ជកម្មរបស់>ភូមិភាគ<> ហើយក៏មានការវាយប្រយុទ្ធមួយទៀត<នៅចុងអង្រ្គងកន្លែងម៉ាស៊ីនក្រឡឹង>ជាមួយកងទ័ពភូមិភាគបូព៌ានេះដែរ។ ហើយលោក អ៊ុក ប៊ុនឈឿន ក៏បានរៀបរាប់អំពីការវាយប្រយុទ្ធទ្រង់ទ្រាយធំមួយ ក្នុងនោះលោក ហេង សំរិន និងលោក ជា ស៊ីម ក៏បានលើកឡើងថាមានការវាយប្រយុទ្ធ

ទ្រង់ទ្រាយធំបែបនេះដែរ។" ខ្ញុំសួរលោកម្តងទៀតមើល <លោកចាំថ្ងៃហ្នឹងដោយសារតែនាឡិការរបស់លោក ឬក៏ដោយសារ>មានការវាយប្រយុទ្ធទ្រង់ទ្រាយធំ <រវាងកងទ័ពបូព៌ាជាមួយនឹងកងកម្លាំងផ្សេងទៀត>?

**ឆ៖** បាទ ខ្ញុំដឹងថ្ងៃហ្នឹង ដោយសារនាឡិកាទេ បើកាលវ៉ៃនោះ វាខ្ញុំអត់ដឹងដែរ ប៉ុនឮតែសូរតែកាំភ្លើង វាមិនដឹងឮពីខាងណាខាងណី ព្រោះខ្ញុំគេចាប់យកទៅឲ្យទៅថ្ងៃហ្នឹងបាទ។

[១០:៤២:២៥]

**ស៖** តើលោក ឬក៏អ្នកដទៃទៀត ដែលលោកបានលើកឈ្មោះមកនិយាយពីព្រឹកមិញនេះ មានចូលរួមពាក់ព័ន្ធក្នុងការប្រយុទ្ធដែរឬទេក្នុងឋានៈលោកនេះជាអនុប្រធានកងចល័ត ខ្លួនលោកផ្ទាល់ និងអ្នកដទៃទៀត មានចូលរួមប្រយុទ្ធដោយផ្ទាល់ដែរទេ?

**ឆ៖** បាទ ខ្ញុំជាកងចល័តអនុ"គ" មិនមែនអនុ"គ" ទ័ពទេណា អនុ"គ" ចល័តហ្នឹង គឺចល័តយុវជន ទេបាទ តែកម្លាំងធ្វើការ មិនមែនអនុ"គ"ទ័ពទេ។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែតើខ្លួនលោកផ្ទាល់ ឬក៏អ្នកដទៃទៀតនោះ មានធ្លាប់បានចូលរួមប្រយុទ្ធប្រឆាំងជាមួយនឹងកងទ័ពមជ្ឈិមដោយផ្ទាល់ដែរទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** ពីខាងដើម លោកបាននិយាយអំពីឈ្មោះ សោ ភឹម។ លោកជម្រាបអង្គជំនុំជម្រះថាលោកបានជួប សោ ភឹម នៅឆ្នាំ១៩៧៤។ តើឱកាសដែលលោកបានជួប សោ ភឹម ហ្នឹងវាជាឱកាសអ្វីដែរ ហើយមានហេតុផលអីដែរ បានជាលោកអាចមានឱកាសទៅជួបដល់ សោ ភឹម នោះ?

**ឆ៖** បាទ កាលនុំង ខ្ញុំបរទេះសេះនៅក្នុងភូមិភាគនុំង ចម្ការកៅស៊ូនុំង ព្រោះក្តោបក្តាប់ដោយទាំងចម្ការកៅស៊ូ ទាំងទ័ពអី គាត់មក ខ្ញុំហៅពួកបរទេះសេះដឹកជ័រហ្នឹង ចូលប្រជុំអី។ អ៊ីចឹងគ្រាន់លើកឡើងពីការងារហ្នឹង អត់មានលើកពីការងារខុសពីហ្នឹងទេ។

**ស៖** តើលោកជួប ក្រោយៗមកទៀត លោកមានបានជួប សោ ភឹម ទៀតទេ ដូចជា នៅមុន ឬក៏នៅថ្ងៃ២៥ ឧសភា ១៩៧៨ នេះជាដើម?

**ឆ៖** បាទ មិនដែលជួបទេ។

[១០:៤៤:៤៣]

**ស៖** ចុះលោកដឹងថាមានអ្វីកើតឡើងចំពោះ សោ ភឹម ដែរទេ នៅថ្ងៃទី០៣ ឧសភា ១៩៧៨ --

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅថ្ងៃទី០៣ មិថុនា ១៩៧៨?

**ឆ៖** បាទ មិនដឹងទេខ្ញុំ វាអត់ដឹង ព្រោះកិច្ចការអីដែលនេះអី ព្រោះខ្ញុំនៅនេះណេះ នៅកងចល័តណេះ ព្រោះមុនថ្ងៃនេះ បើថ្ងៃក្រោយ ក្រោយថ្ងៃ២៥ហ្នឹង ខ្ញុំនៅពួនតែក្នុងផ្ទះ ហើយចងមុងទៀត នៅឯ - - ខ្ញុំអត់ដឹងហេតុអីទាំងអស់ ព្រោះខ្ញុំពួនដែរ។

**ស៖** ចុះធ្វើម៉េចទើបបានជាលោកដឹងថា កងទ័ពដែលចូលរួមពាក់ព័ន្ធនោះ គឺថាមក ជាកងទ័ពដែលមកពីភូមិភាគនិរតី។ <តើ>លោកមាន<ស្គាល់នរណាម្នាក់>ទេ<ក្នុងចំណោមពួកគេទាំងនោះ>?

**ឆ៖** បាទ ពួកនោះ និយាយសុទ្ធតែរដឺន។ បាទ ស្ដាប់អ៊ីចឹង សុទ្ធតែរដឺន ព្រោះអីអត់និយាយដូចពួកខ្ញុំអីនោះទេបាទ។ ព្រោះរដឺន ខ្ញុំមិនដឹងដែរ មិនដឹងនៅខាងណា និរតីៗ ប៉ុន្តែតែពួករដឺន ពួកនិរតីហើយ បាទ។

**ស៖** តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេ និយាយអំពីសំនៀង ឬក៏ថាតុង អ្នកដែលមកពីខាងខេត្តតាកែវ ខេត្តកំពតហ្នឹង មានសំនៀង ឬក៏មានតុងខុសពីតំបន់ដែលលោករស់នៅហ្នឹង ដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ដឹងថាពួកហ្នឹង បើថាពួកនិយាយរដឺន គឺប្រាកដជាដឹងពួកនិរតី អត់ដឹងខេត្តណា ស្រុកណាអីដែរ បាទ។

[១០:៤៦:៥៥]

**ស៖** បាទ ខ្ញុំយល់ហើយអ្វីដែលលោកឆ្លើយនេះ ក៏ប៉ុន្តែលោក តើលោកអាចញែកឲ្យវាខុសពីគ្នាបានទេ រវាងកងទ័ពដែលមកពីភូមិភាគនិរតី និងកងទ័ពភូមិភាគបូព៌ាហ្នឹង គាត់មានសំឡេង សំនៀងហ្នឹងខុសគ្នាយ៉ាងដូចម្ដេច?

**ឆ៖** បាទ និយាយចំទៅ ពួកហ្នឹងនិយាយរដឺនតែម្ដងបាទ។ ពួកខាងនិរតី ខុសតែប៉ុណ្ណឹង។

**ស៖** តើលោកមានចាំពាក្យពេចន៍អ្វីជាក់លាក់ដែលនាំឲ្យលោកអាចសន្និដ្ឋានថា "អ៎! កងទ័ពនេះគឺមកពីភូមិភាគនិរតីហើយ មិនមែនមកពីភូមិភាគបូព៌ាទេ"។ លោកមាននៅចាំពាក្យពេចន៍ ឬក៏ឃ្លាប្រយោគដែលអ្នកទាំងនោះប្រើប្រាស់ដែរទេ?

**ឆ៖** បាទ ខ្ញុំគ្មានចាំអ្វីសោះ។ បើចាំ ចាំតែរដឺន ពួកនិរតី។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើមានអ្នក<>ណាម្នាក់អាចចូលរួមសហការព្រឹត្តិការណ៍ដែលលោកបានរៀបរាប់ព្រឹកមិញទេ ឬក៏ថាមានតែលោកម្នាក់ទេ ដែលដឹងរឿងរ៉ាវទាំងឡាយដែលមានកើត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឡើងនៅចំពោះលោក ឯរឿងដទៃៗទៀត លោកដឹងថា មានអ្នកដទៃទៀតគេដឹងទេ អាចមានព័ត៌មានស៊ីចង្វាក់គ្នាទេ?

**ឆ៖** បាទ រឿងហ្នឹងដឹងតែខ្ញុំទេ បើរឿងអ្វីដែលខ្ញុំកើតឡើងហ្នឹង គឺដឹងតែខ្ញុំ អត់មានអ្នកដទៃដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំអស់សំណួរហើយលោកប្រធាន ប៉ុន្តែមេធាវីជាតិរបស់សហការីរបស់ខ្ញុំមានសំណួរខ្លះទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ!

**សួរដោយលោក លីវ សុវណ្ណ៖**

**ស៖** បាទ សូមគោរពតុលាការ។ សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំឈ្មោះ លីវ សុវណ្ណ ជាមេធាវីជាតិនៅក្នុងក្រុមការពារក្ដីលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួនបន្ថែមទៀត។ ទី១ បន្តពីសហភាតារបស់ខ្ញុំ ដែលលោកថារដឺនហ្នឹង លោកអាចឧទាហរណ៍បានទេ សម្ដីដែលលោកថា ជានិរតី ដែលរដឺនហ្នឹង។ តើរដឺនរបៀបម៉េច? លោកអាចរំឭកការចងចាំរបស់លោកថាពាក្យណាមួយដែលលោកគិតថារដឺនហ្នឹង យ៉ាងម៉េចបានទេ បាទ?

[១០:៥០:០០]

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ រដឺនៗហ្នឹងខ្ញុំនេះដែរ ប៉ុន្តែគ្រាន់តែឮថានិយាយរដឺនៗអ៊ីចឹង បើខ្ញុំមិនដឹងថាតាមពាក្យដូចពាក្យខាងណាដែរ គ្រាន់តែសម្ដីរដឺន និយាយរដឺនអ៊ីចឹង។

**ស៖** លោកអាចរកនឹកមើលថាពាក្យរដឺនហ្នឹងលោកឧទាហរណ៍ថាពាក្យអីមួយដែលលោកគិតថារដឺនខុសពីតំបន់ដែលលោករស់នៅហ្នឹង?

**ឆ៖** បាទ ខ្ញុំដូចថា ក្នុងតំបន់ហ្នឹងដូចថាគ្មានអ្នកណានិយាយរដឺន តែនិយាយរដឺនៗពួកហ្នឹងមកពីនិរតីហ្នងបាទ។ និយាយឲ្យចំឮក្រែងឮគេថាដែរ ក្រែងពួកនៅតាកែវមិនដឹងអីមិនដឹង ព្រោះខ្ញុំអត់ដឹងដែរ ឮថាពួករដឺន ពួកនិរតីហើយ ព្រោះកាលនោះកងទ័ពនៅនឹងទ័ពបូព៌ាអីមិនដែលឮសម្ដីនិយាយអ៊ីចឹងទេ ព្រោះដឹងនិយាយយ៉ាងម៉េចដែរ ពួកខ្ញុំវាដូចថាគ្រាន់តែដឹងថារដឺនប៉ុណ្ណឹងបាទ។

[១០:៥១:១៤]

**ស៖** ពេលដែលលោកដឹងថារដឹនដែលមកពីនិរតីហ្នឹង តើលោកដឹងក្រោយឆ្នាំ១៩៧៩ ឬក៏ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** បាទ ខ្ញុំដឹងត្រង់វាយកខ្ញុំទៅសម្លាប់ចោលហ្នឹងបាទ ឃើញពួកវាហ្នឹងនិយាយជាមួយខ្ញុំសុទ្ធតែរដឹនអ៊ីចឹង ដឹងត្រឹមហ្នឹងទេ។

**ស៖** ឥឡូវខ្ញុំបែរមករឿងដែលលោករៀបអាពាហ៍ពិពាហ៍វិញ។ តើពេលដែលលោករៀបអាពាហ៍ពិពាហ៍ហ្នឹង ប្រពន្ធរបស់លោកហ្នឹងគាត់ធ្វើការនៅកងចល័ត ឬមួយក៏ធ្វើការនៅក្នុងភូមិ?

**ឆ៖** បាទ នៅកងចល័តហ្នឹង ប៉ុនការមកនៅក្នុងភូមិជិតបែកហើយហ្នឹង គេរត់ ថាចេញពីអស់ទៅពីកន្លែងចល័ត នៅតាមផ្ទះ។

**ស៖** នៅក្នុងឯកសារមានលេខ E3/6147a ដែលលេខ ERN ជាភាសាខ្មែរមានលេខ 0058 1459, ERN ជាភាសាអង់គ្លេសមានលេខ 01069283, ERNជាភាសាបារាំងមានលេខ 01139790។ ពេលហ្នឹងលោកបានថ្លែងថាពេលការហ្នឹង គឺមានរៀបម្តងហ្នឹងមាន២០គូ។ តើ២០គូហ្នឹង លោកនៅចាំថាមានអ្នកភូមិលោកទាំង២០គូ ឬមួយមកពីភូមិផ្សេងៗដែរ?

**ឆ៖** បាទ កាលពេលហ្នឹងគឺ២០គូហ្នឹង បើនិយាយចំទៅទូទាំងឃុំផង តាមភូមិឯណោះមួយគូ ឯណោះពីរគូទៅ។ បូកសរុបទៅ ការនៅកន្លែងឃុំនោះ២០គូ សាមុននោះបាទ។

[១០:៥៣:៥៥]

**ស៖** អ៊ីចឹងថ្ងៃរៀបការលោកហ្នឹង លោកចាំបានទេនៅក្នុងភូមិលោកហ្នឹង ការជាមួយលោកប៉ុន្មានគូដែរ?

**ឆ៖** បាទ ការស្ងាត់ៗ បើអត់មានទៅនេះឯណា ព្រោះខ្ញុំទើបតែងើបមកពីនេះមក របួសអីហ្នឹងហើយហ្នឹង ខ្ញុំគ្រាន់តែដឹងថាការស្ងាត់ៗទេ ព្រោះការគ្មានប្រាប់ថាប៉ុន្មានគូៗទេ បាទការមានតែចាស់ៗពីរបីនាក់ប៉ុណ្ណឹង មានឯណាចាស់ៗច្រើនឯណា ហើយមានតែសាមីខ្លួន និងម៉ែឪផ្ទាល់ៗប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវីសំណួរក្រៅវិសាលភាព។

**លោក លីវ សុវណ្ណា៖**

បាទ ដោយសារខ្ញុំបាទបញ្ជាក់ពីសហព្រះរាជអាជ្ញា ដែលគាត់បានសួរពីរឿងការរៀបការហ្នឹងគឺជាឯកជន។ អ៊ីចឹងដើម្បីបញ្ជាក់អង្គសវនាការឲ្យបានច្បាស់លាស់ ខ្ញុំសួរបញ្ជាក់បន្ថែមទៅលើសំណួរ

របស់សហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីមកនេះ គឺដើម្បីថ្លែងទុក្ខសោក។

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ហើយពេលវេលាលោកជិតអស់ហើយ។ លោកមេធាវីបើមីក្រូហ្វូន!

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** អម្បាញ់មិញហ្នឹង លោកបានបញ្ជាក់ថា អ្នកដែលចាប់ខ្លួនមកជាមួយលោកហ្នឹង នៅចេញពីភូមិលោកហ្នឹង សុទ្ធតែប្រធាន "គ" ឬអនុ "គ" ហើយក្នុងហ្នឹងមានមកពីភូមិផ្សេងទៀត ដែលលោកស្គាល់ឈ្មោះមាន មិត្តឈិត។ តើ មិត្តឈិត ហ្នឹងគាត់ធ្វើ មានតួនាទីអីដែរនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យហ្នឹង?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហមសិន ចាំឆ្លើយ។

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ មិត្តឈិត ហ្នឹងជាអនុ"គ"កងចល័តដែរ បាទ កង។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ចុះ មិត្តហឹម?

**ឆ៖** បាទ? មិត្តហឹម ម៉េច? មានតែ មិត្តឃឿន, មិត្តឈិត។ មិត្តឃឿន ប្រធាន "គ", មិត្តឈិត , នារី ខន អនុ"គ", នារីឌឹប អនុ "គ"បាទ រួច បងផាត ប្រធាន "គ", ហើយមិត្តហ៊ីម គាត់ប្រធាន "គ", មិត្តបាន ក៏ប្រធាន"គ"ដែរ។

[១០:៥៧:០៦]

**ស៖** បាទមុនហ្នឹងបន្តិច លោកបានថ្លែងថា នៅក្នុងដំណាក់កាលហ្នឹងគឺមានប្រជាជនថ្មី និងមានពេទ្យពីសង្គម។ អ៊ីចឹងតើប្រជាជនថ្មីហ្នឹង មានប៉ុន្មាននាក់ដែរ ដែលគេយកទៅជាមួយលោកហ្នឹង បាទ?

**ឆ៖** បាទ អត់មានទេ មានតែពួកមកពីខាងលើមក គេយកមក មានតែពួកខ្ញុំប្រធាន"គ", អនុ

"គ" កងចល័តនៅប្រធានហ្នឹងចូលជាមួយគេមួយឡាននុំង គឺមកពីខាងលើមក។

**ស៖** អ៊ីចឹងមុនហ្នឹងដែលលោកថាមានប្រជាជនថ្មី ហើយនិងពេទ្យដែលគេយកទៅសម្លាប់ដែរហ្នឹង តើហ្នឹងពេលណាដែរ?

**ឆ៖** បាទ ពេលក្រោយជិតចប់ហើយបាទ គឺគេរើនៅតែនឹងឃុំព្រះធាតុហ្នឹង គេយករើក្នុងអណ្ដូងដង្កៅសៀន។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអស់ពេលហើយ។ សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន សូមអញ្ជើញមានសំណួរ។ លោកស្រីមានពេល ១៥ នាទី បាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់គ្នា។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរសុំបំភ្លឺមួយចំនួន។ លោកបាននិយាយថា ក្រោយពីបានរត់រួច ក្រោយពីពេលដែលគេចាប់ខ្លួនលោកហើយនោះ ហើយនាំរូបលោកទៅរើទម្លាក់រណ្ដៅនោះ លោកបាននិយាយថា លោកបានត្រឡប់ទៅនៅផ្ទះឪពុកម្ដាយរបស់លោកវិញ ហើយលោកលាក់ខ្លួននៅទីនោះ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ លោកបាននិយាយអ៊ីចឹងមែនទេ?

[១០:៥៩:២០]

**លោក យន់ ប៊ីន៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ បាទ។

**ស៖** តើលោកលាក់ខ្លួននៅផ្ទះឪពុកម្ដាយរបស់លោកនោះរហូតដល់មកវា ឆ្នាំ១៩៧៩ បានន័យថា រហូតដល់វៀតណាមចូលមកដល់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ លាក់ជិតដែរ ប៉ុនគេឆ្លើលថា "អ៊ូ! ពួកអាពតវាមកសម្លាប់"អីអ៊ីចឹង។ គេដឹងហូរហែអ៊ីចឹង ខ្ញុំជិតជានេះហ្នឹង គ្រាន់តែចេញឲ្យអ្នកជិតៗហ្នឹងឃើញទៅបាទ។

**ស៖** ខ្ញុំអត់យល់ច្បាស់ តើពេលដែលលោកចេញពីផ្ទះលោកហ្នឹង កាលហ្នឹងនុំង ពេលណាដែរ? សូមលោកជួយបញ្ជាក់បន្តិចមើល៍ ខ្ញុំយល់អត់ច្បាស់។

**ឆ៖** បាទ សូមសំណួរសួរម្ដងទៀត ព្រោះថាចេញពីផ្ទះ ចេញម៉េចបាទ?

**ស៖** បាទ នៅតាមការបកប្រែជាភាសាបារាំងនេះ ខ្ញុំឮថាលោកលាក់ខ្លួននៅផ្ទះរបស់លោក ហើយពេលមួយនោះ លោកបានចេញពីផ្ទះលោក ហើយគេឃើញលោក។ អ៊ីចឹងខ្ញុំសួរលោកថា នៅពេលដែលលោកចេញពីផ្ទះឪពុកម្ដាយលោកនោះនៅពេលណាដែរ ហើយគេឃើញលោកនោះនៅពេលណាដែរ?

**ឆ៖** បាទ ចុងឆ្នាំ៧៨ហើយ ព្រោះគេដឹងថាកន្លែងត្រង់នេះ ព្រោះគេមានកងរំដោះហ្នឹងគេមក គេដឹងថាពួកហ្នឹងវាយចោលហើយ បានគេដឹងលាន់ហើយ បានខ្ញុំចេញ។ មុនបែក៧៩។

**ស៖** បាទ នៅពេលដែលលោកទៅៗដល់ហ្នឹង លោកនិយាយថា លោកលាក់ខ្លួននៅផ្ទះឪពុកម្ដាយលោក ហើយលោកបានលួចរៀបការនៅផ្ទះឪពុកម្ដាយលោកហ្នឹងទៀត។ តើខ្ញុំនិយាយអ៊ីចឹងត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះគឺថាជិតដល់ដាច់ចុងឆ្នាំហ្នឹង ការមុនបែកបន្តិច បាទ។

[១១:០២:៥២]

**ស៖** នៅពេលដែលលោកលោករៀបការនោះ តើលោកនៅកំពុងតែលាក់ខ្លួនដដែលទេ ឬក៏ពេលដែលរៀបការនោះលោកលួចរៀបការហ្នឹង គឺលោកចាប់ផ្ដើមបង្ហាញខ្លួនឲ្យគេអ្នកភូមិផងរបងជាមួយហ្នឹងឃើញហើយ?

**ឆ៖** បាទ គេឲ្យៗឃើញហើយ គេស្គាល់ខ្ញុំ គេដឹងខ្ញុំ ហើយគេមកមើលខ្ញុំហ្នឹងថា អ្នកដែលគេយកទៅវាយចោល រស់រានមានជីវិតហ្នឹង បាទ។

**ស៖** ខ្ញុំសូមឲ្យច្បាស់លាស់ជាងនេះបន្តិចទៀត។ នៅពេលដែលលោកនិយាយថា គេស្គាល់លោកហ្នឹង លោកចង់និយាយថាៗ មានតែបងប្អូនលោកទេ ដែលនៅធ្វើពិធីរៀបការហ្នឹង ឬក៏អ្នកភូមិទាំងអស់ហ្នឹង ដឹងថាលោកលាក់ខ្លួននៅផ្ទះហ្នឹងហើយ ហើយកំពុងរៀបការអ៊ីចឹង?

**ឆ៖** បាទ ដោយគាត់ឃើញថាខ្ញុំនឹង គេដឹងតែខ្ញុំមកពីវ៉ៃចោល ព្រោះកាលនុំងវាថា គេដឹង គេលែងជឿហើយ ព្រោះលែងជឿពួកនិរតីនេះហើយ ព្រោះតែផ្អើលសុះសាយហើយ វាជិតបែកហ្នឹង។ ដល់អ៊ីចេះ ខ្ញុំបង្ហាញខ្លួន ហើយខ្ញុំរៀបការឲ្យគេដឹង គេឮអ៊ីចឹង។ អ្នកភូមិហ្នឹង មិនមែនតែគ្រួសារខ្ញុំទេ អ្នកភូមិដែលស្គាល់ខ្ញុំប៉ុន្មាន គេដឹងខ្លះ គេមិនដឹងខ្លះអ៊ីចឹង។

**ស៖** តើមេភូមិ មេឃុំនោះ នៅពេលនោះៗ ជាអ្នកមកពីនិរតី ឬក៏ជាអ្នក<នៅតំបន់លោក>ទេ?

**ឆ៖** បាទ មេឃុំ ដល់អាជិតបែកហ្នឹង ថាមេឃុំមកពីនិរតី។ បើមេភូមិវិញ គឺមេភូមិថ្មីដែលគេ

ជ្រើសតាំងមក អ្នកអត់ចេះអក្សរ អ្នកស្មោះត្រង់ អ្នកលីលាតអ៊ីចឹង អត់មាននេះអ៊ីចឹង គេចាត់តាំងឲ្យធ្វើជាប្រធានភូមិ។

[១១:០៥:៣៩]

**ស៖** តើមេឃុំហ្នឹងគាត់ដឹងទេ ដឹងថា លោកលាក់ខ្លួននៅផ្ទះឪពុកម្ដាយលោកហ្នឹង មុនពេលដែលវៀតណាមចូលមកដល់ទេ?

**ឆ៖** បាទ អត់ដឹងទេ។

**ស៖** ចុះមេភូមិវិញ គាត់ដឹងទេ?

**ឆ៖** បាទ មេភូមិដឹងបាទ។

**ស៖** បាទ នៅចំណុចចុងក្រោយនៃសំណួរខ្ញុំហ្នឹង លោកបាននិយាយអំពីការរៀបការរបស់លោក ការរៀបការសម្លាត់ហ្នឹង ហើយនៅក្នុងឯកសារ E3/6147a ដែលសហភាតារបស់ខ្ញុំបានដកស្រង់អម្បាញ់មិញជា ភាសាខ្មែរ ERN គឺ00581460, ERN ជាភាសាបារាំងគឺ 01139790, ជាភាសាអង់គ្លេសគឺ <01069283>។ លោកនិយាយថា “<មាន២០>គូ<រៀបការនៅថ្ងៃ>នោះ<>”។ ខ្ញុំសួរថាអ៊ីចេះ <តើនេះជាការរៀប>ការសម្លាត់<> ឬក៏ការជារួម<>?

**ឆ៖** បាទ ការស្លាត់ៗ អត់មានទៅយកគូច្រើនណា ការមួយគូដូចស្លាត់ៗអ៊ីចឹង។

**ស៖** តើអ្នកណាជាអ្នករៀបចំផ្សំផ្គុំឲ្យ ហើយមេភូមិហ្នឹង មានវត្តមាននៅទីហ្នឹងទេ?

**ឆ៖** បាទ មេភូមិគ្មានទេ មានតែម៉ែឪសងខាង និងចាស់ពីរបីនាក់ប៉ុណ្ណោះ។

**ស៖** ចុះការរៀបការ២០នាក់នេះ ដែលខ្ញុំសួរថា ពិធីការហ្នឹងបានប្រព្រឹត្តទៅនៅផ្ទះឪពុកម្ដាយរបស់លោក ឬក៏នៅអីណាវិញទៅអ៊ីចឹង?

**ឆ៖** បាទ គេការ២០គូហ្នឹង គេទៅការឯកន្លែងឃុំនោះ គ្រប់ភូមិទៅការអីនុ៎ងតែម្ដងបាទ។

[១១:០៩:១០]

**ស៖** សំណួរខ្ញុំ ខ្ញុំចង់ដឹងថា ហេតុអ្វីបានលោកនិយាយថា ការរៀបការហ្នឹងជាការរៀបការសម្លាត់នោះ បើការរៀបការហ្នឹងប្រព្រឹត្តទៅនៅសាលាឃុំនុ៎ង ហើយម៉េចក៏លោកថា ជាពិធីការសម្លាត់?

**ឆ៖** បាទ ការ -- មិនមែនការសម្លាត់អី ការដែលរឿងគេប្រកាសគ្រប់ភូមិ អង្គាល់ពីមុនដែលគេយកខ្ញុំទៅវៃចោលម្ដេះ បាទ ការ២០គូនោះ ដែលខ្ញុំការនេះ ការស្លាត់ៗបាទ។ ខ្ញុំនេះហើយ មានការតែបីបួនប្រាំនាក់ម៉ែឪសងខាងប៉ុណ្ណឹង។ បើការសាមុននោះ អា២០គូ គឺ២០គូតាំងពីមុនហ្នឹងម្ដេះបាទ មុន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នឹងគេយកខ្ញុំទៅសម្លាប់ម្ដេះ។

**ស៖** អ៊ីចឹងនៅក្នុងចម្លើយព័ត៌មានបន្ថែមរបស់លោកហ្នឹង ខ្ញុំដកស្រង់ "លោករៀបការនៅក្រោមរបបខ្មែរក្រហមដោយគ្មានការបង្ខិតបង្ខំទេ គឺយើងស្ម័គ្រចិត្តទាំងអស់គ្នា។ ហើយនៅថ្ងៃនោះ យើងទាំងអស់គ្នាមាន ២០គូ ពេលរៀបការហ្នឹង។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំចង់សួរលោកថា នេះចម្លើយនៅក្នុងព័ត៌មានបន្ថែមរបស់លោកហ្នឹង គឺចម្លើយខុសទេ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ការ២០គូហ្នឹង ការតាំងពីមុនម្ដេះ ការតាំងពីគេមិនទាន់យកខ្ញុំសម្លាប់ចោលម្ដេះបាទ។ ខ្ញុំប្រាប់ថាការហ្នឹង ការមាន២០គូ ប៉ុនគេការនៅកន្លែងឃុំ គេថាមួយភូមិដូចពីរបីគូអ៊ីចឹង គេប្រមូលគ្នាទៅប្ដេជ្ញាការនៅមន្ទីរឃុំ ដែលខ្ញុំហ្នឹងវាអត់បានការ ដល់ពេលខ្ញុំមកវិញទីនេះហ្នឹង ខ្ញុំការស្ងាត់ៗប៉ុណ្ណឹងវាជិតបែក៧៩ ហើយហ្នឹង។

**ស៖** អ៊ីចឹងសំណួរខ្ញុំនៅតែដដែលទេ គឺថានៅក្នុងចម្លើយរបស់លោកនោះ លោកនិយាយថា កាលនោះយើងទាំងអស់គ្នា២០គូ រៀបការនោះ។ អ៊ីចឹងសំណួរខ្ញុំនៅតែដដែលទេ តើចម្លើយហ្នឹងនៅក្នុងនេះហ្នឹង តើចម្លើយខុស ឬក៏យ៉ាងម៉េច?

[១១:១១:៤២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំហាក់ដូចជាមិនច្បាស់សោះ ចំពោះប្រយោគដែលលោកស្រីលើកឡើង។ ប្រយោគទី១ គឺពាក់ព័ន្ធសួរអំពីការរៀបអាពាហ៍ពិពាហ៍របស់គាត់ ហើយបន្ទាប់មកប្រយោគទី២ គឺពាក់ព័ន្ធនឹង<ការរៀបការជា>សមូហភាព។ តើ<មានតែមួយសំណួរទេ ដោយបញ្ចូលគ្នានូវឃ្លាទាំងពីរនេះ ដោយនិយាយថា "ខ្ញុំបានចូលរួមការរៀបការជាសមូហភាព">?

**កញ្ញា អង់តា ហ្គីសសេ៖**

បើតាមការបកប្រែជាភាសាបារាំងនេះហ្នឹង គឺបកថា "ខ្ញុំរៀបការនៅក្រោមរបបខ្មែរក្រហមដោយគ្មានការបង្ខិតបង្ខំអីទេ គឺស្ម័គ្រចិត្តទាំងអស់គ្នា។ កាលនោះយើងទាំងអស់គ្នាមាន ២០គូ ដែលរៀបការហ្នឹង។" អ៊ីចឹងខ្ញុំសូមលើកឡើងថា គាត់ ចម្លើយគាត់នេះវាមានភាពផ្ទុយគ្នា។ ឥឡូវនេះ គាត់ឆ្លើយផ្សេង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាមានការ -- មានបញ្ហាបកប្រែភាសា ព្រោះជាភាសាអង់គ្លេស គេបកប្រែផ្សេង។ ខ្ញុំដកស្រង់ជាភាសាអង់គ្លេសនៅទំព័រ 01069283 ជាភាសាអង់គ្លេស។

[១១:១២:៥៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើអាចអានជាភាសាខ្មែរបានដែរទេ ដោយសារតែ<វាជា>ភាសា<ដើម ហើយគេ>បកប្រែ<មកពី>ភាសាខ្មែរ។ <ដូច្នេះតើវាបញ្ជាក់ច្បាស់លាស់ទេ?>

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំសូមបញ្ចប់បន្តិចសិនលោកស្រីចៅក្រម។ "<ខ្ញុំបានរៀបការនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែ>គឺខ្ញុំមិនមានការបង្ខិតបង្ខំនោះទេ ខ្ញុំស្ម័គ្រចិត្ត"។ (ហើយបន្ទាប់មកប្រយោគបន្ទាប់ទៀត) "គឺក្នុងពេលដែលរៀបការជាសមូហភាពនោះមាន២០គូ"។ ដូច្នេះ ជាភាសាខ្មែរប្រហែលជាឲ្យខាងតំណាងមេធាវីអានទៅ។

[១១:១៣:៣៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំសូមអានឃ្លារបស់គាត់ជាភាសាខ្មែរ។ ខ្ញុំសូមស្រង់៖ "ខ្ញុំរៀបការនៅរបបខ្មែរក្រហម អត់មានការបង្ខំទេ គឺដោយស្ម័គ្រចិត្ត ការម្ដងមាន២០គូ។ កាលនោះខ្ញុំសួរគេដែរ បើស្គាល់ស្នាមអ៊ីចឹងយកខ្ញុំដែរ? គេក៏ព្រម អត់មានបងប្អូនបង្ខំឲ្យរៀបការទេ។" សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារ លោក ខៀវ សំផន បន្ត។

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងខ្ញុំអស់សំណួរហើយលោកប្រធាន បើក្នុងករណីហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

ជាចុងក្រោយលោក យន់ ប៊ីន តើលោកមានអ្វីចង់រៀបរាប់ថ្លែងពីទុក្ខសោកជាចុងក្រោយដែរឬទេ? ឬក៏លោកមានសំណួរអ្វីចង់សួរ តាំងសំណួរទៅជនជាប់ចោទតាមរយៈប្រធានអង្គជំនុំជម្រះ គឺតាមរយៈយើងដែរឬទេ? បើសិនមានបំណងដូច្នេះ សូមអញ្ជើញ។

[១១:១៥:១៧]

**លោក យន់ ប៊ីន៖**

ខ្ញុំចង់សួរថា កាលនោះ ប្រើថា យកមនុស្សទៅរៀនសូត្រ ចុះហេតុអ្វីបានយកមនុស្សទៅសម្លាប់ចោល? ព្រោះចាំបាច់ ភូតកុហកដល់ ដែលខំនៅធ្វើនៅកងចល័ត ដែលចល័តកាលនោះ ខ្ញុំបញ្ជាក់ប្រាប់ ហើយមិនមែនចល័តទ័ពទេណា ចល័តយុវជន-យុវនារីទេ បាទ។ អ៊ីចឹងសំណួរខ្ញុំថា ហេតុអ្វីបានជាប្រើភាសាថា យកទៅរៀនសូត្រ ហើយបែរជាយកទៅសម្លាប់វិញ បាទ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបដើមបណ្ដឹងរដ្ឋប្បវេណីថា រហូតមកដល់ពេលនេះ ជនជាប់ចោទអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហេតុដូច្នេះសូមលោកជ្រាប។

អង្គជំនុំជម្រះអរគុណលោក យន់ ប៊ីន។ សវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីស្ថានទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកអះអាងថា លោកបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹងអង្គហេតុការបោសសម្អាតផ្ទៃក្នុងដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ។ ហើយអង្គជំនុំជម្រះក៏អរគុណលោក ប៊ុន លឹមហួរ បុគ្គលិកអង្គការ ធី.ភី.អូ ឥឡូវហ្នឹងលោកអាចសម្រាកបានហើយ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក យន់ ប៊ីន វិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់ ឬគោលដៅណាដែលមានបំណងចង់ទៅបានហើយ។ សូមអញ្ជើញ!

និងជាបន្តបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1051 ចូលមកកាន់កន្លែង ថ្លែងរៀបរាប់ទុក្ខសោកនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១១:១៨:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រី ដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអីដែរ?

លោកស្រីចាំមីក្រូហ្វូន ប្រតិបត្តិការចេញភ្លើងពណ៌ក្រហមសិន ចាំលោកស្រីឆ្លើយ។

**លោកស្រី កាន់ សុន្ធរ៉ា៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ កាន់ សុន្ធរ៉ា។

**ស៖** សូមអរគុណ។ លោកស្រីកើតនៅថ្ងៃខែឆ្នាំ ណាដែរ លោកស្រីចាំទេ?

**ឆ៖** ចាស កើតនៅថ្ងៃទី១៦ ខែ១១ ឆ្នាំ១៩៥២។

**ស៖** សព្វថ្ងៃលោកស្រីរស់នៅកន្លែងណាដែរ?

**ឆ៖** ចាស សព្វថ្ងៃរស់នៅក្នុងខេត្តកំពង់ស្ពឺ នៅភូមិរំលោងប្របួះ ឃុំសុព័រទេព សង្កាត់ច្បារមន ខេត្តកំពង់ស្ពឺ។

**ស៖** អរគុណលោកស្រី។ លោកស្រីប្រកបមុខរបរអីដែរ សព្វថ្ងៃ?

**ឆ៖** ចាស សព្វថ្ងៃខ្ញុំជាមន្ត្រីរ៉ែត្រែតពីការងារ កាលមុនធ្វើជាគ្រូបង្រៀន។

**ស៖** អរគុណ។ តើឪពុកម្តាយលោកស្រីគាត់មានឈ្មោះអីដែរ?

**ឆ៖** ចាស ឪពុកខ្ញុំឈ្មោះ កាន់ វ៉ាត, ម្តាយឈ្មោះ ឆេង ផុន។

[១១:២០:០២]

**ស៖** តើប្តីលោកស្រីឈ្មោះអី ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស ប្តីខ្ញុំឈ្មោះ យន់ ពុច ហើយខ្ញុំមានកូនពីរនាក់។

**ស៖** អរគុណលោកស្រី។ លោកស្រី កាន់ សុន្ធរ៉ា ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសវនាការនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និងលោក ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនាំឱ្យលោកស្រីប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត និងជាសម្ពហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្ម ដែលមានចំពោះលោកស្រី មានជាអាទិ៍ ការខូតខាតខាងរាងកាយ សម្ភារៈ ឬ

ផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកដល់បច្ចុប្បន្ន។

[១១:២១:១៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការតាំងសំណួរលើបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន។ ខ្ញុំសូមលោកប្រធានអនុញ្ញាតប្រគល់វេទិកាជូនលោក ហុង គឹមសួន ដើម្បីសួរសំណួរទៅលោកស្រី កាន់ សុន្ទរ៉ា។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ហុង គឹមសួន៖**

បាទ ខ្ញុំបាទសូមអរគុណលោកប្រធាន និងសូមគោរពលោកស្រី លោកចៅក្រម អង្គសវនាការជាទីគោរព។ ខ្ញុំបាទ ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងជាមេធាវីនៃអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។

[១១:២២:១០]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ខ្ញុំសូមសួរសំណួរទៅអ្នកស្រី កាន់ សុន្ទរ៉ា ទាក់ទងជាមួយនឹងការថ្លែងទុក្ខសោកដូចតទៅនេះ។ លោកស្រីសូមរៀបរាប់ខ្លីៗបន្តិច ទាក់ទងជាមួយនឹងការរស់នៅរបស់លោកស្រីមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក្នុងពីរបីថ្ងៃហ្នឹង លោកស្រីរស់នៅកន្លែងណាដែរបាទ?

**លោកស្រី កាន់ សុន្ទរ៉ា៖**

**ឆ៖** ចាស មុនថ្ងៃ១៧ មេសា ១៩៧៥ នាងខ្ញុំរស់នៅក្នុងសង្កាត់លេខ៥ ក្រុងភ្នំពេញ។

**ស៖** បាទ សូមអរគុណ។ កាលនោះនៅក្នុងសមាជិកនៃក្រុមគ្រួសារទាំងមូលរបស់លោកស្រីមានអ្នកណាខ្លះដែរ?

**ឆ៖** ចាស សមាជិកគ្រួសារខ្ញុំកាលណោះមានប្រាំនាក់ មានឪពុកម្ដាយ បងប្រុស បងស្រី ហើយនិងខ្ញុំ។

**ស៖** ក្នុងប្រាំនាក់ហ្នឹង តើនៅលីវទាំង -- ក្រៅពីឪពុកម្ដាយនៅលីវ ឬក៏មានប្ដីមានប្រពន្ធហើយ?

**ឆ៖** ចាស បងប្រុសខ្ញុំ គាត់មានប្រពន្ធហើយ គាត់បែកផ្ទះនៅផ្សេង។ ចំណែកបងស្រីខ្ញុំ គាត់មានកូនបីហើយ ក៏ប៉ុន្តែនៅផ្ទះជាមួយខ្ញុំដែរ ហើយខ្ញុំក៏មានកូនមួយដែរ ហើយនិងពពោះកូនទី២ នៅជុំជាមួយគ្នានឹងឪពុកម្ដាយ។

**ស៖** បាទ សូមអរគុណ។ នៅថ្ងៃ១៧ ខែមេសា ១៩៧៥ មានន័យថាថ្ងៃដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញទាំងមូល តើក្រុមគ្រួសារអ្នកស្រីមានចាកចេញ ឬក៏រស់នៅកន្លែងណាក្រៅពីទីក្រុងភ្នំពេញដែរទេ?

**ឆ៖** ចាស កាលនុំងថ្ងៃទី១៨ មេសា ហ្នឹង ពួកខ្ញុំចេញពីផ្ទះសង្កាត់លេខ៥ហ្នឹងទៅ ដើរតាមមាត់ទន្លេរហូត គឺទៅដល់ស្រុកស្អាង ខេត្តកណ្ដាល ហើយវាឲ្យឡើងមកនៅក្នុងឃុំសិត្បូរិញ។

**ស៖** បាទ សូមៗបញ្ជាក់បន្តិច។ អំមិញអ្នកស្រីមានប្រសាសន៍ថាថ្ងៃ១៨ ខែមេសា។ ថ្ងៃ១៧ ឬថ្ងៃ១៨ ខែមេសា បាទ?

**ឆ៖** ចាស វាដេញយើងចេញថ្ងៃ១៧ដែរ ប៉ុន្តែគ្រួសារខ្ញុំអត់ទាន់ចេញ នៅបានមួយយប់ទៀតទាល់ស្អែកឡើង ថ្ងៃទី១៨ ហ្នឹងបានដើរចេញពីផ្ទះ ដោយពុំបានមានយកសម្ភារៈអីប៉ុន្មានទេ។

[១១:២៥:០២]

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញ អ្នកស្រីមានប្រសាសន៍អំពីថា មានស្វាមី មានកូនស្រីមួយ មានកំពុងតែមានផ្ទៃពោះជិតគ្រប់ខែ។ តើលោកស្រីបញ្ជាក់បានទេ មានផ្ទៃពោះហ្នឹងប៉ុន្មានខែ?

**ឆ៖** ចាស នាងខ្ញុំចាំមិនសូវច្បាស់ដែរ ប្រហែលជា៨ ឬក៏៩ខែ អត់សូវបានចាំច្បាស់។

**ស៖** ចុះអ្នកស្រីសម្រាលកូននៅឯណា ពេលសម្រាលកូន?

**ឆ៖** ចាស ពេលចុះទៅអ៊ីចឹងទៅ ពេលទៅដល់ស្អាង វាឲ្យយើងត្រឡប់មកវិញ នៅឃុំសិត្បូ យើងក៏រៀបចំរកកាប់ឫស្សី កាប់ដើមឈើធ្វើជាខ្ទមសម្រាកនៅខ្លួនឯងអ៊ីចឹងទៅ ហើយក៏បានពីរបីថ្ងៃហ្នឹង ក៏បានសម្រាលកូនទី២ បានកូនប្រុសមួយ។ ដោយឆ្មបវាហ្នឹង គឺគេមានឆ្មបមកឲ្យពីរនាក់មកជួយយើង ឆ្មបហ្នឹងតូចៗ អាយុប្រហែលយ៉ាងច្រើន១២ឆ្នាំ មកជួយបង្កើតកូននាងខ្ញុំ។

**ស៖** អ្នកស្រីមានប្រសាសន៍ទាក់ទងជាមួយសម្រាលកូន មានឆ្មបតូចៗប្រហែល១២ឆ្នាំ។ គេ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចេះក្បួនពេទ្យ របៀបនៃការបង្កើតកូនឲ្យអ្នកស្រីទេ ពេលហ្នឹង?

**ឆ៖** ចាស ដូចជាមិនឃើញចេះអីប៉ុន្មានដែរ ឃើញបងស្រីខ្ញុំមួយដែរ គាត់នៅជួយមើលហ្នឹង ហើយពេលនោះ ក៏យើងកើតដោយសុវត្ថិភាព អត់មានការ មានគ្រោះថ្នាក់អីដែរ។

[១១:២៦:៥៨]

**ស៖** តើពេលសម្រាលកូនហ្នឹង មានថ្នាំពេទ្យ ឬមានកំណាត់ ឬសម្ភារៈសម្រាប់ជួយទំនុកបម្រុងទៅដល់អ្នកស្រីដែរទេ?

**ឆ៖** ចាស អត់មានអីទាំងអស់ គេមកតែខ្លួនទទេហ្នឹង។ ហើយយើងមានថ្នាំពេទ្យខ្លួនឯងដែរ ក៏ប៉ុន្តែគេមិនឲ្យប្រើផង ខ្ញុំមានថ្នាំ មានម្ជុល សេរ៉ាំងអីហ្នឹង ក៏គេប្រមូលយកទៅអស់ដែរ។ ហើយខ្ញុំក៏អត់បានមានផ្អើរភ្លើង ថ្នាំខ្មែរដាំហូបអីហ្នឹង អត់ទាំងអស់។ នៅអត់ចេះផ្អើរភ្លើងកើត។

**ស៖** សូមអរគុណ។ ចុះចំពោះទារក ឬកូនរបស់អ្នកស្រីដែលកើតមកហ្នឹង មានទឹកដោះ ឬក៏មានសុខភាពយ៉ាងម៉េចដែរ មានទឹកដោះឲ្យកូនម៉ឹមគ្រប់គ្រាន់ទេ?

**ឆ៖** ចាស ចំពោះរឿងទឹកដោះឲ្យកូនបៅ គឺអត់សូវមានទេ ហើយខ្ញុំក៏បេះស្លឹករលួសដែលជារបងៗនៅមុខផ្ទះហ្នឹង បេះស្លឹករលួសហ្នឹងស្ងោរជាមួយអំបិលហូបទៅ ដើម្បីឲ្យវាមានទឹកដោះឲ្យកូនបៅ។ ប៉ុន្តែកូនហ្នឹងក៏រស់មិនបានយូរដែរ បានពីរឆ្នាំ ហើយពីរឆ្នាំហើយ កូនហ្នឹងអត់ចេះដើរចេះអីទេ នៅរាងស្គមនៅហ្នឹង។ ក្រោយហ្នឹងពីរឆ្នាំហ្នឹងក៏គ្នាស្លាប់ទៅ។

[១១:២៨:៣៤]

**ស៖** អ្នកស្រីចាំបានទេ តើកូនរបស់អ្នកស្រីស្លាប់នៅឆ្នាំដែរ?

**ឆ៖** ចាស កូនទី១ ស្លាប់នៅឆ្នាំ១៩៧៧ ប្រហែលជាក្នុងខ្ទង់ខែមិថុនា ១៩៧៧ ហើយកូនទី២ ហ្នឹង នៅខែកញ្ញា ១៩៧៧ដែរ។

**ស៖** អំមិញ អ្នកស្រីមានប្រសាសន៍ថា កូនទី១ កូនទី២។ កូនទី១ ឈ្មោះអី? ហើយអាយុប៉ុន្មាននៅពេលដែលស្លាប់នោះ?

**ឆ៖** ចាស ស្រីទី១នោះ ឈ្មោះ ប៉ុច ថារី។ គ្នាអាយុបាន៥ឆ្នាំដែរ គ្នាឈឺរាកមួល ហើមដោយសារពេលខ្ញុំទៅធ្វើការចោលកូន នៅឲ្យអ្នកមើលអីចឹង គ្នា -- ពេលមួយ ខ្ញុំមកទាន់នោះ កូនហ្នឹងកំពុងតែដំរីខ្យងនៅញ៉ាំ។ ខ្ញុំមកដល់ ឃើញអីចឹងក៏ចាប់ស្ទុះទាញពីដៃហើយ វៃកូនមួយដៃទៀត។ វៃកូនមួយដៃ កុំឲ្យថ្ងៃក្រោយញ៉ាំទៀត ខ្ញុំនឹកឃើញថាមកពីញ៉ាំអាហ្នឹងផងអីផង គ្នាខ្វះជីវជាតិផង គ្នាក៏ឈឺរាក

មួលខ្លាំង។ ពេលនៅឈឺតិចៗ យើងសុំពេទ្យឲ្យយកទៅពេទ្យ វាអត់ឲ្យយើងយកទៅទេ។ ទាល់តែកូនហ្នឹងឈឺខ្លាំងមែនទែន លែងដឹងអីហើយ បានវាឲ្យយើងយកមកពេទ្យ។ មកដល់ពេទ្យ យូរដែរ បានគ្នាស្លាប់ ពីព្រោះវាឈឺធ្ងន់ខ្លាំងពេកហើយ។ ចាសអាហ្នឹងកូនទី១។ កូនទី២ក៏អីចឹងដែរ ទាល់តែឈឺខ្លាំងៗ លែងដឹងខ្លួនអស់ហើយ បានវាឲ្យយើងយកមកពេទ្យ ដល់អីចឹងទៅពេទ្យក៏ជួយអត់កើតដែរ។

**ស៖** បាទ សូមអរគុណ។ អំមិញអ្នកស្រីនិយាយអំពីរឿងកូនទី១ កូនទី២ដែលឈឺហើមស្លាប់ដោយសារគ្មានថ្នាំ ឬក៏អត់មានអាហារគ្រប់គ្រាន់។ ចុះនៅពេលដែលកូនរបស់អ្នកស្រីឈឺធ្ងន់ហ្នឹង តើប្ដីឬស្វាមីអ្នកស្រីហ្នឹងគាត់នៅជួយមើលកូនដែរទេ?

[១១:៣០:៤៨]

**ឆ៖** ចាស នៅក្នុងឆ្នាំ១៩៧៦ គឺវាបំបែកហើយ វាបំបែកប្រុសៗយកទៅដាក់កងចល័តរបស់គេមួយកន្លែងឆ្ងាយពីយើងដែលជាស្រី ជាម្ដាយនៅខ្ទមនៅនឹងផ្ទះឯណេះ។ ហើយពេល១០ថ្ងៃអីចឹងទៅបានគេឲ្យឡើងមកផ្ទះម្ដង ដូច្នេះពេលកូនទី១ហ្នឹងស្លាប់ ឪពុក ពេលឈឺអីឪពុកអត់ដឹងអត់បានមើលកូនទេទាល់កូនស្លាប់បានមកផ្ទះទៅដឹងបាត់កូន ហើយសួរខ្ញុំម៉េចបានកូនស្លាប់? មកពីខ្ញុំវ៉ៃកូនពេកទេហ្អីបានកូនឈឺស្លាប់។ ខ្ញុំប្រកែកអ្នកណាទៅវ៉ៃកូនទាល់តែស្លាប់។ បើកូនទី២ស្លាប់ ប្ដីខ្ញុំគាត់អត់ដឹងទេ ព្រោះគាត់នៅនឹងកងចល័តបែកគ្នាដែរ ដូច្នេះបើតាមគាត់ស្មាន គាត់ស្មានថាខ្ញុំអាចនៅមានសល់កូនមួយនៅនឹងខ្លួនដែរ។

**ស៖** សំណួររបស់ខ្ញុំទាក់ទងនឹងប្ដីអ្នកស្រីដដែលទេ ថានៅពេលកូនទី២ កូនប្រុសទី២ ដែលអ្នកស្រីកើតបានប្រហែលពីរឆ្នាំស្លាប់ហ្នឹង តើប្ដីអ្នកស្រីហ្នឹងគាត់បានមកមើលកូនជាចុងក្រោយដែរទេ?

**ឆ៖** ចាស គាត់អត់ដែលបានមកមើលកូនទោះជាកូនឈឺម៉េចក៏ដោយ ក៏គាត់នៅតែធ្វើការអត់ដែលបានមកមើលកូនថៅឈឺទេ ហើយក៏គាត់អត់បានដឹងកូនស្លាប់ដែរ ហើយក៏គាត់បាត់ខ្លួននៅក្នុងថ្ងៃដែលកូនហ្នឹងស្លាប់ដែរ។ បានជាដឹងថាគាត់បាត់ខ្លួន គេយកទៅនៅថ្ងៃដែលកូនស្លាប់ហ្នឹង មកពីកូនស្លាប់ហើយ ខ្ញុំចេញពីពេទ្យមកធ្វើការវិញ ដល់មកធ្វើការវិញអីចឹង ខ្ញុំនៅខាងក្រោមទំនប់ឯណេះ ហើយពួកគាត់អ្នកធ្វើការប្រុសៗហ្នឹងដើរលើទំនប់ ហើយខ្ញុំតាមមើលតាំងពីលេខរៀងទី១ដល់ចុងបញ្ចប់អត់ឃើញស្រមោលប្ដីខ្ញុំអីចឹង។ ដល់ពេលរ៉ឺត្រែត -- ដល់ពេលសម្រាកទៅ ខ្ញុំក៏ដើរទៅរកកន្លែងដែលប្រុសៗគាត់សម្រាកហ្នឹង ហើយសួរទៅៗគេអត់ហ៊ាននិយាយឮៗទេ គេខ្សឹបៗ ថា “គេយកទៅបាត់ម្សិលមិញហើយមិនដឹងយកទៅណាទេ” ហើយខ្ញុំក៏បានដឹងថា អូ៎! ថ្ងៃបាត់ហ្នឹងជាមួយគ្នានឹងថ្ងៃដែលកូនខ្ញុំស្លាប់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ហុង គីមសួន៖**

សូមអរគុណ។ ដោយសារពេលវេលា លោកប្រធាន តើយើងសម្រាកនៅពេលនេះសិន។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ តែខ្ញុំសូមរំឭកដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកនៅសល់ពេល១៥នាទីទៀតនៅពេលត្រឡប់ចូលមករសៀលនេះវិញ។

អង្គជំនុំជម្រះប្រកាសឈប់សម្រាកអាហារថ្ងៃត្រង់ចាប់ពីពេលនេះរហូតដល់ម៉ោងមួយសាមសិបនាទីអញ្ជើញចូលវិញ។ នៅពេលរសៀលនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សេចក្ដីថ្លែងរៀងរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា លោកស្រី កាន់ សុន្ធរ៉ា សវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោករបស់លោកស្រីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះអញ្ជើញលោកស្រី រួមជាមួយបុគ្គលិកអង្គការជាមួយលោកស្រីបន្តផ្ដល់សក្ខីកម្មនៅរសៀលនេះចាប់ផ្ដើមពីម៉ោងមួយសាមសិបនាទីតទៅ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៤ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្ត សូមអញ្ជើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបន្តសំណួររបស់លោក។

**លោក ហុង គីមសួន៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំបាទនឹងបន្តសំណួរពីព្រឹកមិញបន្តទៅលោកស្រី កាន់ សុន្ធរ៉ា បន្តទៀត។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** ជម្រាបសួរលោកស្រី កាន់ សុន្ធរ៉ា ខ្ញុំនឹងបន្តសំណួររបស់ខ្ញុំទៅលោកស្រីថែមទៀតទាក់ទង

ពីព្រឹកមិញ។ ខ្ញុំសួរដល់រឿងប្ដីអ្នកស្រី និងកូនអ្នកស្រីត្រូវបាន ប្ដីត្រូវបានចាប់ និងកូនបានស្លាប់ដោយជំងឺ។ ឥឡូវនេះចូលដល់សំណួរអំពី នៅក្នុងបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីហ្នឹង បានរៀបរាប់អំពីមានបងប្រុសលោកស្រីដែលមានឈ្មោះ ជឹម ឡាង និងបងថ្លៃឈ្មោះ ឱម យិនដូនី និងក្មួយៗ។ តើលោកស្រីជម្រាបអង្គសវនាការបានទេថា តើមានរឿងអ្វីកើតឡើងចំពោះរូបគាត់ទាំងអស់នោះ បាទ? ហើយមានអារម្មណ៍យ៉ាងណាដែរបាទ?

**លោកស្រី កាន់ សុន្ធរ៉ា៖**

**ឆ៖** ចាស ជម្រាបលោកមេធាវី លោកតុលាការ បងប្រុសខ្ញុំគាត់វិស្វករនៅតិចណូជំនាន់ទី១ ហើយដែលពេលគាត់បានត្រូវវាបញ្ជូនជម្លៀសចុះទៅហ្នឹង គាត់ចុះទៅដល់កោះក្របី ហើយវាក៏ហៅគាត់ឲ្យឡើងមកវិញដើម្បីមើលគ្រឿងអគ្គិសនីហ្នឹងនៅផ្សារតូច។ ហើយពេលនោះ ខ្ញុំក៏បានដឹងដំណឹងនេះតាមឪពុកម្ដាយ -- តាមមិត្តភក្ដិរបស់បងប្រុសខ្ញុំហ្នឹង គាត់បានដឹង បានជួប។ គាត់ប្រាប់ថា បងខ្ញុំនៅរស់ទេ គាត់បានឡើងមកភ្នំពេញវិញហើយ។ ខ្ញុំក៏មានចាប់អារម្មណ៍ថា បានបងប្រុសមួយនៅ។ ដល់ពេលក្រោយរបប ប៉ុល ពត យើងបែក៧៩ បានប្រហែលជាមួយខែ បានឮដំណឹងថាបងខ្ញុំហ្នឹងត្រូវគេសម្លាប់នៅទួលស្លែង បានដំណឹងថាគាត់ស្លាប់នៅទួលស្លែង។ ពេលដែលបានទទួលដំណឹងហ្នឹង គឺពេលបាយល្ងាច។ ចាស ទទួលទានបាយលែងកើតហើយ ទឹកភ្នែកហូរ បេះដូងមិនដឹងធ្លាក់ដល់ណាទេ ថ្មើមប្រមាត់អីហ្នឹង។ ហើយស្អែកឡើងក៏នាងខ្ញុំដើរពីស្រែ ដែលចម្ងាយ១៦គីឡូ បានឡើងមកដល់ខេត្តកំពង់ស្ពឺហ្នឹង។ ឡើងមកដល់ខេត្តហើយ ក៏សុំឡានគេជិះឡើងមកមើលនៅគុកទួលស្លែង។ ហើយក៏បានជួបមិត្តភក្ដិនៅគុកទួលស្លែងហ្នឹង គេក៏ជូនដើររក ក៏ឃើញរូបថតបងប្រុសនាងខ្ញុំ ហើយនិងបងថ្លៃស្រីដាក់ពីលើពីក្រោមគ្នាហ្នឹង។ ប៉ុន្តែក្មួយគាត់ពីរនាក់តូចៗដែលយកមកធ្វើជាកូនមកភ្នំពេញជាមួយគាត់ហ្នឹង អត់ឃើញទេ។ ចាស អារម្មណ៍នាងខ្ញុំនៅតែនឹកឃើញបងប្រុសហ្នឹង ពីព្រោះគាត់ជាបងមួយដ៏ស្លូតបូត គាត់មើលថែប្អូន ហើយគាត់ជាអ្នកចូលចិត្តគ្រឿងតន្ត្រី។ គ្រាន់តែឮសូរភ្លេងតន្ត្រីសម័យនុ៎ងគឺថា នាងខ្ញុំទឹកភ្នែកហូរ។ មានតែការសោកស្ដាយគាត់ ដែលបាន -- មិនបានរស់នៅបន្តបានយូរនឹងគេ។ ឃើញបងគេនឹកបងឯង ឃើញឪពុកម្ដាយគេ នឹកឃើញឪពុកម្ដាយឯង។ អារម្មណ៍នាងខ្ញុំនៅតែឈឺចាប់រហូតទល់នឹងសព្វថ្ងៃ ចាស។

[១៣:៣៤:០៣]

**ស៖** បាទ សូមអរគុណលោកស្រី។ ទាក់ទងជាមួយនឹងបងបង្កើតលោកស្រី ខ្ញុំសួរបន្តិចទាក់ទង

ជាមួយនឹងបងថ្លៃ មិនមែនបងបង្កើត ៗបានរៀបរាប់ហើយ។ បងថ្លៃឈ្មោះ ឱម យិនដូនី ឬ យិនដូរី?

**ឆ៖** ចាស *(ឮមិនច្បាស់)*។

**ស៖** សុំម្តងទៀត លោកស្រី។

**ឆ៖** ចាស បងថ្លៃស្រីឈ្មោះ ឱម យិនដូនី។

**ស៖** បាទ សូមអរគុណ។ ឥឡូវទាក់ងទងជាមួយនឹងឪពុកម្តាយបង្កើតលោកស្រីម្តង។ តើមានរឿងអ្វីកើតឡើងចំពោះគាត់ដែរទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬសម័យខ្មែរក្រហមនោះបាទ?

**ឆ៖** ចាស ឪពុកខ្ញុំគាត់ចុះទៅធ្វើការធម្មតាជាមួយតាៗក្នុងភូមិអ៊ីចឹងទៅ ហើយថ្ងៃមួយនៅក្នុងឆ្នាំ៧៧ដែរ ម៉្លុជាខែកុម្ភៈ គេប្រមូលចាស់ៗគ្នាប៉ុន្មានហ្នឹងថា បញ្ជូនឲ្យទៅកាប់ឫស្សី។ ឪពុកខ្ញុំ គាត់ខំយកកំសៀវដាំទឹក យកអីទៅពិសាដែរអីផង ប៉ុន្តែតាំងពីពេលនុំងមក គឺអត់ឃើញគាត់មកផ្ទះវិញរហូតចាស។

**ស៖** ចុះចំពោះម្តាយលោកស្រីវិញ?

**ឆ៖** ចាស ចំពោះម្តាយនាងខ្ញុំ គាត់ស្លាប់ដោយជំងឺ។ ក៏ប៉ុន្តែមុននឹងគាត់ស្លាប់ហ្នឹង គឺគាត់ឈឺនៅយើងការដ្ឋានហ្នឹងយូរ វាអត់ព្រមបញ្ជូនគាត់ទៅមន្ទីរពេទ្យទេ។ ហើយពេលដែលម្តាយខ្ញុំហ្នឹង គេបញ្ជូនទៅមន្ទីរពេទ្យហ្នឹង គឺពេលដែលខ្ញុំនាំកូនឈឺទាំងពីរហ្នឹងទៅពេទ្យស្រុក។ ហើយគេបញ្ជូនគាត់ ទៅពេទ្យឃុំ។ ដល់តែពេលខ្ញុំកូនស្លាប់ទី១អ៊ីចឹង ក៏ដើរមកវិញ ចូរកាត់ពេទ្យឃុំ ជួបគាត់បានតែមួយដងនុំងគាត់នៅពេទ្យឃុំហ្នឹង ជួបបានតែមួយដងនុំង ប្រហែលពេល១ម៉ោង ២ម៉ោងហ្នឹង ខ្ញុំត្រឡប់មកការដ្ឋានវិញ។ ពេលនោះកូនខ្ញុំស្លាប់មួយហើយ នៅមួយពមកឲ្យគាត់ឃើញ។ ហើយបាត់ដំណឹងគាត់រហូត ទល់តែថ្ងៃមួយ បានខ្ញុំឮសួរអ្នកទៅពេទ្យហ្នឹង គេប្រាប់ថាម្តាយខ្ញុំបានស្លាប់ហើយ។ ហើយយើងមិនអាចសុំវាមកមើលម្តាយបានទេ ថាយើងមិនមែនពេទ្យទេ មានពេទ្យគេព្យាបាលហើយ។ យើងទៅនាំខាតការងារ។ ដូច្នេះអត់ដែលបានជួបមុខគាត់យូរខែ។

[១៣:៣៦:៤២]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងក្រៅអំពីលោកឪពុក និងអ្នកម្តាយអ្នកស្រី តើមានបងប្អូនអ្នកស្រីណា ដែលត្រូវបាត់ខ្លួន ហើយក៏ត្រូវបានយកទៅសម្លាប់ ឬក៏បាត់រហូតអី មានដែលតទៀតដែរទេ?

**ឆ៖** ចាស នៅបងថ្លៃប្រុសខ្ញុំមួយទៀត ដែលគាត់ធ្វើជាសាស្ត្រាចារ្យនៅសាលាជម្ពូវ័ន្តនេះ ហ្នឹងពេលខែមេសា ចូលឆ្នាំហើយ ឆ្នាំ៧៧ហ្នឹង វាក៏ពេលល្ងាចមួយនៅការដ្ឋានជីកប្រឡាយហ្នឹង វាហៅគាត់ "ចុល ឯងអស់ថ្នាំជក់ ទៅយកថ្នាំជក់" វាហៅទៅ។ ហើយគាត់អត់មានក្រមាជាប់នឹងខ្លួនអ៊ីចឹង មិត្តភក្តិ

គាត់ហុចក្រមាឲ្យ។ ពេលបណ្ដើរបានបន្តិចទៅ វាក៏យកក្រមាហ្នឹងចងដៃគាត់ ហើយបណ្ដើរទៅបាត់រហូតទៅ។ ហើយការដែលនាងខ្ញុំដឹងហ្នឹង ក៏ដឹងដោយសារមិត្តគាត់ហ្នឹងមានប្រពន្ធធ្វើការជាមួយពួកខ្ញុំអ៊ីចឹងទៅ គេខ្សឹបប្រាប់។ ពេលដែលបានឮដំណឹងថា គេយកប្ដីគាត់ទៅហើយហ្នឹង បងស្រីខ្ញុំមួយគាត់ប្រាប់ខ្ញុំ ចាស ខ្ញុំហូរទឹកភ្នែកយំឡើងខ្យល់ចាប់ យើងរែកដីពេលយប់លែងកើត កោសខ្យល់ពីរនាក់បងស្រីខ្ញុំនៅនឹងមាត់ប្រឡាយហ្នឹង។ បងស្រីខ្ញុំហាមខ្ញុំកុំឲ្យយំ កុំឲ្យម្ដាយខ្ញុំគាត់ដឹង គាត់កើតទុក្ខ។ ចាស ប៉ុន្ដែពេលមកដល់ខ្ទមដែលនៅ គាត់អ្នកយំវិញម្ដង។ ទៅហើយ ម្ដាយខ្ញុំគាត់ដឹងហើយ បាត់កូនមួយទៀតហើយ។

[១៣:៣៨:១៩]

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណ។ លោកប្រធាន ដោយសារឯកសារទាក់ទងជាមួយនឹងបងបង្កើតរបស់លោកស្រី កាន់ សុន្នារ៉ា ខ្ញុំបាទសូមអនុញ្ញាតបញ្ចាំងតាមអេក្រង់ទូរទស្សន៍។ ជាឯកសារលេខ E3/8607 ដែលមានលេខ ERN 00088716 ជាភាសាខ្មែរ, ហើយជាភាសាអង់គ្លេសលេខ ERN 01303367 ទៅដល់ 01303372 ដែលនិយាយអំពីឈ្មោះអ្នកទោសត្រូវយកពីតាខ្មៅផ្នែកអគ្គិសនី នៅឈ្មោះ ជឹម ឡាង លេខរៀងទី៣០។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ ដាក់បង្ហាញលើទូរទស្សន៍នូវឯកសារនេះ។

[១៣:៣៩:២៩]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** លោកស្រី កាន់ សុន្នារ៉ា នេះជាឈ្មោះ ជឹម ឡាង នៅ ដែលមានអង្គភាពនៅផ្សារតូច ផ្នែកជួសជុលភ្លើង។ តើលោកស្រីធ្លាប់ឃើញឯកសារនេះដែរទេ?

**លោកស្រី កាន់ សុន្នារ៉ា៖**

**ឆ៖** ចាស ខ្ញុំធ្លាប់ឃើញឯកសារនេះក្នុងសៀវភៅដែលគេរាយឈ្មោះអ្នកសម្លាប់នៅទួលស្លែង។

**ស៖** បាទ សូមអរគុណ។

**ឆ៖** ចាស។

**លោក ហុង គឹមសួន៖**

លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតបន្តការបញ្ចាំងឯកសារពីរទៀតលេខ E3/10061 ដែលមាន ERN 01012805។ ខ្ញុំបាទមានឯកសារតែភាសាខ្មែរតែមួយមុខនេះទេ។ សូមអនុញ្ញាតបញ្ចាំងបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ដាក់បង្ហាញឯកសារនេះលើអេក្រង់ទូរទស្សន៍។

**លោក ហុង គឹមសួន៖**

ខ្ញុំសូមបន្តតែម្តង ពីព្រោះមានតែពីរទំព័រទេ ថែមមួយទៀត គឺឯកសារលេខ E3/9842 ដែលមានលេខ ERN 01009876 ទៅដល់ 01009981 ហើយនៅក្នុងនេះ មាន ERN ជាភាសាអង់គ្លេសពី 01009961 ទៅដល់លេខ 01009961 ដដែល។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ដាក់បង្ហាញឯកសារនេះ លើអេក្រង់ទូរទស្សន៍។

[១៣:៤១:៣២]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** លោកស្រី កាន់ សុន្នារ៉ា នេះជាឈ្មោះ ឱម យិនដូរី។ អ៊ីចឹងអំមិញខ្ញុំសួរហើយថា តើក្នុងនេះគេសរសេរ ឱម យិនដូរី ឬក៏ ឱម យិនដូនី ពិតប្រាកដបាទ?

**លោកស្រី កាន់ សុន្នារ៉ា៖**

**ឆ៖** ចាស ឱម យិនដូនី ពេលក្នុងឃើញនៅក្នុងសៀវភៅឃើញដាក់ ដូនី ត្រូវដែរ។

**លោក ហុង គឹមសួន៖**

សូមអរគុណ។ ដោយសារនៅក្នុងឯកសារមួយទៀតមានរូបភាពដែលខ្ញុំបាទ ទើបទទួលបាននេះ មិនបានដាក់បញ្ចាំងតាមទូរទស្សន៍ ប៉ុន្តែខ្ញុំបានពីអ្នកស្រី កាន់ សុន្នារ៉ា ដែរ លោកប្រធាន។ ខ្ញុំចង់សួរគាត់ ដោយសារយើងមានតែលើដៃគាត់បែបនេះ តើអនុញ្ញាតឲ្យលើកបង្ហាញបានទេ បាទ?

[១៣:៤២:៤៩]

**ប្រធានអង្គជំនុំ៖**

តើភាគីផ្សេងៗទៀត គាត់យល់ព្រមឲ្យបង្ហាញឯកសារនេះឬទេ?

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំថាអាចបង្ហាញបាន តែសូមបញ្ជាក់អត្តសញ្ញាណឯកសារនេះឲ្យច្បាស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណលោកប្រធាន។ ឯកសារនេះ គឺខ្ញុំបាទមានតែឈ្មោះ ដាក់ប្រវត្តិរូបថត -- ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ដែលមានលេខ D22/18/5។ ឯកសារមិនមាន E3 ទេ គឺមានតែលេខ D22 ហើយមានជា ERN លេខ 00211408 ហើយខ្ញុំមានជាភាសាអង់គ្លេស 00234047, ជាភាសាបារាំងលេខ ERN 00289730។ លេខ D22 ដូចគ្នា គឺនិយាយអំពីឈ្មោះ ឌិម យិនដូនី ជាប្រវត្តិរូបនៅស-២១ បាទ។

តើអ្នកស្រីមានរូបប្រភេទនេះដែរទេ? បាទ សូមអនុញ្ញាតជូនរូបរបស់គាត់នេះ ទៅគាត់។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ្នកស្រីសម្គាល់បានទេ ថារូបថតហ្នឹងពិតជារូបស្រី បងថ្លៃលោកស្រីមែនទេ?

**លោកស្រី កាន់ សុន្នរ៉ា៖**

**ឆ៖** ចាស ពិតជារូបគាត់។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមសួរសំណួរទាក់ទងជាមួយនឹងភាព អារម្មណ៍របស់លោកស្រី ក្រោយពេលដែលលោកស្រីដឹងថា បាត់បង់បងឈ្មោះ ជឹម ឡាង បងថ្លៃឈ្មោះ ឌិម យិនដូនី ឪពុកម្ដាយ ប្ដីអ្នកស្រី កូនៗអ្នកស្រី ឬបងបង្កើត បងថ្លៃទាំងអស់ ដែលពួកគាត់បានបាត់បង់ជីវិតទៅហើយនោះ តើមកដល់សព្វអារម្មណ៍របស់លោកស្រីមានអារម្មណ៍យ៉ាងម៉េចដែរ?

**ឆ៖** ចាស អារម្មណ៍រាល់ថ្ងៃនៅតែនឹកឃើញពួកគាត់ទាំងអស់ និងហាក់ដូចជាថ្មីៗ តែតាមពិតជិត៤០ឆ្នាំហើយ នៅតែនឹកឃើញគាត់ ឃើញឪពុកម្ដាយចាស់ៗគាត់ទៅវត្តអី នឹកឪពុកម្ដាយយើង បងប្រុស បងស្រីសុទ្ធតែបងល្អៗ ស្លូតៗ ហើយចំពោះកូនអីចឹងដែរ។ ឃើញកូនគេដែលមានអាយុដំណាលកូនយើងហ្នឹង ជាពិសេសជួបមិត្តភក្ដិរបស់កូន ឃើញកូនគេដំណាលកូនយើងហ្នឹងគេបានមានចៅ មានអីទៀតហើយ ចាស ខ្ញុំជួបនិយាយអត់កើតទេ។ បានសួរនាំតែមួយម៉ាត់ពីរ គឺទឹកភ្នែកហូរមកហើយ នឹកឃើញកូនយើង។ នឹកឃើញយើងដែលកំព្រានៅតែឯងពិបាក ជាពិសេសពេលឈឺពេលអី អត់មានអ្នកជួយមើលថែទាំ។ គឺថា អារម្មណ៍អត់ដែលភ្លេចពីរឿងរបបចង្រៃដែលធ្វើឱ្យយើងព្រាត់ប្រាសអស់នៅតែម្នាក់ឯងដូចសព្វថ្ងៃ។

[១៣:៤៦:២០]

**ស៖** បាទ សូមអរគុណ។ តើក្រោយពេលលោកស្រីបានរួចជីវិតពីសម័យខ្មែរក្រហមមកដល់សព្វថ្ងៃនេះ ក្នុងខ្លួនលោកស្រី ឬសុខភាពលោកស្រី ដែលមានជំងឺឈឺថ្កាត់អ្វីដែលទាក់ទងជាមួយនឹងអារម្មណ៍ឈឺចាប់របស់លោកស្រីដែរទេ?

**ឆ៖** ចាស ដោយខ្ញុំមានកូនតូចក្នុងសម័យប៉ុលពតហ្នឹង ហើយវាប្រើយើងសព្វគ្រប់ទាំងអស់ រែកដី គាស់គល់ ជីកប្រឡាយ ក្នុងមួយថ្ងៃវាឲ្យយើងឲ្យបាន ៣ម៉ែត្រគូប។ ដល់យប់ឡើងវាឲ្យយើងថែម ១០០អម្រែកទៀត។ ម្ល៉ោះហើយនាងខ្ញុំនៅតែខំប្រឹង ពេលខ្លះយើងទៅធ្វើការអត់រួចសុំច្បាប់គេឈប់ អត់ឲ្យឈប់ យើងនៅតែប្រឹងទៅអ៊ីចឹងទៅ។ ទៅដល់ការដ្ឋាន ខ្ញុំសម្រាកហើយ អត់ធ្វើកើត។ ហើយជំងឺក៏បាននៅបន្សល់ទុកដែរ។ បាយវារីងៗសុទ្ធតែគ្រាប់ពោត។ ចាស ដល់ខ្ញុំមានជំងឺឈឺក្រពះហ្នឹងរហូត ហើយធ្វើការក៏ត្រាំតែទឹក ចេញកន្ទាលគ្រអាកឡើងពេញខ្លួន វាអត់ឲ្យយើងឡើងទេ នៅទាល់តែចប់ដល់ម៉ោងបានវាឲ្យយើងឡើង។ ម្ល៉ោះហើយ ខ្ញុំនៅបន្សល់ជំងឺក្រពះពោះវៀនហ្នឹង ជើងដៃ រាល់ថ្ងៃនៅឈឺខ្លាំង អារៀងជើង ហើយនិងដៃ។ ប្រហែលជាមួយខែមុន ខ្ញុំដើរអត់រួចមួយខែ-- ប្រហែលកន្លះខែ ទើបបានដើរប្រឹងរួចព្យាបាលផងអីផង។ ដូច្នេះរាល់ថ្ងៃហ្នឹងនៅតែព្យាបាលខ្លួនរហូតហ្នឹង ជំងឺបន្សល់ពីរបបហ្នឹងមក។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកស្រី។ សំណួរខ្ញុំមានត្រឹមប៉ុណ្ណេះទេ។ លោកប្រធាន ខ្ញុំបាទអស់សំណួរហើយបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ជាបន្តសូមអញ្ជើញលោកព្រះរាជអាជ្ញាមានសំណួរលើដើមបណ្តឹងរដ្ឋប្បវេណីនេះ។ លោកមានរយៈពេល ១៥ នាទី។ សូមអញ្ជើញ!

[១៣:៤៨:២៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូចសួរលោកស្រីតាំងនាមឱ្យការិយាល័យសហព្រះរាជអាជ្ញា។ ជាដំបូង ខ្ញុំចង់សួរលោកស្រីអំពីសមាជិកគ្រួសាររបស់លោកស្រីដែលត្រូវបានចាប់ខ្លួន ឬក៏ត្រូវបាត់ខ្លួន ប៉ុន្តែមិនត្រូវបាននាំមកស-២១ ទេ។ ឧទាហរណ៍ដូចជា ឪពុករបស់លោកស្រី ឈ្មោះ កាន់ វ៉ាត។ ខ្ញុំដឹងចង់ថា មុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ តើគាត់មានមុខរបបអ្វីដែរ? <តើ>គាត់ធ្វើការឱ្យរបបលន់នល់នៅភ្នំពេញ ឬក៏យ៉ាងម៉េច?

**លោកស្រី កាន់ សុន្ធរ៉ា៖**

**ឆ៖** ចាស មុន ៧៥ ឪពុកខ្ញុំធ្លាប់ធ្វើគយ។ គាត់ធ្វើការ ធ្វើគយនៅរដ្ឋករ។

**ស៖** ក្រោយឆ្នាំ៧៥ តើគេតម្រូវឱ្យគាត់សរសេរប្រវត្តិរូបទេ ហើយបើធ្វើនោះ តើគាត់មានបញ្ជាក់មុខងារគាត់នៅក្នុងប្រវត្តិហ្នឹងថាធ្វើអ្វីដែរ?

**ឆ៖** ចាស នៅឃុំសិត្បូដែលនាងខ្ញុំរស់នៅហ្នឹង ពេលគាត់នេះ អត់បានសរសេរប្រវត្តិរូបថាធ្វើអីទេ ក៏ប៉ុន្តែនៅខាងនុំង ឱ្យតែប្រុសៗគឺវាយកទៅរៀនសូត្រ យកទៅបាត់ៗអត់ សឹងគ្រប់គ្នាប្រុសៗនៅសល់តែអ្នកមូលដ្ឋានទេដែលវាអត់យកទៅ។ ឱ្យតែអ្នកថ្មី ប្រុសៗ វាប្រមូលទៅម្តងបួនប្រាំនាក់ ពីរបីនាក់រហូត។

[១៣:៥០:៤០]

**ស៖** លោក<ស្រី>ដឹងទេថា ខ្មែរក្រហមហ្នឹងគាត់ដឹងថាឪពុកលោកហ្នឹងជាអតីតមន្ត្រីរដ្ឋការទេ? លោកស្រីដឹងអំពីរឿងហ្នឹងទេ?

**ឆ៖** ចាស អត់ដឹងទេ ប៉ុន្តែនៅតែវាយកទៅអ៊ីចឹង។

**ស៖** ចុះបងថ្លៃរបស់លោក អែម ចុល លោក<ស្រី>ថាគាត់ធ្វើការនៅសាលាជម្លូវ័ន្តជាសាស្ត្រាចារ្យ ហើយនិងនៅពុទ្ធិក:វិទ្យាល័យ។ អ៊ីចឹងលោកស្រីដឹងទេថាហេតុអ្វីបានជាគាត់ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោល?

**ឆ៖** ចាស បងប្រុសខ្ញុំគាត់ជាមនុស្សត្រង់ ម្ល៉ោះហើយគាត់ប្រាប់ត្រង់ដែរថា ធ្វើគ្រូបង្រៀន។ ប៉ុន្តែនៅកន្លែងខ្ញុំនៅហ្នឹង អ្នកដាំបន្លែ អ្នករកស៊ីអី ក៏វាយកទៅដែរ ឱ្យតែប្រុសៗ។

**ស៖** ចុះប្តីលោកស្រី នៅពេលដែលគេចាប់ខ្លួននៅខែកញ្ញា ឆ្នាំ៧៧ហ្នឹង លោកស្រីដឹងពីមូលហេតុជាក់លាក់ទេ ថាហេតុអ្វីបានជាគេចាប់ប្តីលោកស្រីហ្នឹង?

**ឆ៖** ចាស អត់បានដឹងមូលហេតុអីជាក់លាក់ផង ព្រោះខ្ញុំនៅបែកគ្នា។ គាត់នៅកងចល័តគាត់

ហើយនាងខ្ញុំកំពុងតែកូនឈឺនៅតាមពេទ្យ បែកគ្នាយូរ។ អត់ដែលបានជួបគ្នាប្រហែលជាមួយខែហើយ។

**ស៖** ចុះក្រោយមក លោកស្រីមានដឹងទេថា គេចាត់ទុកប្តីលោកស្រីហ្នឹងថាជាខ្មាំងនៃរបបខ្មែរក្រហម?

[១៣:៥២:៥៥]

**ឆ៖** ចាស វាមុនចាប់យើង វាចេះតែចោទថាយើងខ្មាំង ហើយវាចាប់ទៅ ឮសួរថាយកទៅទុកនៅកោះគរ យកទៅលត់ដំរៀនសូត្រនៅកោះគរ ហើយកុំអីក៏ខ្ញុំសង្ឃឹមថាប្តីខ្ញុំនៅដែរ ក៏ប៉ុន្តែពេលចុងបញ្ចប់ហ្នឹង មានអ្នកដែលគេរួចពីកោះគរហ្នឹង គេនិយាយថា ពេលថ្ងៃយើង៧មករា ហ្នឹង វាបិទទ្វារផ្ទះអីចឹង វាចោលគ្រាប់បែកសម្លាប់អ្នកដែលនៅឃុំឃាំងនៅកោះគរហ្នឹង។ បានខ្ញុំដឹងថាច្បាស់ជាស្លាប់អស់ហើយ បង ហើយនិងប្តីខ្ញុំអីហ្នឹង។

**ស៖** ខ្ញុំសូមអាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី គឺ E3/4671 ជាភាសាបារាំង 00250788, ជាភាសាខ្មែរ 00211395, ជាភាសាអង់គ្លេស 00239762។ ខ្ញុំសូមដកស្រង់៖ “នៅខែ<វិច្ឆិកា> ឆ្នាំ៧៧ គ្រួសារខ្ញុំ នៅសល់តែ<ប្អូនស្រីខ្ញុំ និងខ្លួន>ខ្ញុំ <>ហើយនិងក្មួយ<ប្រុសពីរនាក់ ហើយខ្ញុំ និងស្ត្រីមេម៉ាយផ្សេងទៀត ដែលប្តីរបស់ពួកគេត្រូវបានគេសម្លាប់ហើយនោះ គឺត្រូវបាន>អង្គការខ្មែរក្រហមបញ្ជូនទៅកោះទឹកវិល នៅក្នុងស្រុក<ស្អាង។> កន្លែងហ្នឹងគឺជាកន្លែងអប់រំកសាងស្ត្រីមេម៉ាយ និងកូនៗ។ ខ្ញុំហើយនិងអ្នកផ្សេងទៀតហ្នឹង ក៏ត្រូវបានចាត់ទុកថាជាប្រពន្ធខ្មាំងដែលត្រូវអង្គការកម្ទេចចោល ហើយត្រូវគេគ្រប់គ្រងហ្នឹង ប្រៀបដូចជាអ្នកទោសដែរ។” សូមបញ្ចប់ការដកស្រង់។ នៅពេលដែលលោកស្រីសរសេរថា លោកស្រីហ្នឹងជាប្រពន្ធខ្មាំង។ លោកស្រីចង់មានន័យថាម៉េចដែរ ហើយតើការរស់នៅកោះទឹកវិលមានសភាពយ៉ាងដូចម្តេចដែរ?

**ឆ៖** ចាស ពេលនៅចុងឆ្នាំ១៧៧ ដែលវាបញ្ជូនទៅកោះគរហ្នឹង ស្រីៗច្រើនហើយនិងកូនតូចៗហ្នឹងសុទ្ធតែអ្នកដែលវាត្រូវយកប្តីទៅ។ គេថាយើងអ្នកពាក់ព័ន្ធជាប្រពន្ធរបស់ខ្មាំងហ្នឹង យកទៅដល់កោះហ្នឹង វាធ្វើបាបមួយសាទៀត។ វាឲ្យយើងធ្វើការធ្ងន់ៗដូចជាប្រុសទាំងអស់ មានការភ្ជួររាស់ ស្ទូងដកអីហ្នឹង យើងធ្វើទាំងអស់ឡើងវិញហ្នឹង ការងារគ្រប់សព្វហ្នឹង ហើយវាបង្អត់អាហារ ដោយវាបបរអង្ករមួយគ្រាប់ៗ ហើយនិងព្រលិត។ ក្នុងនោះមានការស្លាប់ច្រើន មានក្មេងច្រើន ចាស់ៗអីគាត់ស្លាប់ច្រើនមួយសាទៀត។ វាចោទថា យើងសុទ្ធតែប្រពន្ធកូនរបស់ខ្មាំងហ្នឹង។

[១៣:៥៦:១៨]

**ស៖** លោកស្រីថា លោកស្រីអត់មានបានដំណឹងពីកូនរបស់បងរបស់លោកស្រីដែលឈ្មោះ ជឹម ឡាង <និងប្រពន្ធគាត់>ហ្នឹងទេ។ <លោកស្រីនិយាយថា កូនទាំងនោះជាកូនចិញ្ចឹម។> អ៊ីចឹងក្រោយមកទៀតនោះ តើលោកស្រីធ្លាប់ជួបកូនរបស់គាត់ទេ?

**ឆ៖** ចាស អត់ដែលបានជួបកូនគាត់នោះសោះ ខ្ញុំដើររករូបថតនៅទួលស្លែង។ ខ្ញុំទៅទួលស្លែងបានបីដង ដើររកមើលរូបថត អត់ឃើញ។ ហើយរូបថតបងប្រុសខ្ញុំក៏បាត់អស់ដែរ បងប្រុស ហើយបងស្រីនៅទួលស្លែងហ្នឹងទៅមើលបានពីរដង ទៅលើកទី៣បាត់អស់រលីងរូបថត។ រូបថតក្មេងក៏អត់ដែលដឹងដំណឹងដែរចាស។

**ស៖** នៅក្នុងឯកសារ D22/18/5 ជាប្រវត្តិរូបរបស់អ្នកទោស ឱម យិនដូនី គឺបញ្ជាក់ថា គាត់ចូលស-២១ គឺទួលស្លែង គឺមកពីស-២១(យ) គឺនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ដូច្នេះ តើខែវិច្ឆិកា ឆ្នាំ៧៦ហ្នឹង វាត្រូវគ្នាទៅនឹងពេលដែលបងថ្លៃ និងបង<ប្រុស>របស់លោក<ស្រី>បាត់ខ្លួនហ្នឹងទេ? ដូច្នេះ នៅខែវិច្ឆិកា ឆ្នាំ៧៦ ហ្នឹងលោកស្រីចាំថាពេលនុ៎ងហើយដែលបងរបស់លោកស្រី ហើយនិងបងថ្លៃត្រូវបានគេចាប់ខ្លួនហ្នឹង ឬក៏ចាប់ខ្លួននៅមុនហ្នឹងទៀត?

**ឆ៖** ដឹងមុនដែរ ដឹងថាវាហៅយើងឲ្យឡើងមកភ្នំពេញវិញនៅផ្សារតូច ក៏ប៉ុន្តែអត់ដែលបានដឹងថា វាយកទៅទួលស្លែងថ្ងៃណាអីណា ទាល់តែពេលយើងបែកហ្នឹង ដឹងដំណឹងពីឪពុករបស់បងស្រីថា កូនគាត់ស្លាប់ទួលស្លែង បានខ្ញុំឡើងមកស្រាវជ្រាវរកមើលទៅឃើញនៅតាមសៀវភៅ។ សៀវភៅហ្នឹងមានឈ្មោះមានអីចូលទួលស្លែងថ្ងៃណា សម្លាប់ថ្ងៃណាអី ខ្ញុំបានឃើញតាមសៀវភៅហ្នឹងទេ។ ពេលដែលគាត់ចាប់ថ្ងៃនេះហ្នឹង ខ្ញុំអត់បានដឹងទេ។

[១៣:៥៩:០៣]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីកាលបរិច្ឆេទនេះ គឺមានឯកសារ<មួយ>ដែល<យើងមិនធ្លាប់ឮពីមុនមក> គឺឯកសារ E3/8607 ជាបញ្ជីឯកសារស-២១ មានចំណងជើងថា “អ្នកទោសដែលត្រូវយកពីផ្នែកអគ្គិសនីនៅតាខ្មៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦”។ ជាភាសាអង់គ្លេសហ្នឹងគឺ 01303367 ហើយឈ្មោះរបស់បងលោកស្រីហ្នឹងគឺនៅទំព័របន្ទាប់ ហើយចំពោះភាសាខ្មែរគឺ 00088716។ លោកស្រីភ្ញាក់ផ្អើលទេនៅពេលដែលគេបញ្ជូនបងលោកស្រីពីតាខ្មៅមកហ្នឹងតាំងពីខែកុម្ភៈ ឆ្នាំ១៩៧៦ឯណោះ <គឺតាំងពីដើមដំបូងនៃរបបខ្មែរក្រហម>?

**ឆ៖** ចាស ខ្ញុំទើបឃើញដែរ។ ភ្ញាក់ផ្អើល ហើយនឹកថា វាចូលតាំងពីខែកុម្ភៈ ដូច្នេះរយៈពេល

ប៉ុន្មានខែហ្នឹង វាធ្វើបាបយើង ធ្វើបាបគាត់ហ្នឹង។ កាលខ្ញុំនៅបង្រៀនអីចឹងដែរ បង្រៀនដល់ទារុណកម្ម គុកទួលស្លែង នឹកឃើញដល់អនុស្សាវរីយ៍ ប្រហែលជាបងយើងវាធ្វើបាបអីចឹងដែរ។ ម្ល៉ោះហើយ ខ្ញុំបង្រៀនអត់កើត ឲ្យដល់កន្លែងហ្នឹងទឹកភ្នែកហូរ នឹកឃើញតែគាត់។ ប៉ុន្តែកាលឆ្នាំហ្នឹង អត់ទាន់ដឹងច្បាស់ គាត់ស្លាប់ផង មកទើបដឹងច្បាស់ស្លាប់ ក្រោយពី៧៩នេះដែរ។

[១៤:០១:១១]

**ស៖** មានឯកសារផ្សេងទៀតដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែប្រហែលជាមានឯកសារមួយដែលធ្វើឲ្យលោកស្រី និងអង្គជំនុំជម្រះ<ចាប់អារម្មណ៍>នោះ គឺឯកសារ E3/3187 ដែលបញ្ជាក់អំពីកាលបរិច្ឆេទកម្ទេច ឱម យិនដូនី គឺឯកសារនោះ មានចំណងជើងថា "បញ្ជីអ្នកទោសដែលត្រូវបានសម្លាប់<ពី>ថ្ងៃទី០១ វិច្ឆិកា ៧៦ និងទៅដល់ទៅថ្ងៃទី១៥ វិច្ឆិកា ១៩៧៦"។ ជាភាសាខ្មែរគឺ <00008844> ហើយជាភាសាអង់គ្លេស 00874397 ហើយឈ្មោះ ឱម យិនដូនី ហ្នឹង ក៏មាននៅឯកសារ 00874404 ជាភាសាអង់គ្លេសដែរ គឺនៅលេខរៀងទី១៧ មានឈ្មោះបងថ្លៃលោកស្រី ដែលដាក់គេថាមកស-២១ (យ) គឺប្រហែលជាមកព្រៃស ប្រពន្ធរបស់ ជឹម ឡាង ជាងជួសជុលអគ្គិសនី ចូលមកគឺខែ -- នៅថ្ងៃទី០៨ ខែវិច្ឆិកា ៧៦ ហើយកម្ទេច នៅថ្ងៃទី០៩ វិច្ឆិកា ៧៦"។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ តើលោកស្រីដឹងទេថា បងថ្លៃរបស់លោកស្រីហ្នឹង ក៏គាត់ហ្នឹង ក៏ធ្វើការខាងអគ្គិសនីដូចជាបងប្រុសរបស់លោកដែរ?

**ឆ៖** ចាស អត់ដឹងផង។ ប៉ុន្តែដឹងដែរថា យកបានមួយថ្ងៃ ស្អែកឡើងបានវាសម្លាប់ ខ្ញុំមើលដឹងដែរ។ បើបងប្រុសវាយកមកយូរខែ វានៅចោទធ្វើបាបសួរចម្លើយយើង តើយើងចូលស្អីៗ សេ.អ៊ី.អា អីអត់។ ហ្នឹងប្រុស។ បើបងស្រី គាត់ឆាប់ស្លាប់អីចឹង ស្រួល មិនសួរវាបាន បានវាធ្វើបាបបានច្រើនអី ធ្វើបាបខ្លាំងអី។ បើបងប្រុសនៅយូរ។

[១៤:០៣:៤៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

ជាបន្តសូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា តើមានសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ លោកមានរយៈពេល១៥នាទី។ សូមអញ្ជើញ!

**លោក វីុចទ័រ កូប៉េះ៖**

យើងខ្ញុំពុំមានសំណួរទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តីលោក ខៀវ សំផន មានសំណួរទេ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន អត់មានសំណួរទេ។ សូមអរគុណ។

[១៤:០៤:៣២]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

ជាចុងក្រោយនេះ កាន់ សុន្ទរ៉ា តើលោកស្រីមានអ្វីចង់រៀបរាប់ថ្លែងពីទុក្ខសោកវេទនាជាចុងក្រោយដែរឬទេ? ឬក៏លោកស្រីមានសំណួរអ្វីចង់តាំងសំណួរទៅជនជាប់ចោទ តាមរយៈប្រធានអង្គជំនុំជម្រះ គឺតាមរយៈយើង។ បើសិនជាមានបំណងដូច្នេះសូមអញ្ជើញ។

**លោកស្រី កាន់ សុន្ទរ៉ា៖**

ចាស ចំពោះរឿងទុក្ខសោកដែលសំណល់ពីរបបហ្នឹងមក នាងខ្ញុំនៅតែតូចចិត្ត ឈឺចិត្ត នៅតែទឹកភ្នែកពេលណានឹកឃើញ។ វាធ្វើឲ្យយើងនៅតែកំព្រាម្នាក់ឯង ចាស ធ្វើឲ្យយើងឈឺចាប់។ ខ្ញុំមានសំណួរសួរថា តើឪពុកខ្ញុំ បងខ្ញុំ ប្តីខ្ញុំគាត់មានកំហុសអីបានជាវាយកទៅសម្លាប់ដោយសាហាវឃោឃៅព្រៃផ្សៃយ៉ាងនេះ សំណួរទី១។ សំណួរទី២ សូមសួរថា តើមេដឹកនាំកំពូលហេតុម៉េចក៏កំសាកម្ល៉េះមិនហ៊ានប្រឈមមុខទទួលស្គាល់ការពិតនៅក្នុងការកាប់សម្លាប់យ៉ាងរង្គាលព្រៃផ្សៃនេះ ចាសជាសំណួរនាងខ្ញុំ។ ហើយនាងខ្ញុំសូមសំណូមពរមួយបានដែរលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីមានសំណូមពរអ្វីទៅ?

[១៤:០៦:១១៦]

**លោកស្រី កាន់ សុន្ធរ៉ា៖**

ចាស នៅខាងខេត្តកំពង់ស្ពឺនាងខ្ញុំ កន្លែងនៅវត្តពពៃភ្នំហ្នឹងមានធាតុ មានលលាដ៍ក្បាលច្រើន កន្លែងបូជនីយស្ថានហ្នឹងវាចាស់ទ្រុឌទ្រោម នាងខ្ញុំចង់ឲ្យ -- ចង់សុំឲ្យជួសជុលរៀបចំស្អាតបាតគួរជាទីគោរពឡើងវិញ ហើយចង់ធ្វើជាបណ្ណាល័យមួយដើម្បីតម្កល់ឯកសារសៀវភៅរឿងរ៉ាវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីឲ្យក្មេងជំនាន់ក្រោយឲ្យបានដឹងផង ពីព្រោះក្មេងៗទាំងអស់ហ្នឹងអត់ដឹង ហើយអត់ជឿ ពេលខ្ញុំបានឯកសារពីនេះទៅអី ខ្ញុំយកដាក់នៅបណ្ណាល័យ នៅវិទ្យាល័យ ពួកក្មេងៗទាំងអស់ហ្នឹងចូលចិត្តមើលណាស់ ចាសកូនសិស្សអស់ហ្នឹង។ ខ្ញុំមានសំណូមពរប៉ុណ្ណឹងចាស។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សូមជម្រាបលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីថារហូតដល់ពេលនេះ ជនជាប់ចោទនៅតែអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល ហេតុនេះសូមលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីជ្រាប។

អង្គជំនុំជម្រះអរគុណលោកស្រី កាន់ សុន្ធរ៉ា សវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកស្រីអះអាងថាបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខស-២១ បានដល់ទីបញ្ចប់ហើយ លោកស្រីអាចសម្រាកបានហើយ។ សូមអញ្ជើញ!

ជាបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតដែលមានរហស្សនាម 2-TCCP-1050។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1050 រួមជាមួយបុគ្គលិកអង្គការ ធី.ភី.អូ លោក ប៊ុន លឹមហួរ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:១០:០០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកមានឈ្មោះអីដែរ? សូមលោករង់ចាំមីក្រូហ្វូនប្រតិបត្តិការសិន នៅពេលដែលចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**លោក ចៅ ឃឹម៖**

**ឆ៖** ខ្ញុំឈ្មោះ ចៅ ឃឹម។

**ស៖** អរគុណ។ លោកកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ឆ៖** ខ្ញុំកើតនៅថ្ងៃ១៨ ខែ៥ ឆ្នាំ១៩៣៨។

**ស៖** សព្វថ្ងៃលោករស់នៅកន្លែងណាដែរ?

**ឆ៖** សព្វថ្ងៃខ្ញុំនៅផ្ទះក្មួយ ខ្ញុំទៅ ព្រោះខ្ញុំនៅស្រុកបារាំង ហើយនិងស្រុកខ្មែរ ទៅមក។

**ស៖** ឪពុកម្ដាយបង្កើតរបស់លោកឈ្មោះអីដែរ?

**ឆ៖** ម្ដាយបង្កើតរបស់ខ្ញុំឈ្មោះ ឪពុកឈ្មោះ ចៅ សាន ម្ដាយឈ្មោះ នាង កាន ស្លាប់អស់ហើយ។ គាត់ស្លាប់អស់។

**ស៖** លោក ប៊ុន លឹមហួរ លោកទាញមីក្រូហ្វូនគាត់បែរមកខាងនេះបន្តិច ដើម្បីគាត់ស្រួលមើលឃើញភ្លើងក្រហម។ ហ្នឹងហើយ បាទ។ លោកមានកូនប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំមានកូនពីរនាក់ ស្រីមួយ ប្រុសមួយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក។ លោក ចៅ ឃឹម ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងសវនាការនេះលោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្ដាប់អំពីរឿងហេតុ ទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណី ប្ដឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោក មានជាអាទិ៍ ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់បច្ចុប្បន្ននេះ។

អង្គជំនុំជម្រះសូមផ្ដល់វេទិកាទៅសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីតាំងសំណួរលើដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមអនុញ្ញាតលោកប្រធាន អនុញ្ញាតឲ្យលោកមេធាវី គឹម ម៉េងឃី សួរសំណួរទៅលោកដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃឹម។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

[១៤:១៣:៣១]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក គឹម ម៉េងឃី៖**

បាទ សូមអរគុណ។ សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំបាទ គឹម ម៉េងឃី ជាមេធាវីនៃក្រុមមេធាវីគ្មាន -- ពីមុនគ្មានព្រំដែនប្រទេសបារាំង។ ឥឡូវយើងនៅជាក្រុមមេធាវីតំណាងដើមបណ្តឹង ប៉ុន្តែដូរឈ្មោះទៅជាក្រុមការពារក្តីគ្មានព្រំដែនបារាំង ហើយក៏ជាមេធាវីរបស់លោកពូនៅក្នុងសំណុំរឿងផង ហើយនិងបន្តមកក្នុងសំណុំរឿង០០២នេះផង។ បាទ ពាក់ព័ន្ធទៅនីតិវិធីនេះ ខ្ញុំសុំទាំងសំណួរជូនលោកពូដូចខាងក្រោម ដូចតទៅ។

**ស៖** សំណួរទី១ ខ្ញុំសូមសួរលោកពូថាតើ លោកពូពេលដែលមានការនឹកឃើញពីរបបខ្មែរក្រហមនេះ តើមានការឈឺចាប់ ឬក៏មានកំហឹងអ្វីខ្លះចំពោះរបបនេះ ដែលលោកពូមានកន្លងមក បាទ?

**លោក ចៅ ឃឹម៖**

**ឆ៖** សូមគោរពអង្គប្រជុំ សូមគោរពអង្គជំនុំ ជម្រាបលោក លោកស្រីព្រះរាជអាជ្ញា លោក លោកស្រីមេធាវី ជនរងគ្រោះគ្រប់រូប ព្រមទាំងសាធារណជនដែលមានចូលរួមតាមដានសវនាការនៅពេលនេះ។ ថ្ងៃនេះ ខ្ញុំមានកិត្តិយសជាទីបំផុត ដែលបានសាលាដំបូងនៃអង្គប្រជុំជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានអនុញ្ញាតឲ្យខ្ញុំបាទមករៀបរាប់ទុក្ខវេទនា ទុក្ខសោកវេទនារបស់គ្រួសារខ្ញុំ ចំពោះការបាត់បង់ជីវិតរបស់ឪពុកខ្ញុំ បងប្អូនពីរនាក់ ជាពិសេសបង ចៅ សេង – បងប្រុស ចៅ សេង – ក្នុងរបបប្រល័យពូជសាសន៍នៃខ្មែរក្រហម។ ការទុក្ខសោករបស់ខ្ញុំ វាមានទី១ គឺឪពុកខ្ញុំបានស្លាប់ទៅនៅឆ្នាំមួយពាន់ -- គាត់មានអាយុ៧៦ឆ្នាំ បានឈឺជំងឺលើសឈាម។ គាត់បានស្លាប់ ធ្វើការធ្ងន់ បរិភោគមិនគ្រប់គ្រាន់ គ្មានថ្នាំព្យាបាលខ្លះ ស្លាប់ទៅក្នុងឆ្នាំ៧៦ នៅម្តុំស្រុកកំពង់ជ្រៃ។ ឯប្អូនពីរនាក់ទៀត ចៅ សុខយន់ និងប្តី នាង គឹមវ៉ាន ជាកងចល័ត មិនដឹងស្លាប់នៅទីណាទេ។ ប្រហែលស្លាប់នៅចុងឆ្នាំចិតសិប -- ១៩៧៦។ ចំពោះលោក ចៅ សេង គាត់បានត្រឡប់មកមាតុភូមិវិញ ក្នុងឆ្នាំ៧៥ ថ្ងៃ១៩ ខែ១២ បានចូលរួមក្នុងការអប់រំជាមួយមិត្តដទៃទៀតជាច្រើន នៅ ដល់ខែកក្កដា ឆ្នាំ១៩៧៦ អង្គការបានអនុញ្ញាតឲ្យគាត់សរសេរសំបុត្រមកភរិយាគាត់ ឲ្យមកតាមគាត់នៅក្នុងប្រទេស។ រួចមក អង្គការបានបញ្ជូនគាត់ទៅ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01350906



តំបន់ខាងកើតគឺនៅស្រុកស្នួង។

[១៤:១៧:០០]

ដល់ខែសីហា ៧៦ មកដល់ -- គាត់ក៏បានដល់កន្លែងអប់រំសេដ្ឋកិច្ច គ្រប់គ្រងដោយក្រសួងការបរទេស ដែលមានមិត្ត វ៉ាន់ ពីនី ជាប្រធាន, គាត់ជាអនុប្រធាន។ លោក ហោ ណាំហុង និងលោក ស្វាយ បូរី ជាៗសមាជិក។ ដល់ខែកុម្ភៈ ១៩៧៧ បានមកដល់ ក-១៦ (បឹងត្របែក) អង្គការនៅតែធ្វើការអប់រំឱ្យផ្លាស់ប្តូរគំនិតមារយាទពីសង្គមចាស់ មកសង្គម មកនៅកម្រិតមារយាទឯកជន។ តាមៗ បញ្ជា ប៉ុល ពត ឲ្យចាប់ ថៅ សេង នៅៗ -- នេះជាយោងទៅតាមសារភាពរបស់ ឌុច ហើយនិងជាឯកសាររបស់គាត់ គឺថា ប៉ុល ពត បានឲ្យចាប់ ថៅ សេង នៅខែវិច្ឆិកា ឆ្នាំ១៩៧៧។ ហើយឲ្យស-២១ ប្រែឈ្មោះ ថៅ សេង ទៅជា ចិន សួន ហៅ សាន បណ្ឌិតគរុចិត្តសាស្ត្រនៅក្នុងបញ្ជី ពីព្រោះដោយសារតែ ថៅ សេង ជាមនុស្សដ៏ល្បីល្បាញ ដើម្បីជាការបិទបាំងភ្នែកអន្តរជាតិ។ ក្នុងពេលចាប់ ឌុច ឲ្យ -- ឌុច រក្សា ឲ្យគាត់ទុកដោយឡែក ជូនបាយ ផ្តត់ទឹក ជូនទឹកបាយសមរម្យ និងក៏កន្លែងដេកសមរម្យ ដែលចង់គាត់ដែល ឌុច ចង់សងគុណដល់គាត់។ នេះជាសម្តីរបស់ ឌុច។ នៅពេលឃុំពីឆ្នាំ ពីខែ១១ ដល់៧៧ ទៅដល់ ១៩៧៨ – ទៅដល់ខែ០២ ជិត១៩៧៨ – ខ្មែរក្រហម ឲ្យគាត់សរសេរសារភាព១២ដង ដែលមានចំនួនសរុប២០០ទំព័រ មុននឹង នួន ជា បញ្ជាឲ្យយកគាត់ទៅកម្ទេចចោល។ នេះជាឯកសារនៅក្នុង នៅ*ដេកាំ សង់ដឺ ឌុកកីម៉ង់តាស្យុង ឌុយកាំបូដស៍* ហ្នឹង បាទ។ ចំពោះខ្ញុំ និងគ្រួសារ ការបាត់បង់បងប្រុស ថៅ សេង ដូចជាការបាត់បង់ឪពុកទី២។ បាត់បង់បង្គោលគ្រួសារ គ្រួសារៗត្រូវរងទុក្ខវេទនាដ៏ក្រៃលែង ធំធេងដែលមិនអាចរកអ្វីមកប្រៀបបាន។ គ្រួសារចុះក្រីក្រអស់ទីពឹង អស់អ្នក អស់អនាគត អស់អ្នកគ្រប់គ្រង អស់ការគ្រប់គ្រងគ្រប់បែបយ៉ាង។ ចំណែកគ្រួសាររបស់ ថៅ សេង គ្រួសារគាត់ជាគ្រួសារបារាំង និងកូន នៅស្រុកបារាំង គាត់ដឹង។ គាត់តែងតែចាំជានិច្ចថា ថៅ សេង អត់ស្លាប់ទេ គឺគាត់មានទុក្ខវេទនារកអ្វីប្រៀបមិនបាន។

[១៤:២០:០៨]

ចំពោះប្រទេសជាតិវិញ ការបាត់បង់ ថៅ សេង ជា -- ដូចជា បាត់បង់បញ្ញវន្តមួយ ម្នាក់ស្នេហាជាតិ វីរបុរសមួយ គឺអេលីត អ្នកអេលីត អ្នកចម្រើនជឿនលឿន ឆ្លាតវៃ ដ៏ឆ្នើម ដែលមានចូលរួមចំណែកយ៉ាងសកម្មក្នុងការកសាងសង្គមជាតិក្នុងជំនាន់សង្គមរាស្ត្រនិយមពី១៩៥៦ ទៅដល់ ១៩៦៨។ ខ្ញុំសូមជូនលោកចៅក្រម និងអង្គប្រជុំសវនាការនូវជីវប្រវត្តិបងប្រុសខ្ញុំដូចតទៅ ត្រួសៗដូចតទៅ៖

គាត់កើតនៅឆ្នាំ១៩២៩ នៅកម្ពុជាក្រោម ហើយបានមកសិក្សានៅភ្នំពេញ រួចបានទៅសិក្សានៅប្រទេសបារាំងពីឆ្នាំ១៩៤៨ បានមានសញ្ញាប័ត្រខាងអក្សរសាស្ត្របារាំង ជាលីសង់អេសស្លែត ហើយនិងវិបត្តិខាងចិត្តសាស្ត្រគរុកោសល្យ – *ឌីប្លូម ដឺស៊ីកូប៉េដាកូហ្ស៊ី ដឺលុយណាស្តេ ឌីម៉ុងពេយ៉េ*។ ឆ្នាំ១៩៥៦ ទៅ ទៅ៥៧ ជាសាស្ត្រានៅសាលាគរុវិជ្ជា។ ឆ្នាំ១៩៥៨ ជាប្រធានការិយាល័យគណៈរដ្ឋមន្ត្រី *សេហ្វដឺកាប៊ីនេ អូប្រេស៊ីដង់ ឡឺកុងសី* ។ រួចតំណាងរាស្ត្រភ្នំពេញ ជាអនុប្រធានរដ្ឋសភា។ ឆ្នាំ១៩៥៨ ទៅ ៦០ ជារដ្ឋលេខាធិការក្រសួងអប់រំ។

[១៤:២១:៥៣]

ឆ្នាំ១៩៦០ ទៅ ៦២ ជាមន្ត្រី ជារដ្ឋមន្ត្រីក្រសួងឃោសនាការ។ ពី៦២ ទៅ៦៤ ជារដ្ឋមន្ត្រីពាណិជ្ជ -- កសិកម្ម។ ពី៦៤ ទៅ ៦៦ ជាប្រធានការិយាល័យសម្តេចព្រះសីហនុ ព្រះមុខរដ្ឋ – *សេហ្វដឺកាប៊ីនេ ដឺសម្តេច សីហនុ សេហ្វ ដឺ ឡេតា*។ ១៩៦៧ ជាទេសរដ្ឋមន្ត្រីក្រសួងកសិកម្ម -- អ៎! ពាណិជ្ជកម្ម និងសេដ្ឋកិច្ចពីឆ្នាំ១៩៥៨ ទៅ ៦២។ រួចពី៦២ ទៅ៦៦ គាត់បានជាប់ជាតំណាងរាស្ត្រពីរអាណត្តិ។ គាត់ជាអ្នកនិពន្ធកាសែតច្រើន ដូចជា *រេអាល់លីតេ កាំបូដស្យាង, ឡាដឺប៉េស ឌុយកាំបូដស៍, ឡឺ ណាស្យូណាល់លីស, ឡឺ សង្គម ឡឺកាំពូឆា ដឺ* សង្គមរាស្ត្រនិយម។ គាត់ជាប្រធានអ្នកកាសែត ជំនាន់នោះ ជាប្រធានសមាគមអ្នកកាសែត។ ដល់ឆ្នាំ៦៨ ទៅ ៧០ គាត់បានភៀសខ្លួនទៅប្រទេសបារាំង ដោយសារមានការគំរាមកំហែងពី លន់ នល់ បាទ។ ពី៧៥ -- ៧០ ទៅ ៧៥ គាត់ជារដ្ឋមន្ត្រីទទួលបន្ទុកខាងបេសកម្មពិសេសរបស់រដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា ក្រោមការដឹកនាំរបស់សម្តេច សីហនុ។

[១៤:២៣:២៦]

នៅថ្ងៃទី១៩ ខែធ្នូ ៧៥ គាត់បានត្រឡប់មកមាតុប្រទេសវិញ ដើម្បីជួយកសាងប្រទេស។ ក្នុងនាមខ្ញុំជាប្អូនបង្កើតរបស់ ថៅ សេង ការសម្លាប់គាត់ដោយឥតមានទោសពៃ ធ្វើឲ្យមានការឈឺចាប់ឥតឧបមា។ ខ្ញុំបានស្វែងរកការពិតគ្រប់ទីកន្លែង តាំងពីវៀតណាមបានចូលកាន់កាប់កម្ពុជា ស៊ើបសួរអ្នកដែលធ្លាប់រស់នៅជាមួយគាត់ ដែលបានរស់នៅមានជីវិត ដូចជា អៀង គុណាសាគី, លោក សៅ គឹមហុង, លោក *ហេ្សណឺរ៉ាល់* ដួង សំអុល, លោក គឹម គុណ ដែលធ្លាប់រស់នៅជាមួយគាត់នៅបឹងត្របែក។ គាត់ថា ថ្ងៃមួយកំពុងតែបេះត្រកួន មានឡានហ្ស៊ីបមួយមកហៅ គាត់ទៅ យកទៅ តែគ្មានអ្នកណាហ៊ានសួរថាយកទៅណាទេ។ ស្មានតែយកទៅធ្វើការនៅក្រសួងការបរទេសជាមួយ អៀង សារី។ កាលពីឆ្នាំ១៩៨២ ក្នុងឱកាសលោក អៀង សារី មកបំពេញបេសកម្មនៅប៉ារីស ប្រទេសបារាំង ដើម្បីជូនដំណឹង

ដល់ជនរួមជាតិពីស្ថានការណ៍នៅស្រុក នៅក្នុងស្រុក ខ្ញុំបានសុំជួបលោក អៀង សារី ពិភាក្សាពីករណីលោក ថៅ សេង ដែលបាត់ខ្លួន។ គាត់បានប្រាប់ខ្ញុំថានៅបឹងត្របែក គេចែកជាបីៗពួក ពួកទូត ពួកអ្នកនិស្សិត ហើយនិងពួករដ្ឋការចាស់។ ហើយគាត់បានប្រាប់ថានៅក្នុងនោះមានៗឲ្យ អង្គការបានៗឲ្យកម្មាភិបាលម្នាក់ឈ្មោះ អាសារ៉ន – អ៊ុក សារ៉ន – ទទួលខុសត្រូវនៅទីនោះ។ ដល់ថ្ងៃមួយ ឃើញបាត់ពួកទូតជា សាន, មេធាវី ទ្រង់មេធាវី នរោត្តម ភីហ្សារ៉ា មួយម្តងៗ។ បាត់ វ៉ាន់ ពិនី បាត់មក បាត់ពួកប៉ុន្មានហ្នឹង គាត់ក៏ហៅ អាសារ៉ន មកសួរ។ វាថាយកទៅសម្លាប់ចម្ការលើ។ ប៉ុន្តែមែនទែន គឺថាវាយក វាចាប់យកមកដាក់ស-២១ ហើយ។ ហើយតមកទៀត គាត់ថា អាសារ៉ន ហ្នឹង វាជាខ្មាំងៗយកមកដាក់បន្ទប់ក្នុងកន្លែងបញ្ញវន្ត ដើម្បីៗសម្លាប់បញ្ញវន្ត គឺថាចុងក្រោយបានយក អាសារ៉ន ហ្នឹងទៅៗ យកអាសារ៉នហ្នឹងទៅទៅសម្លាប់វិញ។

[១៤:២៦:២៧]

ដោយមានការបាត់ទូតម្តងមួយៗ គាត់ក៏ហៅអាសារ៉ន ហ្នឹងមកសួរ។ ថាតើយកទៅណា? ហ្នឹងហើយ វាថាយកទៅចម្ការលើ។ គាត់ក៏បានបញ្ជាឲ្យវាយកមកវិញ។ ដល់មក គាត់បានប្រាប់ខ្ញុំថា អាសារ៉ន ជាភ្នាក់ងារខ្មាំងបង្កប់ទុកឲ្យសម្លាប់បញ្ញវន្ត។ ក្រោយមក មុននឹងវៀតណាមចូលកម្ពុជា ខ្មែរក្រហមបានចាប់ អាសារ៉ន យកទោសម្លាប់បាទ។

នៅទីបញ្ចប់ ខ្ញុំសូមស្នើឲ្យសាលាដំបូង បើអាចសួរ នួន ជា ហេតុអ្វីបានជាគាត់ឲ្យបញ្ជាទៅ ឌុចឲ្យសម្លាប់? តើ ថៅ សេង មានគំនុំគុំកួនអ្វីនឹងជាមួយខ្មែរក្រហម? តើគាត់មានខុសអ្វី? ហើយខ្ញុំចង់សួរលោក ខៀវ សំផន ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់អ្នកបញ្ញវន្ត អ្នកស្នេហាជាតិ មកជួយកសាងប្រទេស ចោលប្រពន្ធកូន យកទៅសម្លាប់? បើតាមលោក អុង ថុងហឿង អ្នកនិពន្ធសៀវភៅ "ខ្ញុំជឿខ្មែរក្រហម – *សែ ត្រី អូ ខ្មែររូស៍*" អ្នកមកពីបារាំង និងអាមេរិកដែលបានស្លាប់ក្នុងបឹងត្របែកមានចំនួន ២៧៧ នាក់។ សូមអរគុណបាទ។

[១៤:២៨:២១]

**ស៖** បាទ សូមអរគុណលោកពូ ដែលបានអត្ថាធិប្បាយក្បោះក្បាយលម្អិតគួរសមដែរ ពាក់ព័ន្ធទៅនឹងរឿងហេតុទុកក្ខសោករបស់លោកពូ ក៏ប៉ុន្តែនៅខ្ញុំផ្តោតទៅលើចំណុចសំខាន់មួយដែលលោកពូចូលនៅក្នុងនីតិវិធីនេះ គឺធំបំផុតគឺពាក់ព័ន្ធទៅនឹងការបាត់បង់បងប្រុសរបស់លោកពូឈ្មោះថា ថៅ សេង។ ហើយលោកបានរៀបរាប់ថាមានការស្វែងរកការពិតគ្រប់ពេលវេលាទាំងអស់ មិនថាទីកន្លែងណាទេ

រហូតដល់ក្នុងសំណុំរឿងនេះជាក់ស្តែងមានទាំង០១, ០២។ ដូច្នេះ ខ្ញុំសូមតាំងសំណួរពាក់ព័ន្ធទៅនឹងថា ការព្យាយាមស្វែងរកព័ត៌មាន ហើយនិងបានព័ត៌មានខ្លះអំពីសំណុំរឿងនេះ តើបានធ្វើឱ្យលោកពូដឹងអ្វីខ្លះ អំពីទំនាក់ទំនងរបស់បងប្រុសរបស់លោកពូ ចៅ សេង ហ្នឹងជាមួយនឹងរបបខ្មែរក្រហមហ្នឹង ហើយតើលោកពូបានដឹងទេថា មូលហេតុអីដែលគាត់ត្រូវបានគេសម្លាប់នៅក្នុងរបបហ្នឹង?

[១៤:២៩:៤៣]

**ឆ៖** ដោយសារសាលាខ្មែរក្រហម – សាលាជំនុំជម្រះខ្មែរក្រហម ខ្ញុំបានមានព័ត៌មានច្រើន ដូចជា ឌុច វាបានឆ្លើយថា -- ពីព្រោះពួកខ្ញុំរកគ្រប់កន្លែង វាគ្មានឈ្មោះនៅទួលស្លែងហ្នឹង គឺគ្មានឈ្មោះ ចៅ សេង ទេ វាអត់មាន ហើយគ្មានទាំងរូបថតទៅទៀត។ ទើបតែ ឌុច បាននិយាយពីៗថ្ងៃ១៩ ខែសីហា ឆ្នាំ ១៩០៩ *(ស៊ីក)* បានខ្ញុំដឹងថា វាដូរឈ្មោះ បានខ្ញុំទៅរកឯកសារនៅខាង ឌី.កាំ ហើយបានគេជា ចិន សួន ហើយនៅក្នុងនោះមានសារភាពគាត់ទាំងអស់ មានទៅដល់២០០ទំព័រ។ ខ្ញុំបានសិក្សាមើលគឺថា ខ្មែរក្រហមបន្ទោសគាត់ពីរឿង គាត់ដូចថាគាត់មិនបានគិតគូរពីបដិវត្តន៍តាំងពីគាត់នៅរៀននៅម៉ុងពេយ៉េ តាំងពីគាត់នៅនិស្សិត។ តមកទៀត គាត់បានទៅសហការជាមួយព្រះបាទ សីហនុ – សម្តេច សីហនុ ដល់ជាង១០ឆ្នាំ ហើយមិនបានគិតគូរពីបដិវត្តន៍ ហើយចោទគាត់ៗថា ចោទគាត់ថាគាត់ជាអ្នកធ្វើការឱ្យអ្នកភ្នាក់ងារសម្ងាត់នៅខាងបារាំង ហើយនិងកាន់ខាង សេ.អ៊ី.អា ដែលគ្មានអ្វីជាភស្តុតាងទាំងអស់ គឺចោទទេ។ មិនដឹងខ្មែរក្រហមមានគំនុំគុំកួនយ៉ាងណា។ ហើយហេតុនេះបានខ្ញុំចង់ៗសួរទៅឱ្យព្រះរាជអាជ្ញាមានអនុញ្ញាត សួរទៅ នួន ជា និង ខៀវ សំផន។ តើ ចៅ សេង បានធ្វើអីខុសខ្លះបានយកគាត់យកទៅសម្លាប់ចោល?

**ស៖** បាទ សូមអរគុណលោកពូ។ ខ្ញុំសូមការបញ្ជាក់អំពីទំនាក់ទំនងរបស់បងប្រុសរបស់លោកពូ ចៅ សេង ជាមួយនឹងមេដឹកនាំខ្មែរក្រហម ហើយនិងសម្តេច សីហនុ ពីព្រោះមានក្រោយពីរដ្ឋប្រហារទៅថា តើគាត់តួនាទីរបស់គាត់រវាងគាត់ជាមួយនឹងមេដឹកនាំខ្មែរក្រហមនៅក្នុងសម័យនោះ ហើយនិងសម្តេចព្រះ សីហនុ តើលោកពូដឹងរឿងហ្នឹងដែរឬទេ?

[១៤:៣២:១៩]

**ឆ៖** ចំពោះរឿងនេះខ្ញុំដឹងច្បាស់ ពីព្រោះខ្ញុំតាមដានតាំងពីគាត់ចេញពីស្រុកខ្មែរទៅស្រុកបារាំងពីឆ្នាំ១៩៦៨ គាត់លែងធ្វើនយោបាយហើយ ទៅដល់នោះគាត់បានរៀនខាង ដុកទ័រវ៉ា អេសស្តែត ហ្នឹង តទៅទៀត នៅស៊ិកប៊ិន នៅប៉ារីស។ ពីព្រោះគាត់ចេញទៅហ្នឹងដោយសារពួកខាងស្តាំវាឈ្នះឆ្នោតវា

គាត់នៅអត់បាន វាត្រូវរក វារកសម្លាប់គាត់ដែរកាលនុ៎ុង។ បានជា សីហនុ គាត់ប្រាប់ថាឲ្យទៅនៅៗស្រុកបារាំងសិនទៅ។ ដល់ចាប់ពីបានរដ្ឋប្រហារ១៩៧០ សម្តេចបាន១ឲ្យ -- សម្តេច ប៉ែន នុត ហៅគាត់ពីម៉ុងពេយ៉េមកវិញ មកវិញមកជួយរៀបចំការតស៊ូជាមួយនឹង លន់ នល់។ ពេលនោះជ័យជម្នះខ្មែរក្រហមគឺថា គាត់បានចូល បានចូលរួមចំណែកច្រើនដែរ ពីព្រោះគាត់ជាអ្នកទៅតស៊ូ ទៅជាបេសកកម្មទៅប្រទេស ទៅអាមេរិកឡាទីន ទៅអាហ្វ្រិក ទៅគ្រប់តែស្រុក ដើម្បីឲ្យគេជួយគាំទ្រខាងការតស៊ូរបស់សម្តេច ហើយនិងការទទួលស្គាល់នៅសហប្រជាជាតិ។ ហេតុនេះគាត់បានចូលរួមចំណែកច្រើនក្នុងការជ័យជម្នះរបស់ខ្មែរក្រហម។ ប៉ុន្តែគ្មាននរណាយល់ទាំងអស់ ហេតុអ្វីបានខ្មែរក្រហមសម្លាប់អ្នកចេះដឹងទាំងអស់នេះ គឺថា ម្នាក់ៗនៅតែសួរដល់លើកហ្នឹង ហើយខាងខ្មែរក្រហមក៏មិនបានឆ្លើយឲ្យតបឲ្យបានច្បាស់លាស់។ តើហេតុអ្វីបានសម្លាប់ពួកអ្នកចេះ ហើយគ្នាគ្មានអ្វីសោះ មានតែចំណេះដឹង។

*(ដើមបណ្តឹងរដ្ឋប្បវេណីយំ)*

សូមអភ័យទោស។ យកមកសម្លាប់ គឺខ្មែរក្រហមពេលនោះគ្មានដឹងតម្លៃ តើដើម្បីធ្វើ រៀនសូត្រខាងអាំងស៊ីញញើរ ឬខាងអីហ្នឹង តើតម្លៃប៉ុន្មាន? គឺខ្មែរក្រហមអត់មានដឹងតម្លៃហ្នឹងសោះ យកមកសម្លាប់រាប់រយនាក់។ សូមអរគុណ។

[១៤:៣៤:០០]

**ស៖** បាទ សូមអរគុណលោកពូ។ តើខ្ញុំអាចតាំងសំណួរទៅកាន់លោកពូបន្ថែមទៀតបានទេ ឬក៏លោកពូត្រូវការសម្រាកសិន? បាទ អរគុណ។ តើលោកពូមានបានដឹងអំពីថាតើលោក ថៅ សេង គាត់មានគំនុំនឹងមេដឹកនាំខ្មែរក្រហមណាមួយ ឬក៏មានទំនាស់អ្វីមួយទៅនឹងការដឹកនាំរបស់គេនៅក្នុងរបបនោះដែរឬទេ?

**ឆ៖** ថៅ សេង គាត់បាន -- កាលគាត់នៅសង្គមរាស្ត្រនិយម គាត់បាន អង្គាល់គាត់កាន់ជាអគ្គលេខាធិការ។ គាត់បាន គាត់មិនដែលធ្វើអ្វីប្រឆាំងនឹងខ្មែរក្រហមទេ។ ក្នុងកាសែត គាត់ -- *ឡាឌូវ៉ែល ដេប៉េស* គឺគាត់សរសេរការពារ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ នៅពេលដែល កាលណាមានការចោទប្រកាន់គាត់ឥត -- វាគ្មាន *ប៉ុងដឺម៉ុង* គឺគ្មានមូលដ្ឋាន។ ហេតុនេះ ថៅ សេង ដូចជាគ្មាននឹងស្អប់ខ្មែរក្រហមទេ។ បើស្អប់ខ្មែរក្រហម ថៅ សេង អត់មកជួយតាំងពីឆ្នាំ១៩៧៥ ចោលកូន ចោលចៅ ចោលកូនចោលប្រពន្ធ មកជួយពួកខ្មែរក្រហម ជួយសម្តេចដើម្បីបានជ័យជម្នះ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥។ សូមអរគុណ។

**ស៖** បាទ សូមអរគុណលោកពូ។ ខ្ញុំសូមដកស្រង់នូវសំណេររបស់លោកពូមួយដែលសរសេរនៅក្នុងពាក្យបណ្ដឹងសរសេរថា "បងប្រុស ចៅ សេង គឺជាមនុស្សឆ្លាត ហើយពូកែ ព្រមទាំងមានសមត្ថភាព។ គាត់ជាអ្នកមានគំនិតជឿនលឿន ជាអ្នកស្នេហាជាតិ ហើយបានសម្រេចចូលបម្រើប្រទេសជាតិ។ គាត់ជាមនុស្សដែលស្រឡាញ់យុត្តិធម៌ មិនគួរណា បងប្រុសខ្ញុំមកសម្លាប់ទទេៗ ឥតប្រយោជន៍ ចោលប្រពន្ធកូន គ្រួសារ ចូលមកជួយ តែបែរត្រូវសម្លាប់ចោល។ មិនគួរណាគាត់ត្រូវបានស្លាប់ ព្រមទាំងបញ្ញវន្តទៀតស្លាប់យ៉ាងវេទនា។" ខ្ញុំដកស្រង់នូវចំណុចនេះ ខ្ញុំចង់សួរលោកពូថា តើលោកពូចង់បង្ហាញភាពឈឺចាប់របស់លោកពូយ៉ាងម៉េច បានលោកនិយាយថា មនុស្សល្អ មនុស្សស្រឡាញ់យុត្តិធម៌ មនុស្សស្រឡាញ់ប្រទេសជាតិ ត្រូវបានគេកាប់សម្លាប់?

[១៤:៣៨:១៦]

**ឆ៖** ខ្ញុំមានយោបល់ដូចតទៅ គឺថា ចៅ សេង ប្រហែលគេច្រណែន។ ពួកខ្មែរក្រហម គឺថាវាច្រណែនគាត់ តាំងពី គាត់មិនមែនជាកុម្មុយនីស្ត។ បើខ្លះ (ឮមិនច្បាស់) ពេញទេ គឺគាត់ជា*អ្នក ប្រូគ្រែស ស៊ីស* គឺអ្នកជឿនលឿន។ មិនមែនតែចំណែកខ្ញុំទេ អាឌុច ក៏វាដឹងដែរ កាលវានៅជាកូនសិស្សគាត់ ទៅនៅ គាត់នៅបង្រៀននៅគរុវិជ្ជា។ ហើយគាត់ជាអ្នក នៅកាលជំនាន់ហ្នឹង ក្នុងឆ្នាំ៦០ហ្នឹងទៅ ពី៦០ ទៅ ៦៨ហ្នឹង គឺគាត់ល្បី ឈ្មោះគាត់គឺថា អ៊ីចឹងបានសម្ដេចយកទៅធ្វើ យកទៅប្រើការ ពុំមែនសម្ដេចយកនេះ ចៅ សេង អី ចៅ សេង គ្មានៗប៉ាកទី គ្មានអីអ្នកណាស្អី អីត្រង់ណាទេ គឺថាគាត់ ដោយសារគាត់ជាពូកែ។ ក្នុងជំនាន់ ជំនាន់គាត់ហ្នឹង គឺមានតែគាត់មួយដែលពូកែជាងគេក្នុងជំនាន់ដែលមកពីស្រុកបារាំងជំនាន់នោះ។ កាលពីទៅរៀនពី៤០ មកដល់៥៧ ហ្នឹង គាត់មាន -- គាត់ខាងនយោបាយ គាត់ពូកែជាងគេ។ ហេតុនេះ បានគាត់ជាប់នៅធ្វើរដ្ឋមន្ត្រីរហូត១០ឆ្នាំ ហើយគាត់បានធ្វើច្រើន ជួយច្រើន។ ដូចអាឌុចវានិយាយអ៊ីចឹង ខាងសិក្សាធិការ ខាងស្អីនេះ គាត់បង្កើតសាលាដើម្បីបង្ហាត់បង្រៀន ប្រូហ្វេសស៊័រ ពួកនែ ពួកសាស្ត្រាចារ្យ ហើយគាត់ខាង -- កាលគាត់នៅកសិកម្ម គាត់បានធ្វើកិច្ចការច្រើន គាត់ធ្វើបានច្រើនណាស់។ គាត់រឿងពុករលួយ គាត់ការតស៊ូជាមួយសម្ដេច ព្រោះកាលពីមុនដំបូង សម្ដេច នៅជុំវិញសម្ដេចសុទ្ធតែពួកសក្តិភូមិ ពួក*ហ្វេលដូ*។ ដល់គាត់មក គាត់បានជម្រះខ្លះ ចូលខ្លះ ប៉ុន្តែពិបាកមិនមែនស្រួលប៉ុន្មាន គាត់តស៊ូដើម្បីៗសង្គមខ្មែរ មិនមែនជាដើម្បីជាគាត់ទេ អ៊ីចឹងបានគាត់ គេស្រឡាញ់គាត់ណាស់ជំនាន់ពីជំនាន់នោះ គឺគាត់មានឈ្មោះល្បី ព្រោះគាត់ជាអ្នកស្នេហាជាតិមួយ បញ្ញវន្តមួយដែលពិបាករកៗក្នុងជំនាន់គាត់ហ្នឹង ដែលដូចគាត់អត់មានៗ វាមានតែគាត់ជាអ្នក គាត់ជួយទាំងអស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជួយទាំង ពួកខ្មែរក្រហមក៏ជួយដែរ ជួយដូចកាលស្រុបក់ គាត់កាលធ្វើរដ្ឋមន្ត្រី គាត់ជួយ ខៀវ សំផន ឲ្យមកធ្វើខាង*កុំម៉ែក* ប៉ុន្តែពួកខាងស្ដាំវាមិនសប្បាយចិត្ត បាន ខៀវ សំផន គាត់នៅអត់បានដែរ។ ហេតុនេះគាត់មិនមែនជាអ្នកអី ចង់បានលោភលន់ប៉ុន្មានទេ ព្រោះគាត់ជា មកពីកម្ពុជាក្រោមមក ខ្ញុំជាគ្រួសារអ្នកស្រែមិនមែនគ្រួសារអ្នកមានអីណាទេ ប៉ុនគាត់អ្នកមកបណ្ដុះបណ្ដាល ទាំងខ្ញុំ អ៊ីចឹងបានដឹងគុណគាត់ហ្នឹង ដើម្បីសងគុណគាត់ ដើម្បីរកយុត្តិធម៌ហ្នឹងដើម្បីសងគុណគាត់ ព្រោះគាត់ បើខ្ញុំគ្មានគាត់ ខ្ញុំទៅធ្វើស្រែហ្នឹង នៅធ្វើស្រែឯណោះនៅស្រុកយួនហ្នឹង នៅកម្ពុជាក្រោម ប៉ុន្តែខ្ញុំបាន គាត់បានឲ្យខំរៀនបន្តទៅឲ្យរៀនដល់ស្រុកបារាំង ហើយប្អូនមួយទៀតក៏ឲ្យបានទៅបន្ត ឲ្យទៅៗរៀននៅស្រុកបារាំងដែរ។ សូមអរគុណ។

[១៤:៤១:២៩]

**ស៖** បាទ ខ្ញុំសូមសួរសំណួរមួយចុងក្រោយ ហើយបើសេសសល់ សូមទុកឲ្យដៃគូខ្ញុំគាត់បន្ថែមលោកពូ។ គឺថា តើលោកពូចង់ឲ្យមេដឹកនាំខ្មែរក្រហមដែលជាជនត្រូវចោទទាំងអស់ ដែលមាននៅក្នុងសំណុំរឿងនេះទទួលខុសត្រូវយ៉ាងដូចម្ដេចចំពោះការទុក្ខសោកឈឺចាប់វេទនាខាងផ្លូវចិត្តរបស់លោកពូ?

**ឆ៖** ចំពោះខ្ញុំៗថានែ! ខ្មែរក្រហមវា ខ្មែរក្រហមបានវាស្លាប់អស់ដូច អៀង សារី ក៏អស់ទៅស្លាប់ទៅៗប៉ុន្មានហ្នឹងគឺនៅតែពីរនាក់ រួចគាត់មិនព្រមឆ្លើយទៀតហ្នឹងគឺពិបាកហ្នឹង ប៉ុន្តែគាត់ទទួលខុសត្រូវទាំងអស់ អ្វីដែលទទួលខុសត្រូវគឺនៅក្នុងសង្គមខ្មែរហ្នឹង គឺនគរខ្មែរមួយចេះតែលាយនៅរបប ប៉ុល ពត ជិតរលាយ។ ដល់ទី២ គឺថាសង្គមខ្មែរវាបែកបាក់ ទោះអ្នកក្រទៅមាន អ្នកមានទៅក្រ ឃ្លោកលិចអម្បែងអណ្ដែតហ្នឹងបាទ ហើយនិងមួយទៀត គាត់ខ្មែរក្រហមបានទទួលខុសត្រូវចំពោះច្រើនណាស់ទាំងក្នុងកាលក្នុងរបប ប៉ុល ពត ប៉ុន្មានឆ្នាំ ៣ឆ្នាំប៉ុន្មានខែហ្នឹងបាទ។ ហេតុនេះត្រូវឲ្យលោក នួន ជា ហ្នឹងមកសារភាព និងលោក ខៀវ សំផន តើហេតុអ្វីបានជាកាប់សម្លាប់ពួកបញ្ញវន្តដែលគ្នាគ្មានអីតស៊ូគ្មានអីទាំងអស់ មកយកទៅសម្លាប់នៅក្នុងបឹងត្របែកហ្នឹង គឺថាដោយចោទតែផ្ដេសផ្ដាសថានេះ ថាអ៊ីចុះ ប៉ុន្តែគ្នាគ្មានអីអ្វីជានេះទេ បាទជាដុំកំភួន។ ហេតុនេះអ្នកពីរនាក់ហ្នឹងនៅសល់ហ្នឹងគឺត្រូវទទួលខុសត្រូវទាំងអស់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកអស់ពេលហើយ។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាប់ឱកាសសម្រាក១៥នាទីចាប់ពីពេលនេះតទៅ។ សូមអញ្ជើញ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមជូនវេទិកានេះទៅឲ្យលោកព្រះរាជអាជ្ញា ដើម្បីសួរដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ ជម្រាបសួរលោកប្រធាន។ បាទ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឈ្មោះខ្ញុំ ឈ្មោះ វាំងសង់ ដឺវីល។ ខ្ញុំនឹងចោទសំណួរលោកចំនួន១៥ ទៅ២០ នាទី។

**ស៖** ជួសមុខឲ្យតំណាងឲ្យព្រះរាជអាជ្ញា ខ្ញុំមិនសូវមានសំណួរច្រើនទេ ពីព្រោះថាសំណួរដែល ខ្ញុំសួរលោកនេះគឺទាក់ទងទៅនឹងកន្លែងដែលបងប្រុសរបស់លោកត្រូវបានសម្លាប់ ពីព្រោះថានៅក្នុង ចម្លើយរបស់លោកហ្នឹង លោកនិយាយថា គេសម្លាប់គាត់នៅចំការលើ តែឥឡូវនេះលោកបានបញ្ជាក់ថា នៅមន្ទីរស-២១ទេ។ អ៊ីចឹងទាក់ទងនឹងចំណុចមួយ ទាក់ទងនឹងកន្លែងនេះ នៅសម័យកម្ពុជាប្រជាធិប-តេយ្យហ្នឹង ខ្ញុំចង់សួរលោកថា លោកនៅឯណាដែរ ចន្លោះឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩ នេះ ពីព្រោះខ្ញុំ រកអត់ឃើញព័ត៌មានណាទាក់ទងនឹងកន្លែងដែលរស់នៅទេ?

**លោក ចៅ ឃឹម៖**

**ឆ៖** ខ្ញុំបានចេញពីកម្ពុជា ពីព្រោះខ្ញុំបានប្លូកបារាំងមួយ។ ខ្ញុំបានប្លូកអាហារូបករណ៍បារាំងមួយ ទៅរៀនបន្ត ពីព្រោះខ្ញុំបានជាបណ្ឌិតខាងបសុពេទ្យហើយ *ឌុកទ័រវិតេរ៉ែរ* ហើយគេឲ្យទៅរៀនខាង *ប្រូហ្វេសស៊័រ* ខាងគ្រូបង្រៀន។ និងបានចេញពីបារាំង -- ពីស្រុកខ្មែរពី៧៤ ទៅដល់៧០ ខ្ញុំទើបចូលមក ប្រហែលទើបខ្ញុំរ៉ីត្រែត ខ្ញុំធ្វើការស្រុកបារាំងជិត៣០ឆ្នាំ នៅក្រសួងពេទ្យសត្វនៅស្រុកបារាំង។ រួចខ្ញុំ ពេលនោះខ្ញុំអត់នៅនេះ ប៉ុនខ្ញុំបានតាមដានជានិច្ចក្នុងរឿងហ្នឹង ពីព្រោះ ចៅ សេង ជាអ្វីរបស់ខ្ញុំ គឺវាជា សំខាន់ណាស់បាទ។

[១៥:០២:៥០]

**ស៖** បាទ លោកនិយាយថា ចាប់ពីឆ្នាំ១៩៧០ ទៅបងប្រុសរបស់លោកធ្វើដំណើរច្រើន គឺថា

គាត់ទៅរុស្ស៊ី ទៅអឺរ៉ុប ទៅអាហ្វ្រិក។ តើគាត់ខកចិត្តដែរឬទេ ដែលគាត់មិនបានត្រឡប់មកប្រទេសកម្ពុជាផ្ទាល់មុនខែធ្នូ ឆ្នាំ១៩៧៥? ពីព្រោះថាកាលនោះគាត់នៅភាគច្រើន គាត់នៅប្រទេសចិន។ តើគាត់មានបាននិយាយអំពីអារម្មណ៍របស់គាត់ ទាក់ទងទៅនឹងការដែលគាត់មិនបានត្រឡប់ចូលមកប្រទេសកម្ពុជាបានឆាប់ដែរឬទេ?

**ឆ៖** ចៅ សេង គាត់មិនអាចមកស្រុកខ្មែរមុនសម្ដេច សីហនុ ព្រោះទៅ សម្ដេច សីហនុ មុនមកចូលមុន បានគាត់មកតាមក្រោយ។ គាត់មិនៗយូរប៉ុន្មានដែរ ថ្ងៃ១៥ ខែ១២ ឆ្នាំ៧៥ គាត់បានមកដល់ស្រុកខ្មែរ។

**ស៖** បាទ បងប្រុសរបស់លោកធ្លាប់ជារដ្ឋមន្ត្រីនៅក្រោមរបបសម្ដេច សីហនុ គាត់ជាកម្មា -- ជាសមាជិក<ការិយាល័យនយោបាយ>នៃហ្វុងរណសិរ្សរួបរួមជាតិនៅបារីស ហើយគាត់ជាបេសកជនពិសេស<របស់សម្ដេច សីហនុ>មុន ១៧ មេសា ឆ្នាំ១៩៧៥។ អ៊ីចឹងខ្ញុំសួរលោកថា មានមូលហេតុអ្វីដែលជាជំរុញឲ្យគាត់ត្រឡប់ចូលប្រទេសកម្ពុជាវិញ? តើកាលនោះគាត់មិនមានភាពមន្ទិលសង្ស័យអំពីការយល់ឃើញ កាលដែលគាត់នៅពេលប៉េកាំង គាត់នៅអមសម្ដេច សីហនុ ហើយនិងទស្សនៈយល់ឃើញរបស់ខ្មែរក្រហម ដែលមេដឹកនាំខ្មែរក្រហមដែលនៅប្រទេសកម្ពុជា? តើគាត់អត់មានមើលឃើញថា មានទស្សនៈខុសគ្នារវាងភាគីទាំងពីរនេះ ដែលៗជាធាតុផ្សំនៃរណសិរ្សរួបរួមជាតិកម្ពុជាទេឬ? ហើយមូលហេតុអ្វីដែលជំរុញឲ្យគាត់ត្រឡប់ចូលមកស្រុកខ្មែរ?

[១៥:០៥:១៥]

**ឆ៖** មូលហេតុដែល -- គឺការស្រឡាញ់ជាតិ ព្រោះគាត់ដែលបានចូលរួម តាំង មិនៗគាត់ទើបនឹងចូល ពីម្សិលមិញ ពី៧៥មកចូលទេ គឺគាត់បានតស៊ូតាំងពី៧០ ជាមួយសម្ដេច សីហនុ នៅតស៊ូជាមួយសម្ដេច សីហនុ តាំងពី៧០មក ហើយគាត់ក៏បានចូលមក ប៉ុន្តែគ្មានអ្នកណាយល់ តែសម្ដេចសីហនុ ក៏ច្រឡំដែរ។ គ្មានអ្នកណានឹកដល់ថា ខ្មែរក្រហមវាៗ វាមានគ្រប់គ្រងការតែរបៀបហ្នឹង គឺគ្មានអ្នកណាតែម្ដង។ គាត់ថា គាត់មក គាត់លាប្រពន្ធគាត់។ កាលលើកមុនៗ -- មុនៗគាត់ចេញមក គាត់ចូលញុំាបាយជាមួយគ្នាទាំងអស់។ គាត់ហៅបងប្អូននៅស្រុកបារាំងប៉ុន្មាន មកញុំាបាយជាមួយគ្នា។ រួចទៅ បានគាត់ប្រាប់ថា គាត់មិនៗនេះទេ គឺថាអត់មានចង់បានអំណាចអីពីខ្មែរក្រហមនោះទេ គឺគាត់ចង់មកដើម្បីជួយជាតិ ព្រោះវា ការដែលគាត់ៗៗពូកែខាងរឿង ខាង*ឌីប្លូម៉ាស៊ី* – ខាងទូត។ បាទ ហេតុនេះបានគាត់ៗសុខចិត្តលះបង់ចូលមកចោលប្រពន្ធ ចោលកូន ព្រោះគាត់ប្រពន្ធបារាំង ចោលប្រពន្ធ ចោល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កូន *(ឮមិនច្បាស់)* គាត់ត្រឡប់មករក មកជួយជាតិ។ ហេតុនេះ ហើយជា។*អនណ៍*របស់គាត់ ជាកិត្តិយសរបស់គាត់ ដែលគាត់ចូលមកហ្នឹង ដើម្បី គឺថាគាត់មិន។ខ្លាច។ គាត់ថា គាត់ទៅគ្មានចង់បានអីតែបើគ្មានខុសអីហើយហ្នឹង មកមិន។នេះទេ។ បាទ ហេតុនេះបានគាត់សុខចិត្តចូលមក ព្រោះសម្តេចមកគាត់តស៊ូ មិនមែនគាត់មិនតស៊ូ។ បើតស៊ូហើយ មិនត្រូវយាង មិនហ៊ានចូល មិនស្មានថា ខ្មែរក្រហមដល់សាហាវដល់ម្លឹង។

[១៥:០៦:៥៩]

**ស៖** បាទ ខ្ញុំសុំអានអត្ថបទមួយ អត្ថបទកាសែតមួយរបស់ អា.អេហ្វ.ប៉េ គឺជាសម្រង់របស់ឯកសារ E3/118 គឺជាឯកសារ អេហ្វប៊ីស មានចំណងជើងថា "ចៅ សេង៖ <មិនមានការបង្ហូរឈាមនៅភ្នំពេញទេ>"។ បាទ មិនមានការបកប្រែជាខ្មែរទេ អំមិញជាភាសាអង់គ្លេស។ ព្រោះថា យើងមើលនៅខែមេសានោះ ដល់ពេលជិតបានជោគជ័យហើយហ្នឹង គឺ ចៅ សេង គាត់ជឿជាក់លើចលនាខ្មែរក្រហម ហើយគាត់និយាយដូចតទៅនេះ លោក ចៅ សេង គាត់និយាយដូចតទៅនេះ ថ្ងៃទី១២ មេសា នៅទីក្រុងប៉ារីស ដកស្រង់ជាភាសាអង់គ្លេស៖ "បេសកជនពិសេស ចៅ សេង របស់សម្តេចសីហនុ គឺគាត់<និយាយនៅទីនេះ នៅថ្ងៃនេះ>ថា <មិន>មានការបង្ហូរឈាម<ទេ> បើសិនខ្មែរក្រហមចាប់យកទីក្រុងភ្នំពេញ<បាន>។ យើងគួរតែ យើងត្រូវតែដាក់ទណ្ឌកម្មទៅលើពួកក្បត់ ដូច<>ពួកណាហ្ស៊ី <ដែល>សម្ព័ន្ធមិត្ត<បានធ្វើអ៊ីចឹង។ ប៉ុន្តែយើង>អនុវត្ត<នយោបាយមួយ>ទៅលើសហភាពរួបរួមជាតិ។ <អ្នកផ្សេងៗទៀតអាចចូលរួមបាន ហើយពួកគេនឹងក្លាយជាពលរដ្ឋដូចមនុស្សគ្រប់គ្នាដែរ។ ពលរដ្ឋខ្មែរទាំងអស់មានកន្លែងរបស់ពួកគេនៅក្នុងសហគមន៍ជាតិ។" ហើយបន្តមកក្រោមទៀត គាត់បន្ថែមថា៖> "ប្រទេសកម្ពុជា ប្រជាជនកម្ពុជា គឺជាប្រជាជនដ៏អស្ចារ្យ ពួកគេមិនភ្លេចអ្នកដែល អ្នកជួយពួកគេនោះទេ ក៏ប៉ុន្តែពួកគេក៏មិនភ្លេចនូវភាពដែលអន្តរាយដែលបានកើតឡើងចំពោះពួកគេតាំងពីដំបូង។ ហើយក៏មិនភ្លេចចំពោះអ្នកដែលបានធ្វើការបង្កនូវព្យសនកម្មទៅលើពួកគេផងដែរ។"

តើនៅខែមេសា ឆ្នាំ១៩៧៥នោះ តើលោកមាន -- លោកគិតឃើញថា គេបោកគាត់ដែរឬទេ ក្នុងខណៈដែលគាត់និយាយ ទៅធ្វើសន្និសីទដែលនិយាយអំពី<កំពូល>ជនក្បត់<>នេះ ដែល<គេបានកាត់ទោសប្រហារជីវិត ឬក៏អំពីអង្គហេតុដែលគេមិនភ្លេច>សម្ព័ន្ធមិត្តរបស់គេ <និង>អ្នកណាមិនមែនជាសម្ព័ន្ធមិត្តរបស់គេនោះ តើលោកមានដឹងថា គាត់ហ្នឹងមានអារម្មណ៍ថាគេក្បត់គាត់ទេ?

[១៥:០៩:៥៩]

**ឆ៖** បើតាមយោបល់ខ្ញុំ គឺថាគាត់អត់បានដឹងទេ រឿងបើគាត់ដឹងថាគេក្បត់គាត់ គាត់អត់មានអត់ចាត់មកទេបាទ គាត់ចាំបន្តិចទៀត គាត់បានមក ប៉ុន្តែថាគាត់វាគ្មានអាន៉ុងតែម្តង គឺថាមក វាស្មោះត្រង់ ដើម្បីមកហ្នឹង មកដើម្បីជួយ គេត្រូវការអ្នកចេះ អ្នកដឹង ដើម្បីជួយ ពួកនៅក្នុងជួរខ្មែរក្រហម អ្នកចេះដឹងតិចណាស់ គឺបានពីស្រុកបារាំងមកហ្នឹង គឺរាប់រយនាក់ដែលមកហ្នឹងគឺមកជួយ ប៉ុន្តែខ្មែរក្រហមមិនដឹងអាម៉េច មិនទុកចិត្តពួកអាពួកស្រុកបារាំង ទៅៗយកពួកអ្នកស្រុកបារាំងជាអ្នកក្បត់ទៅវិញ។ ខ្ញុំអាហ្នឹងខ្ញុំមិនយល់ អាហ្នឹងចង់សួរទៅលោក នួន ជា ហើយនិងលោក ខៀវ សំផន។

**ស៖** បាទ មុននឹងចូលមកនិយាយអំពីចម្លើយសារភាពរបស់គាត់ ដែលបន្តិចទៀត ខ្ញុំនឹងសួរលោកហ្នឹង។ តើខ្ញុំសួរលោកថា ហេតុអ្វីបានជាគេដកបងប្រុសរបស់លោកចេញពីបឹងត្របែកបញ្ជូនទៅមន្ទីរស-២១? <ខ្ញុំគិតថា> លោកបាននិយាយជាមួយអ្នកដែលស្គាល់បងប្រុសរបស់លោក ដូចនិយាយជាមួយ អៀង សារី ជាដើមអីចឹងហ្នឹង តើតាមរយៈការនិយាយគ្នាហ្នឹង តើលោកមានទទួលបានព័ត៌មានណាដែលអាចឲ្យលោកដឹងពីមូលហេតុនៃការដកគាត់ពីបឹងត្របែកទៅមន្ទីរស-២១ ហ្នឹងដែរឬទេ?

[១៥:១១:៣៥]

**ឆ៖** កាលដកគាត់ពីបឹងត្របែក គឺថាខ្ញុំបានជួបនឹងលោក អៀង គុណសាគី មិនមែន អៀង សារី, អៀង គុណសាគី។ គាត់ជា គាត់ធ្លាប់រស់នៅជាមួយគាត់នៅក្នុងបឹង នៅៗបឹងត្របែក។ គាត់បានថាថ្ងៃមួយ គេយកអាឡានហ្ស៊ីបមកដឹកគាត់ ហៅគាត់ពីកំពុងបេះត្រកួនឲ្យយកអីវ៉ាន់ គេមក អង្គការហៅទៅលើ។ ហើយពួកនៅបឹកត្របែកហ្នឹង ក៏អត់ហ៊ានអ្នកណាសួរថាទៅណាទេ ស្មានថាទៅពីហ្នឹងទៅ ធ្វើការនៅៗជាមួយ អៀង សារី នៅក្រសួងការបរទេស។ ហេតុនេះ គាត់អត់ដឹង អត់មាននេះទេអត់មានដឹងទេបាទ។ រួចបើតាម ឌុចៗ ក៏វាមិនដឹងច្បាស់ដែរ ថ្ងៃមុនវាឆ្លើយមកថា វាមិនដឹង ថៅ សេងនៅកន្លែងណាច្បាស់ទេ ប៉ុន្តែមែនទែន ថៅ សេង នៅបឹងត្របែក។ អីចឹងវានាំពីបឹងត្របែកមកៗស-២១តែម្តង។ ឌុចៗ វាថាមិនដឹងច្បាស់ បើស្មានថានៅណាស្អីណា បើខ្ញុំស្តាប់សវនាការមុន លើកមុន។

**ស៖** ទាក់ទងនឹងមូលហេតុនៃការចាប់ខ្លួននេះ ខ្ញុំសូមអានអ្វីដែល អៀង សារី បានឆ្លើយទៅ ស្ទីវហេដឌ័រ គឺឯកសារ E3/89។ ខ្ញុំមើលទៅឃើញថា ខ្ញុំអត់មានលេខ ERN ទេ ខ្ញុំនឹងផ្តល់លេខ ERN នៅពេលក្រោយជូនទៅអង្គជំនុំជម្រះ។ ខ្ញុំសូមអភ័យទោស។ អៀង សារី គាត់និយាយដូចតទៅនេះ នៅពេលដែលគាត់និយាយអំពីអ្នកដែលចូលទៅក្នុង សេ.អ៊ី.អា ហើយនិងជាប់ពាក់ព័ន្ធនឹងវៀតណាម។

[១៥:១៣:២៥]

"ចំពោះអ្នកខ្លះហ្នឹង ខ្ញុំគិតថាពួកគេគាត់ហ្នឹងមិនចូលជាប់ខ្សែសេ.អ៊ី.អា ឬក៏វៀតណាមនោះទេ តែគេប្រឌិតទេ។ ដូច ថៅ សេង អ៊ីចឹង ដូចខ្ញុំនិយាយតាំងពីដើមអ៊ីចឹង ខ្ញុំប្រាប់ថាកុំឲ្យសម្លាប់គាត់អី គាត់មិនមែនជាគិញអីទេ ក៏ប៉ុន្តែគាត់ហ្នឹង<ដូចជាអត់វិន័យបន្តិច ដោយសារគាត់>ចូលចិត្តនិយាយច្រើន។ គាត់មិនសូវខ្វាយខ្វល់ <គាត់និយាយអ្វីៗទាំងអស់ដោយមិនប្រុងប្រយ័ត្នទេ>។ <គាត់ជា>បញ្ញាជនដែលត្រឡប់មកពីបរទេស<វិញតាំងពីដំបូង> ហើយគាត់ហ្នឹងមិនជាភ្នាក់ងារសម្ងាត់របស់បារាំង ឬក៏សេ.អ៊ី.អា អីទេ។ អ៊ីចឹងគ្រាន់តែគាត់ហ្នឹង គ្រាន់តែជាមនុស្សមិនមានវិន័យតែប៉ុណ្ណឹងឯង។ <គាត់ធ្វើអ៊ីចឹង>តាំងពីសម័យសង្គមរាស្ត្រនិយម<ម្ល៉េះ។ ប៉ុន្តែនៅពេលគាត់>ត្រឡប់មកចូលស្រុកវិញហ្នឹង ខ្ញុំចង់ជួយគាត់<ដែរ> ហើយគាត់បានឆ្លើយថា និយាយត្រឹមតែថា សូមដកស្រង់៖ បើសិនជាឲ្យខ្ញុំជីកដីអីនោះ ខ្ញុំនឹងទៅយកអាត្រាក់ពីបារាំងមក ហើយគាត់ថាប្អូនដប់នាទីមកអីហ្នឹង ធ្វើហើយបាត់ហើយ មិនចាំបាច់ទៅជីកដីនឹងដៃអីវេទនាអ៊ីចឹងទេ។ អ៊ីចឹងគេចោទគាត់ថា គាត់ប្រឆាំងនឹងបដិវត្តន៍ ហើយគេចោទគាត់ថា ថាគាត់ជាភ្នាក់ងារសម្ងាត់របស់បារាំងអ៊ីចឹងហ្នឹង ខ្ញុំគ្មានជឿអីម៉ាបន្តិចណាទេ។" តើបងប្រុសរបស់លោកហ្នឹង មានធ្លាប់និយាយជាមួយលោកអំពីទស្សនៈរបស់គាត់ទាក់ទងនយោបាយនៃពួកអ្នកដឹកនាំខ្មែរក្រហមទេ?

[១៥:១៤:៥៨]

**ឆ៖** បើតាមនេះ គឺថា គាត់ -- បើតាមយោបល់ខ្ញុំដែលខ្ញុំដែលបានរស់នៅជាមួយគាត់តាំងពី៦៦ ដែលខ្ញុំត្រឡប់មកពីស្រុកបារាំងវិញ គឺថាគាត់គ្មានជារបស់អ្នកណាទេ ព្រោះគាត់មិនមែនជាភ្នាក់ងារបារាំង ឬភ្នាក់ងារអី ប៉ុន្តែខ្មែរក្រហមចោទថាគាត់ធ្វើការប៉ុន្មានជាមួយសម្តេចហ្នឹងគឺថា ដើម្បីប្រយោជន៍បារាំង មិនមែនជាប្រយោជន៍ខ្មែរទេ។ ប៉ុន្តែគាត់វាគ្មាននឹកឃើញអាអ៊ីចឹងនេះសោះ ពេលនុ៎ងគឺបារាំងនៅធ្វើជាមួយគ្នា សហការជាមួយគ្នា វាគ្មានថាធ្វើការហ្នឹងវាអីដោយខូចប្រយោជន៍ដល់ស្រុកខ្មែរ វាគ្មានទេ ហ្នឹងគាត់ធ្វើការរាល់ថ្ងៃ ដែលគាត់ធ្វើជាកុងសី គឺជារដ្ឋមន្ត្រី គឺជាជាប្រធានកាប៊ីនេសម្តេច ក៏គ្មានដែលគាត់មិនដែលយករឿងស្អីដែល គ្មានរឿងស្អីដែលធ្វើជាសម្ងាត់ ជាសេ.អ៊ី.អាហ្នឹងគឺឆ្ងាយណាស់ គឺថានេះគឺជាការចោទតែផ្តេសតែផ្តាស ដើម្បីឲ្យយកគាត់យកទៅសម្លាប់មិនដឹង។ បាទៗ សូមអរគុណ។

**ស៖** សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារមួយទៅលោកដើមបណ្តឹងរដ្ឋប្បវេណីផ្នែកមួយចំនួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៃចម្លើយសារភាពរបស់ ចិន សួន ហៅ សាន នៅមន្ទីរស-២១ គឺឯកសារ E3/10609។ បាទ ខ្ញុំសូមផ្ដល់ឯកសារនេះទៅគាត់ ដើម្បីឲ្យគាត់ជួយកំណត់អត្តសញ្ញាណឯកសារលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយកឯកសារនេះ យកជូនដើមបណ្ដឹងរដ្ឋប្បវេណី។

*(មន្ត្រីតុលាការយកឯកសារដើមបណ្ដឹងរដ្ឋប្បវេណី)*

[១៥:១៧:០២]

**សួរដោយលោក វាំងសង់ វ៉ាយជ៍ ដេស្នាងឈ៖**

**ស៖** បាទ គឺទំព័រទី១ នៃចម្លើយសារភាពហ្នឹង គឺទំព័រ១ ដល់ ៣៩ ហើយទំព័រទី១ មានលេខ 00246843 ដែលមានសរសេរថា "ចិន សួន នេះហៅ សាន អាយុ៥០ឆ្នាំចូល ត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី១៩ ធ្នូ ៧៥ ហើយគាត់ត្រូវបានចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ១៩៧៧"។ អ៊ីចឹងលោកអាចបើកឯកសារហ្នឹងមើលទេ ហើយលោកស្គាល់ មានស្គាល់អក្សរអីទេ? តើអក្សរហ្នឹងអាចជាអក្សរបងប្រុសលោក ឬក៏យ៉ាងម៉េច?

**លោក ចៅ ឃឹម៖**

**ឆ៖** ឯកសារទាំងអស់នេះ ខ្ញុំបានយកពី ឌី.កាំ ខ្ញុំបានយកមកពិភាក្សា គឺឯកសារនេះគឺពិតជារបស់គាត់មែន គឺគ្មាន មិនអាចឆ្លើយបាន ព្រោះអក្សរនេះគាត់ ខ្ញុំស្គាល់ច្បាស់ អក្សរគាត់ហ្នឹងប្រហែលនឹងអក្សររបស់ខ្ញុំ។ ហេតុនេះ គឺថា អានេះគាត់បានៗសរសេរខ្លួនគាត់ទាំងអស់ទៅនេះហ្នឹង គឺវាឲ្យសរ-សេរទាំងអស់ ខ្ញុំយកមកវា ២០០ទំព័រ។ បាន ហើយវាឲ្យចោទគាត់ ខ្ញុំមើលដែរ ប៉ុន្តែថាឃើញវាចោទគាត់ហ្នឹងវាគ្មានៗន័យគ្មានអីទាំងអស់ គាត់ចង់ដកថយចេញពីយើងដែរ ប៉ុន្តែគ្រាន់ថា ការធ្វើបដិវត្តន៍គឺថាត្រូវទៅមុខ មិនឲ្យថយក្រោយ ព្រោះគាត់ដឹងដែរ គាត់ថាគាត់មកហ្នឹងវានេះ គាត់ចង់ថយក្រោយវិញប៉ុន្តែថានេះជាមួយ។ ហើយលោកមានប្រសាសន៍ថា គាត់និយាយហ្នឹងគាត់និយាយច្រើនបន្តិច ដូចពីរឿងត្រាក់ទ័រ ហើយប៉ុន្តែខ្មែរក្រហមឆាប់ចាប់ណាស់ *(ឮមិនច្បាស់)* ហ្នឹងគាត់ថា "ហ៊ឺ ! បើញ៉ាំបាយរួចបានកាហ្វេមួយកែវ" វាចោទថាគាត់ហ្នឹងជា*រ៉េអាក់ស្យុនែរ* ជាអ្នកប្រឆាំងនឹងបដិវត្តន៍ហើយ។ អ៊ីចឹងហេតុនេះ បន្តិចបន្តួច អាកំប៉ិកកំប៉ុកហ្នឹង វាចូលចិត្តយកមកធ្វើជាបានការ។ ខ្ញុំថាអាហ្នឹងជានេះមួយដែរ។ បាទ សូមអរគុណ។

[១៥:១៩:១២]

**សៈ** បាទ លោកនិយាយត្រូវហើយដែលលោកនិយាយថា ឌុច បាននិយាយពីបងប្រុសរបស់លោក ចៅ សេង ហ្នឹង ដែលនៅថ្ងៃទី០២ ខែ៤ ឆ្នាំ២០១២ នៅចំពោះមុខអង្គជំនុំជម្រះនេះ គឺឯកសារ E1/57.1 នៅម៉ោង ១១:៣៦:៤៩វិនាទី គាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "មុននឹងពេលគេចាប់មនុស្សណាម្នាក់នៅក្រសួងការបរទេសនេះត្រូវតែឲ្យ អៀង សារី អនុញ្ញាតសិន។ មានករណីលើកលែងតែមួយទេ គឺការចាប់ខ្លួន ចៅ សេង តែចាប់គាត់នេះដោយក្លែងឈ្មោះ ដោយមិនឲ្យ <អៀង សារី> ដឹង<ទេ>"។ ម៉ោង ១១:៤៤:២៧ វិនាទី គាត់និយាយដូចតទៅនេះ ឌុច និយាយដូចតទៅនេះថា "គេចោទ ចៅ សេង នៅក្នុង<>ចម្លើយសារភាព។ <នៅខែសីហា ឆ្នាំ១៩៧៧> សុន សេន និយាយថា <>ត្រូវបញ្ជូន ចៅ សេង ទៅមន្ទីរស-២១។ <អ៊ីចឹង>ហើយ ចៅ សេង <ត្រូវបាន>គេសួរចម្លើយនៅទីនោះ។ ហើយ<បន្ទាប់មក>ថ្នាក់លើគេសម្រេចកម្ទេចគាត់ ហើយបុគ្គលរូបនោះគឺ នួន ជា។" សូមបញ្ចប់ការដកស្រង់។

នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយឯកសារ E3/60 កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះដដែលនេះ គាត់និយាយនៅទំព័រជាភាសាបារាំងគឺ 00195614 ទៅដល់ 15, ជាភាសាអង់គ្លេសគឺ 00195604 ទៅដល់ 05 ខ្ញុំគួរតែផ្ដល់ ខ្ញុំនឹងផ្ដល់លេខ ERN ជាភាសាខ្មែរនៅពេលក្រោយ។ គាត់និយាយថា "សុន សេន បានទូរស័ព្ទមកប្រាប់ខ្ញុំប្រាប់ថា គេនឹងចាប់ ចៅ សេង ឆាប់ៗ ហៅ សាន <គាត់>ហ្នឹងដែលជាអ្នកបង្កើតសាលាគរុកោសល្យ ដើម្បីបណ្ដុះបណ្ដាលសាស្ត្រាចារ្យ។ ហើយសូមឲ្យខ្ញុំរក្សាការសម្ងាត់នេះ ហើយនិងឲ្យចុះឈ្មោះអ្នកទោសហ្នឹងដាក់ដូរទៅជាឈ្មោះ ចិន សួន វិញ។ នេះកើតឡើងនៅខែសីហា ឆ្នាំ១៩៧៧ ហើយបីថ្ងៃក្រោយមកទៀត ខ្ញុំបានមកជួបធ្វើការជាមួយ នួន ជា ដោយគាត់បាននិយាយប្រាប់ខ្ញុំថានេះជាការសម្ងាត់ ហើយថាទោះបីជាក្រសួងការបរទេសមកសូមព័ត៌មានក៏ត្រូវឆ្លើយប្រាប់គាត់ថា បងវ៉ាន់ ឯងទៅសួរ បងលេខ២ទៅ។" <ដូច្នេះតើ>ចម្លើយរបស់ ឌុច <>លោក<មានបាន>ទទួល<ព័ត៌មានបញ្ជាក់បែប>នេះ <>ពីអ្នកជិតស្និទ្ធ ឬក៏អ្នកនៅជិតស្និទ្ធជាមួយបងប្រុសលោក<ទេ ឬក៏មានតែ>ចម្លើយ ឌុច <និងចម្លើយសារភាពរបស់បងប្រុសលោក>នេះ<ទេ ដែលអាចឲ្យ>លោក<យល់ថាបងប្រុសរបស់លោកត្រូវបាន>គេ<ឃុំខ្លួននៅ>មន្ទីរស-២១<ដោយដាក់ឈ្មោះថា ចិន សួន នោះ>?

[១៥:២២:៣៤]

**ឆៈ** រឿងនេះគឺខ្ញុំបានពី ឌុច ទាំងអស់។ ព្រោះបក្សពួកខាងនៅក្នុង នៅជាមួយគាត់បឹងត្របែកហ្នឹង គ្នាប៉ុន្មានពួកទូតប៉ុន្មានហ្នឹងខ្ញុំសួរ សាកសួរទៅគឺថា អត់មាននិយាយពីរឿងៗ ចៅ សេង ទេ អត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានទេ។ ប៉ុន្តែខ្ញុំយកចម្លើយរបស់ ឌុច បានខ្ញុំបានរកឯកសារឃើញ រកឯកសារហ្នឹងឃើញបានខ្ញុំ -- ដើម្បី -- អ្នករកខាងដេអិន -- ឌី.កាំ បាទៗ។ ហេតុនេះជាមួយពួកអ្នកចាប់ប៉ុន្មានគឺថា កាលណាចាប់គ្មាននរណាហ៊ានសួរថាទៅណា មកណា គឺថាគេស្មានតែយកទៅនៃ -- ទៅៗធ្វើការជាមួយ អៀង សារី។ ដូចចាប់ វ៉ាន់ ពីនី ក៏ដូចគ្នា ដូចគ្នាហ្នឹងគឺថា មិនខុសគ្នាទេ។ ចាប់ វ៉ាន់ ពីនី មុនគាត់បាទ បាន រួចបានចាប់គាត់ ឬមួយថ្ងៃជាមួយគ្នា ប៉ុន្តែថ្ងៃចាប់ហ្នឹងវាខុសពី ឌុច ថាថ្ងៃខែ១៨ ខែសីហា។ តាមក្នុងឯកសារនេះវាថាខែ១១ ខែវិច្ឆិកា ទៅវិញ។ បាទ អ៊ីចឹងបានជាខ្ញុំមាន -- ក្រែង ឌុច មិនសូវចាំរឿង*ដាដ* ព្រោះតែៗដល់ ១១ វាសមហេតុសមផលជាមួយនឹងឯកសារ និងគាត់ធ្វើសារភាព បាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណ។ បាទ ខ្ញុំគិតថាឥឡូវនេះ ខ្ញុំអស់ពេលវេលាហើយ។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

[១៥:២៤:០៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ជាបន្តសូមអញ្ជើញលោកមេធាវី -- អញ្ជើញលោកចៅក្រម។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមចោទសំណួរទាក់ទងទៅនឹងទំនាក់ទំនងរបស់បងប្រុសរបស់លោក ចៅ សេង ជាមួយនឹងមេដឹកនាំខ្មែរក្រហមជាពិសេសជាមួយ ខៀវ សំផន តែម្តង។ តើទំនាក់ទំនងរបស់គាត់ជាក់លាក់ហ្នឹងយ៉ាងម៉េចដែរ? តើជាទំនាក់ទំនងមិត្តភក្តិទុកចិត្តគ្នា ឬតើការដែលលោក ចៅ សេង នៅប្រទេសបារាំងហ្នឹង គាត់មានទំនាក់ទំនងជាមួយ ខៀវ សំផន ដែរឬទេ?

**លោក ចៅ ឃីម៖**

**ឆ៖** ឆ្លើយបាទ ចៅ សេង និង ខៀវ សំផន ជាមិត្តភក្តិមួយជិតដិត ព្រោះធ្លាប់រៀននៅ -- ចៅ សេង រៀនខាងឡែត គាត់រៀនខាងច្បាប់ នៅម៉ុងពេយេ ជាមួយគ្នា។ អ៊ីចឹងចង់សុំ បើលោកព្រះរាជអាជ្ញាមានអនុញ្ញាត សូមសួរផ្ទាល់ ខ្ញុំសូមសួរផ្ទាល់ លោក ខៀវ សំផន ឲ្យឆ្លើយពីរឿង ចៅ សេង បាទ ព្រោះគាត់ជាពួកម៉ាក់ជិតដិត។ ចៅ សេង គឺថាគាត់ កាលគាត់នៅធ្វើជារដ្ឋមន្ត្រីនៅសង្គមរាស្ត្រនិយម គាត់បានជួយលោក ខៀវ សំផន មកជួយ មកធ្វើខាង*កុំម៉ែក* – ខាងពាណិជ្ជកម្ម។ ប៉ុន្តែនៅមិនបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រោះកាលនុ៎ងពួកខាងស្តាំវាមិនទទួល។ បានៗលោក ខៀវ សំផន សុំទទួល សុំ*ដេស្ប៉ូណេ* – សុំលាចេញបានទៅហ្នឹង។ ជាមិត្តភក្តិជិតដិត ព្រោះគាត់នៅរៀនជាមួយគ្នាយូរណាស់ នៅម៉ុងពេយេ៉។ ទើបតែ៦០ - - នែ៥៨ បានលោក ខៀវ សំផន ចេញទៅរៀននៅស៊ែកប៊ិន។ ប៉ុន្តែនេះហ្នឹង នៅ(ឮមិនច្បាស់) គាត់នៅជាមួយគ្នាៗ នៅម៉ុងពេយេ៉។ កាលនៅខ្មែរមិនសូវមានច្រើនទេ។ ខ្មែរមានបីបួននាក់ៗ មួយខេត្ត។ ហេតុនេះ គាត់ជាអ្នកជិតដិតជាមួយ ខៀវ សំផន។

[១៥:២៦:៣១]

**ស៖** តើនៅពេលដែលបងប្រុសរបស់លោកចូលមកនៅក្នុងរាជរដ្ឋាភិបាលរួមរួបជាតិកម្ពុជាហ្នឹង គឺគាត់បានជួប ខៀវ សំផន ទោះបីជានៅប្រទេសបារាំងក៏ដោយ នៅប៉េកាំងក៏ដោយ នៅកន្លែងផ្សេងក៏ដោយនោះ តើដោយសារតែគាត់ចូលធ្វើការនៅក្នុងរាជរដ្ឋាភិបាលរួមរួបជាតិកម្ពុជាហ្នឹងហើយបានគាត់ជួប ខៀវ សំផន ឬក៏យ៉ាងម៉េច?

**ឆ៖** ជួបមុន គាត់និង ខៀវ សំផន ជួបតាំងពីនៅរៀន។ គាត់ជួបតាំងពីនៅរៀន នៅម៉ុងពេយេ៉តាំងពីឆ្នាំ៤៧-៤៨ នេះ បានជួបពីនុ៎ងមក រហូតដល់៥៨ គាត់ម៉ុងពេយេ៉។ ហើយបែបប្រហែល ខ្ញុំមិនដឹងច្បាស់ គាត់បានជួបលោក ខៀវ សំផន នៅពេលដែលគាត់ធ្វើជារដ្ឋមន្ត្រីទទួលបន្ទុកខាងបេសកកម្មពិសេស – *ហ្សាក់សេ ដេមីស្យុងពេស្យាល់* ហ្នឹង តើមាន-- លោក ខៀវ សំផន -- បែបៗគាត់មានឱកាសនឹងជួបលោក ខៀវ សំផន នៅប៉េកាំង។ នេះគឺជាច្បាស់ហើយ។ មិនៗអត់ទេ។ បាទ សូមអរគុណ។

**ស៖** តើលោកដឹងដែរឬទេ ថានៅពេលដែលគាត់ត្រឡប់មកកម្ពុជាប្រជាធិបតេយ្យនៅប្រទេសកម្ពុជាវិញ នៅឆ្នាំ៧៥នោះ តើគាត់ធ្លាប់ជួប ខៀវ សំផន ដែរឬអត់ ពេលដែលគាត់ត្រឡប់ចូលមកប្រទេសកម្ពុជាវិញ?

[១៥:២៨:០២]

**ឆ៖** អាកន្លែងនេះ ខ្ញុំមិនដឹងច្បាស់ ប៉ុន្តែធម្មតា ពួកខ្មែរក្រហមមិនដែលឲ្យជួបទេ។ ពួកអ្នកមកពីក្រៅមិនសូវឲ្យជួបទេ។ គឺថាជួប គឺធ្វើដូចជាមិនសូវស្គាល់គ្នាបាទ។ ហេតុនេះ ខ្ញុំមិនអាចបញ្ជាក់បានក្នុងពេលនោះ។ ក្នុងពេល៧៥ ដែលគាត់ចូលមកនុ៎ងបាទ តើគេបានជួបនឹងប៉ុន្មាននាក់។ ហ៊ូ នឹម គាត់ជាពួកម៉ាកគាត់ជិតស្និទ្ធ បាទ ហ៊ូ នឹម។ ហេតុនេះ អ៊ីចឹងបានថាការសម្លាប់គាត់ទៅ មិនដឹងវាជាប់សែស្រឡាយជាមួយ ហ៊ូ នឹម ឬមួយម៉េច ខ្ញុំមិនដឹងច្បាស់។ បាទ ប៉ុន្តែបើលោក ខៀវ សំផន បែបមាន អាចឲ្យដំណឹងយើងបានច្រើន។ បាទ អរគុណ។

**សៈ** ក្រោយឆ្នាំ១៩៧៩ តើរូបលោកផ្ទាល់នោះ លោកធ្លាប់ជួប ឬក៏ទាក់ទង ខៀវ សំផន ដែរ ឬទេ ឬក៏ ខៀវ សំផន ព្យាយាមទាក់ទងក្រុមគ្រួសារ មិត្តភក្តិរបស់គាត់ ដើម្បីផ្តល់ដំណឹងឲ្យ ឧទាហរ-ណ៍ថា ដើម្បីប្រាប់ជូនដំណឹងអំពីអ្វីដែលគាត់អាចបានដឹងឮមុនឆ្នាំ១៩៧៩នោះ។ តើករណីហ្នឹង លោក ខៀវ សំផន មានបានធ្វើទេ?

**ឆៈ** ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំគ្មានឱកាសជួបលោក ខៀវ សំផន ប៉ុន្តែខ្ញុំមានពួកម៉ាក់ គេបានជួប លោក ខៀវ សំផន បានគេយកមកប្រាប់ខ្ញុំណា។ គេបានជួប ខៀវ សំផន អីវាយរាប់។ លោក តាន់ ប៊ុន ស៊ុយ ខ្ញុំឲ្យឈ្មោះទៀតទៅ។ *សឹម*ជាបញ្ជាក់ លោក ខៀវ សំផន តើគាត់មានជួបលោក តាន់ ប៊ុនស៊ុយ ទេ បាទ នៅស្រុកបារាំង។ សូមអរគុណ។

[១៥:៣០:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកចៅក្រម។ សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា អញ្ជើញតាំង សំណួរលើដើមបណ្តឹងរដ្ឋប្បវេណីនេះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វិចទ័រ កូប៉េ៖**

**សៈ** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ <ខ្ញុំមាន> សំណួរមួយចំនួនទេសួរបន្តជាមួយនឹងលោកតទៅនេះ។ ខ្ញុំជាមេធាវីការពារក្តីលោក នួន ជា។ បាទ ខ្ញុំ ចង់ដឹងឲ្យច្បាស់បន្តិចថាតើលោកអាចបញ្ជាក់អះអាងបានទេថា តើបងប្រុសរបស់លោកជាប្រេសិត ពិសេសសម្រាប់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជារបស់សម្តេច នរោត្តម សីហនុ មែនឬ? ហើយបើសិន ជាយ៉ាងដូច្នេះមែនថាតើគាត់គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍របស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា នេះមែនឬទេ?

**លោក ចៅ ឃឹម៖**

**ឆៈ** ខ្ញុំវា -- តាមយោបល់ខ្ញុំ គាត់បានចូលមកក្នុងរណសិរ្ស ព្រោះសម្តេចលោកឲ្យ ប៉ែន នុត លោកសម្តេច ប៉ែន នុត យកហៅគាត់ពីម៉ុងពេយ៉េមក ព្រោះគាត់ពីដើមគាត់នៅម៉ុងពេយ៉េ ដល់រដ្ឋ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រហារ៧០ហ្នឹង គាត់បានហៅគាត់មកជួយនៅប៉េកាំង គាត់ក៏បានចូលមកជួយសម្តេច ហើយបានសម្តេចបាននាំមេបានធ្វើឲ្យគាត់ជារដ្ឋមន្ត្រីក្រសួង -- រដ្ឋមន្ត្រីទទួលបន្ទុកខាងបេសកកម្មពិសេស។

[១៥:៣២:១០]

**ស៖** ប៉ុន្តែតើលោកដឹងទេថាគាត់ពិតជាសមាជិកនៃរណសិរ្សរួបរួមជាតិកម្ពុជា ហើយថាតើគាត់ជាអ្នកនាំពាក្យសម្រាប់រណសិរ្សរួបរួមជាតិកម្ពុជានេះនៅមុនឆ្នាំ១៩៧៥មែនទេ?

**ឆ៖** គាត់ជារដ្ឋមន្ត្រីទទួលបន្ទុកខាងបេសកកម្មពិសេស ប៉ុន្តែមិនដឹងគាត់ជាអ្នកនាំពាក្យ ខ្ញុំមិនដឹងដែរ អាហ្នឹងគឺថា អ្នកនាំពាក្យមិនដឹង។ ប៉ុនគាត់ច្បាស់ៗជាមួយសម្តេចអត់មាននេះទេ មានឈ្មោះគាត់គ្រប់កន្លែង គឺគាត់បានទទួល មានគ្រប់រូបថត មានស្ទើរទាំងអស់ជាមួយសម្តេច ដែលអង្កាល់នោះបាទ។ អានេះជារូបថតជាមួយសម្តេច គាត់ធ្លាប់នៅកាលនៅប៉ារីស បើចង់លោកចង់មើល ខ្ញុំជូនបាទទៅនេះអានេះសំបុត្រ -- រូបថតជាមួយសម្តេចដែលបាន គាត់បានទៅធ្វើ*គង់ត្រង់ដឺប្រេស* ថាម៉េច ទៅធ្វើ*គង់ត្រង់ដឺប្រេស* ជាមួយសម្តេចបាទ។

**ស៖** តើលោកដឹងទេថា តើលោកដឹងថាគាត់មានបាននិយាយទៅកាន់សារព័ត៌មានអន្តរជាតិនៅថ្ងៃទី១៧ មេសា ១៩៧៥ នៅទីក្រុងប៉ារីសដែរឬទេ? គឺការនិយាយប្រាប់អ្នកកាសែតបរទេសនិយាយអំពីមហាជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥ លោកដឹងទេ?

**ឆ៖** ខ្ញុំដឹងៗ។ ព្រោះកាលនោះខ្ញុំនៅពីស្រុកបារាំងដែរ ១៩៧៧ ហ្នឹងហើយខ្ញុំនៅស្រុកបារាំងដែរ។

**ស៖** សំណួររបស់ខ្ញុំ សួរថាតើគាត់គឺជាអ្នកនាំពាក្យតំណាងឲ្យរណសិរ្សរួបរួមជាតិកម្ពុជានៅមុនឆ្នាំ១៩៧៥ ប្រចាំទីក្រុងប៉ារីសមែនទេ ដែលពេលនោះគឺថាគាត់បានបញ្ជាក់អះអាងអំពីការរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ១៩៧៥?

[១៥:៣៥:០០]

**ឆ៖** ច្បាស់ គឺថាគាត់ជាអ្នកតំណាងសម្តេចនៅទីក្រុងបារីស។ ហេតុនេះគាត់ជាអ្នក ដូចជាអ្វីៗគឺតាមគាត់ទាំងអស់ គឺគាត់ជាអ្នកធ្វើសន្និសីទកាសែត ឬមួយធ្វើអីទាក់នឹងជាមួយបរទេស គាត់ជា -- គាត់ទាក់ទងទាំងអស់ បាទ ហ្នឹងដឹង បាទ។

**ស៖** ហើយតើលោកដឹងទេថា នៅខែមីនា ឆ្នាំ១៩៧៥ គាត់ក៏បានថ្លែងតាំងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា ដោយបានពិភាក្សាលើកឡើងនិយាយអំពីសេចក្តីសម្រេចក្នុងការសម្រេចសម្លាប់ពួក

មហាក្សត់ទាំងប្រាំពីរនាក់ លោកដឹងទេ?

**ឆ៖** អានេះ ខ្ញុំមិនៗៗច្បាស់ ខ្ញុំអត់ច្បាស់អាហ្នឹង។ អ្នកសម្លាប់គាត់ដូចថា អាហ្នឹងខ្ញុំអត់ដឹងទេ អាហ្នឹង។ ខ្ញុំអត់ដឹង។

**ស៖** តើលោកដឹងទេថានៅដើមខែមីនា ឬក៏ក្នុងខែមីនា គាត់បាននិយាយជាមួយនឹងសារព័ត៌មានអន្តរជាតិស្ដីអំពី<ការបង្កើត>គណៈកម្មាធិការមួយចំនួននៅក្នុងតំបន់រំដោះ? លោកបានដឹងរឿងនេះទេ?

**ឆ៖** ខ្ញុំអត់ដឹងទេអាហ្នឹង ព្រោះ*(ឮមិនច្បាស់)* បញ្ហាខ្លះខ្ញុំមិនអាចដឹងទាំងអស់ទេ ព្រោះខ្ញុំមិនបាននៅជាមួយគាត់ជាប់ ព្រោះគាត់ចុះឡើងទៅមកៗ ខ្ញុំនៅប៉េកាំង។ គាត់ទៅមកៗ គឺថាគាត់ធ្វើញឹកញយ កាលហ្នឹង។

[១៥:៣៦:៤១]

**ស៖** តើលោកដឹងអំពីការចាប់ខ្លួន និងការឃុំខ្លួនគាត់ ប្រហែលជាគេត្រូវបានលើកយកមកនិយាយនៅក្នុង<>សវនាការនាឆ្នាំ១៩៧៩ ដែលពេលនោះគេហៅថា តុលាការបដិវត្តន៍ប្រជាជនទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៩ ដែលបានកាត់ទោស ប៉ុល ពត និង អៀង សារី។ លោកដឹងទេ?

**ឆ៖** អានេះខ្ញុំដឹង។ អាហ្នឹងដឹងតាមកាសែត មិនមែនតាមអី តាមកាសែត។

**ស៖** តើលោកដឹងថា គាត់មានឈ្មោះនៅក្នុងបញ្ជីមួយ និយាយអំពីជនល្មើសសំខាន់ៗមួយចំនួន គឺឯកសារ <E3/1993>, ERN ជាភាសាអង់គ្លេស00064840, ខ្មែរ00796751, បារាំង00795339 <-- គាត់>បាន<បញ្ជាក់អំពី>សមាជិកប្រតិបត្តិសម្រាប់រណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅបរទេស ហើយ<គាត់ត្រូវបានគេចុះបញ្ជីថា មានលេខរៀងទី២១ ក្នុងចំណោមមនុស្សរបស់>ក្រសួងការបរទេស?

**ឆ៖** ខ្ញុំមិនយល់ ខ្ញុំមិនយល់នូវសំណួរលោក។

**ស៖** អ៊ីចឹង ខ្ញុំសួរតាមរបៀបផ្សេង បើដូច្នេះ។ តើលោកដឹងទេ ថាម៉េចបានគេចាត់ទុកថា <គាត់>គឺជាជនសង្ស័យ ឬក៏ជនល្មើសមួយដ៏សំខាន់ ឬក៏ថាជាពិរុទ្ធជនមួយដ៏សំខាន់<នៅ ស-២១>? លោកដឹងទេ?

**ឆ៖** អត់ អាហ្នឹងគឺខ្ញុំអត់ដឹងទេបាទ។ អាហ្នឹងខ្ញុំអត់ដឹង។

[១៥:៣៩:១៦]

**ស៖** បើខ្ញុំស្ដាប់មិនច្រឡំទេ <លោក>ថា ក្រោយពេល<បងប្រុស>លោកត្រឡប់មកវិញ គឺ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គាត់និយាយ -- លោកនិយាយថា គាត់ហ្នឹងគឺស្ថិតនៅក្នុងភូមិភាគបូព៌ា។ លោកនិយាយថាអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន។

**ស៖** តើលោកដឹងទេថា នៅភូមិភាគបូព៌ាហ្នឹង គាត់ធ្វើអ្វីដែរ? <តើលោកមានព័ត៌មានផ្ទាល់អំពីរឿងនោះទេ?>

**ឆ៖** អាឡូ ខាងបូព៌ាគឺគាត់គ្មាន -- កាលគេយកទៅដាក់នៅស្លួងហ្នឹង គាត់គ្មានធ្វើអី ជាងនេះ គឺគេៗដក គេអប់រំគាត់នៅជាមួយនឹងពួកបញ្ញវន្តដទៃទៀតដែលទៅជាមួយគាត់នៅពេលនោះ ប៉ុន្តែនៅមិនបានយូរទេ គាត់ត្រឡប់មកវិញ មកៗភ្នំពេញវិញ។

**ស៖** តើធ្វើដូចម្ដេចទើបលោកដឹងថាគាត់ហ្នឹងនៅស្លួង គឺនៅតំបន់ដែលជាចំណុះឲ្យភូមិភាគបូព៌ានោះ?

**ឆ៖** នេះ គាត់បានសរសេរសំបុត្រមួយ ទៅៗ*ម៉ាដាម*គាត់។ គាត់បានសរសេរសំបុត្រពីរដង ទៅ*ម៉ាដាម*គាត់ ទៅ*ម៉ាដាម*គាត់នៅស្រុកបារាំង។ អង្គការបានអនុញ្ញាតឲ្យគាត់សរសេរសំបុត្រទៅនុ៎ង បានខ្ញុំមានសំបុត្រនុ៎ង គាត់ជា*(ឮមិនច្បាស់)* បានគាត់ប្រាប់ថា គាត់បានទៅអប់រំនៅខាងនោះ នៅស្លួង នៅរួចបានតែមិនប៉ុន្មាន រួចទៅ បានមកៗមកភ្នំពេញវិញ។

[១៥:៤១:០៩]

**ស៖** តើនៅក្នុងលិខិតរបស់គាត់ គាត់មាននិយាយអំពីថ្នាក់ដឹកនាំនៅភូមិភាគបូព៌ា ឬក៏និយាយអំពីមេដឹកនាំនៅស្លួងនោះដែរទេ ដូចជាឈ្មោះ សោ ភឹម នេះជាដើម?

**ឆ៖** បើនេះ គាត់អត់មាននិយាយទេ។ គាត់និយាយតែវ៉ៃ *(ឮមិនច្បាស់)* គឺថាបានត្រួតពិនិត្យត្រង់អង្គការ គាត់មិនអាចសរសេរបានតាមចិត្តគាត់ទេ។ គាត់ទៅនិយាយតែពីរឿងដែលសុខភាព រឿងស្អីហ្នឹង គឺថាអត់មានៗនែ ទៅនែនិយាយពីស្អីផ្ដេសផ្ដាសទេ បាទ។

**ស៖** តើលិខិតនេះ ត្រូវបានអាជ្ញាធរស្លួង ឬក៏សមត្ថកិច្ចនៅស្លួងកាលនុះនោះ ត្រួតពិនិត្យសិនឬមុននឹងបញ្ជូនចេញនោះ?

**ឆ៖** ហ្នឹងច្បាស់ណាស់ ព្រោះមិនមែនចេះតែផ្ញើទៅតាមចិត្តទេ។ ហើយផ្ញើមកតាមវ៉ាលីឌីប្លូម៉ាទិក គឺថាតាមៗសមុទ្រ តាមសមុទ្រនែ៎ ទូតៗ បាទ។ បានផ្ញើ គាត់ផ្ញើមក ឲ្យៗប្រពន្ធគាត់នៅៗស្រុកបារាំងពីរដង ហើយគាត់បានឲ្យៗប្រពន្ធគាត់មកតាម ប៉ុន្តែដល់នេះទៅវាស្មុគស្មាញ គឺថាបានឈប់ទៅវិញទៅ។

[១៥:៤២:៣០]

**ស៖** ហេតុអ្វី មុននេះបន្តិចនេះ លោកបានគិតថា គាត់ប្រហែលជាសមាជិក -- សុំដកស្រង់៖ “ប្រហែលជាសមាជិកនៃខ្សែរយៈ ហ៊ូ នឹម”។ ហេតុអីបានលោកលើកមកនិយាយថាយ៉ាងដូច្នេះ?

**ឆ៖** ខ្ញុំអាចនេះ គឺពីព្រោះគាត់នឹងជា ហ៊ូ នឹម ជាមិត្តភក្តិមួយដែលជិតដិត។ គាត់បានផ្ញើ -- ហ៊ូ នឹម បានផ្ញើរូបមួយទៀតទៅឲ្យគាត់ ដែលកាលគាត់ ហ៊ូ នឹម នៅនែនៅក្នុងរណសិរ្សនៅក្នុងស្រុក ឲ្យៗគាត់ បាទ ព្រោះគាត់ជិតដិតជាមួយ ហ៊ូ នឹម។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែលោកប្រើពាក្យថា “ខ្សែរយៈ ហ៊ូ នឹម”។ ហេតុអីបានជាលោកប្រើពាក្យខ្សែរយៈ ហ៊ូ នឹម យ៉ាងដូច្នេះ?

**ឆ៖** ពីព្រោះខ្មែរក្រហម គេៗច្រើនតែយកតាមខ្សែរយៈៗ ហ៊ូ នឹម, ខ្សែរយៈ កុយ ធួន, ខ្សែរយៈ សោ ភឹម, ខ្សែរយៈ -- ព្រោះគេប្រើពាក្យរបៀបហ្នឹង គឺថាមានខ្សែរយៈមួយៗ គឺគេយកទៅ គេៗត្រូវរករបៀបហ្នឹង។

**ស៖** តើលោកកំពុងតែនិយាយថា បងប្រុសរបស់លោក ត្រូវបានគេចាប់ខ្លួននេះ ដោយសារថាគាត់ជាខ្សែ ហ៊ូ នឹម អ៊ីចឹងឬ?

[១៥:៤៤:០៤]

**ឆ៖** នេះជាបន្ទាប់បន្សំ។ កាលគាត់គេចាប់ខ្លួននោះ គឺបែបរឿងផ្សេងទៀត ខ្ញុំមិនដឹងមូលហេតុអីទេ។ ហេតុនេះជាឲ្យច្បាស់ ហ្នឹងជាៗបណ្ដោះ បន្ទាប់បន្សំទេ ក្នុងនាម -- ខ្ញុំលើកពីរឿងសែស្រឡាយ ហ៊ូ នឹម ហ្នឹង គឺថាបន្ទាប់បន្សំ មិនមែនជាៗ *ហ្វាក់ទ័រ*មួយ ជាកត្តាមួយដែលគេចាប់នោះទេ បាទ។

**ស៖** តើបងប្រុសរបស់លោក ធ្លាប់និយាយមកកាន់លោក ឬក៏សរសេរនៅក្នុងលិខិតដែលថាគាត់គិតយ៉ាងដូចម្ដេច អំពីវៀតណាមទេ ឬក៏អំពីគោលនយោបាយបរទេសរបស់វៀតណាមនោះដែរទេ?

**ឆ៖** គាត់មិនសូវដែលនិយាយទេ ពីរឿងគោលនយោបាយវៀតណាមស្អីៗ គឺថាគាត់មិនដែល។ គាត់មាននិយាយម្ដង គាត់ថាកាលយើងហ្នឹង គឺថាវៀតណាមបានប្រាប់ទៅខាងខ្មែរក្រហមថា កុំទាន់អាលយកភ្នំពេញ ចាំគេយកព្រៃនគររួច ចាំយក ចាំគេមកជួយភ្នំពេញ។ អាហ្នឹងគាត់មាននិយាយ។ ហើយវៀតណាមបានសរសើរខ្មែរក្រហម ថាអ្នកឯងដេញប្រជាជនទៅបរទេសហ្នឹង ដេញប្រជាជនចេញពីទីក្រុងហ្នឹង គឺល្អហើយ ខ្ញុំធ្វើវាមិនកើត បើអ្នកឯងធ្វើកើត សូមសរសើរ។

**ស៖** ខ្ញុំសូមបន្តទៅប្រធានបទមួយថ្មី។ បាទពីដើមនេះខ្ញុំឮលោកនិយាយឈ្មោះ ហោ ណាំហុង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តើ ហោ ណាំហុង នេះជាអ្នកណាលោក?

[១៥:៤៦:០០]

**ឆ៖** ហោ ណាំហុង គាត់បាន គាត់កាលនុំងគាត់ធ្វើទូតនៅគុយបា។ តែដល់៧០ ដល់រដ្ឋប្រហារ ៧០ គាត់បាន គាត់មកចូលជាមួយសម្តេចៗ កាលនុំង មិនមែនគាត់មិនមកចូល មិនមែនមកចូលជាមួយខ្មែរក្រហមទេ គាត់ចូលសម្តេច។ គាត់នៅបឹងត្របែកនេះ គាត់មាន ខ្ញុំមានឯកសាររបស់គាត់ គាត់សារភាពពីឯកសារពីរឿងនិយាយពីរឿង ចៅ សេង, ពីរឿង វ៉ាន់ ពីនី រឿងស្អីនៅនៅ គាត់នៅជាមួយគ្នានៅបឹងត្របែកហ្នឹងនៅក្នុងអាគេហៅ*បេ១ត្រង់ដី* ហ្នឹងគឺថាសម្រាប់ផ្គុំរោមទាំងអស់ ពួកអ្នកទូត។ គាត់ថាពួកដល់គេយក វ៉ាន់ ពីនី ទៅសម្លាប់, ពីដើម ចៅ សេង ធ្វើជាប្រធាននៅក្នុងពួកខាងទូតហ្នឹង។ ដល់គេយក ចៅ សេង ទៅសម្លាប់, វ៉ាន់ ពីនី ទៅសម្លាប់ គាត់ឡើងជាប្រធានៗ អាពួកខាងទូត ហើយគាត់ជាប្រធាន ហើយម្នាក់ទៀតនោះឈ្មោះស្អីហ្នឹង ប៉ែន ញ៉ាច –កូន ប៉ែន នុត– ធ្វើជាៗប្រធានរង។ ហេតុនេះមិនដឹងគាត់សហការជាមួយពួក អាវ៉ន ហ្នឹង ថាអានុំង ដឹងជា ដែល អៀង សារី ថាយួនបង្កប់នៅក្នុងនុំង។ អាហ្នឹងខ្ញុំមិនដឹងថា អាហ្នឹងមិនដឹងច្បាស់ណ៎ា បាទមិនដឹងគាត់សហការជាមួយពួកនុំងទេ ឬយ៉ាងណា ខ្ញុំអត់ដឹងទេ។ អាហ្នឹងខ្ញុំមិនសូវច្បាស់។

[១៥:៤៧:៣២]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាឌី.ស៊ី.ខេម យើងខ្ញុំមានអត្ថបទនេះតែជាភាសាខ្មែរទេ មិនទាន់មានការបកប្រែជាភាសាអង់គ្លេសទេ គឺឯកសារ D22/289.5 ខ្មែរគឺ 00481409 លោកបានឆ្លើយថា -- បាទខ្ញុំ<មានសម្រង់ឯកសារដើមនៅទីនេះសម្រាប់លោក បើលោកចង់បាន>សហការីកម្ពុជាខ្ញុំអាន<ជូនលោកបាន> លោកបានឆ្លើយថា “ហោ ណាំហុង ហ្នឹងគឺថាគាត់<>នៅបឹងត្របែក។ អ៊ីចឹងឯងបានជាមានរឿងក្តីក្តាំរវាងលោក រង្ស៊ី ជាមួយលោក ហោ ណាំហុង” ។ <តើនេះជាអ្វីដែលលោកបាននិយាយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាឬ? បើ>លោក<បាន> លើកឡើងចំណុចនេះ<មែន តើ> លោកចង់និយាយថាដូចម្តេចហ្នឹង?

**ឆ៖** លោក ហោ ណាំហុង គាត់សារភាពខ្លួនគាត់។ គាត់មិនមែនថា គាត់លាក់ថានេះទេ ប៉ុន្តែមិនមែនគាត់ត្រួតបឹងត្របែកហ្នឹងទាំងអស់ទេ គាត់ទាល់តែពួកខាងៗទូតៗ ពួកឌីប្លូម៉ាស៊ី ពួកខាងទូតខាងអំបាសាដ័រ។ ហេតុនេះគឺថាមិនខាង រង្ស៊ី បែបចោទគាត់ ថាគាត់ជាមេទាំងអស់ជាមួយក្នុងបឹងត្របែកហ្នឹង ប៉ុនមិនមែនទេ គាត់បែបតែខាងទូត ព្រោះវាចែកជាបី ក្នុងនុំងវាមានខាង មានទូត ពួករដ្ឋ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការចាស់ ហើយនិងកូនសិស្ស ខុសគ្នា។ នៅបីខុសគ្នា នៅបីកន្លែងខុសគ្នា។ ហេតុនេះ គឺថាគាត់ៗថា ដល់ វ៉ាន់ ពីនី ស្លាប់ទៅ គេចាប់ វ៉ាន់ ពីនី ទៅ, គាត់ ចៅ សេង ចាប់ ចៅ សេង ទៅ គាត់ស្មានតែយក ទៅធ្វើការនៅអឹកន្លែងធ្វើការខាងទូតខាងអីហើយ គាត់ៗបានគេៗតាំងគាត់ជាប្រធាន គាត់ប្រធាននៅក្នុងនុំង ហើយគាត់មានលោក ប៉ែន ញាច –កូន ប៉ែន នុត– ហ្នឹងជាអនុប្រធាន។

[១៥:៤៩:៤៤]

**ប្រធានអង្គជំនុំ៖**

លោកៗមេធាវី លោកអស់ម៉ោង អស់ពេលហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំដឹងថាអស់ម៉ោងហើយលោកប្រធាន ក៏ប៉ុន្តែក្រុមមេធាវីការពារក្តីលោក ខៀវ សំផន នេះអត់មានសំណួរទេ។ ដូច្នេះ ខ្ញុំសូមយកម៉ោងរបស់គាត់សុំសួរបីប្អូនប្រាំនាទីទៀត លោកដើមបណ្តឹងរដ្ឋប្បវេណី។ បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ពិតហើយថា ខ្លួនលោកផ្ទាល់នេះលោកដើមបណ្តឹងរដ្ឋប្បវេណី លោកមិនស្ថិតនៅបឹងត្របែកទេ ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីមួយដែលផ្តល់សក្ខីកម្មកាលពីសប្តាហ៍មុនហ្នឹង គាត់ធ្លាប់នៅបឹងត្របែក។ ឥឡូវ ខ្ញុំសូមអាននូវសក្ខីកម្មរបស់គាត់ដែលបានឆ្លើយកាលពីថ្ងៃព្រហស្បតិ៍ សប្តាហ៍មុននៅម៉ោង១៥:៥១ សូមដកស្រង់៖ "នៅពេលដែលខ្ញុំនៅឯបឹងត្របែក ហោ ណាំហុង គឺជាប្រធានមន្ទីរបឹងត្របែក។ គាត់ជាប្រធាន គាត់បែងចែកការងារនៅក្នុងក្រុមទាំងអស់នោះ នេះបើតាមខ្ញុំដឹង។ ដូច្នេះគាត់ទទួលខុសត្រូវក្នុងការប្រគល់ចាត់ចែងការងារឲ្យអ្នកដទៃទៀតធ្វើ គឺថាគាត់មិនមែនជាអ្នកទោសទេ"។ បញ្ចប់ការដកស្រង់។ តើចំណុចនេះលោកអាចបញ្ជាក់អះអាងដែរទេ ដើមបណ្តឹងរដ្ឋប្បវេណីនេះឈ្មោះរស់ ជួរ ស៊ីអ៊ី។ តើលោកយល់យ៉ាងដូចម្តេចដែរចំពោះចម្លើយរបស់គាត់នេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[១៥:៥០:៤២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំគិតថាមេធាវីការពារក្តីគួរតែលើកឡើងថា ម៉ោងដែលគេសួរដើមបណ្តឹងរដ្ឋប្បវេណីនេះគឺ

<ការ>បែងចែក<នេះមិនមែនធ្វើឡើងដោយក្រុមមេធាវីការពារក្តី រវាង>ផ្នែកទាំងបីហ្នឹង<ទេ ហើយខ្ញុំមិនបានរកឃើញថាតើដើមបណ្តឹងរដ្ឋប្បវេណីនេះ នៅក្នុងផ្នែកទាំងបីនេះឬយ៉ាងណានោះទេ ហើយនៅក្នុងផ្នែកផ្សេងទៀត មាន> ហោ ណាំហុង <នៅក្នុងនោះ>។ អ៊ីចឹង<ជាមួយនឹងការកត់សម្គាល់នេះ ខ្ញុំគិតថា នេះជាសំណួរត្រឹមត្រូវ ប៉ុន្តែគ្មានករណីណាមួយដែលអាចចាត់ទុកថាពាក់ព័ន្ធនឹងបឹងត្របែកទាំងមូលនោះទេ>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំដឹងហើយ គឺថាកាលពីសប្តាហ៍មុនដើមបណ្តឹងរដ្ឋប្បវេណីធ្វើការវែកញែកច្បាស់ពីគ្នាហើយថា ហោ -- ហើយលោក ហោ ណាំហុង គាត់បានធ្វើការវែកញែកច្បាស់លាស់ហើយដែរ។ សំណួរនេះសំណួរតែដដែលទេ ខ្ញុំមិនយល់ថាហេតុអីបានជំទាស់ទៅនឹងសំណួរខ្ញុំ។ ក៏ប៉ុន្តែខ្ញុំសួរម្តងទៀត តើលោកយល់យ៉ាងដូចម្តេចចំពោះចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលខ្ញុំទើបអានឲ្យលោកស្តាប់អម្បាញ់មិញនេះ?

**ឆ៖** ជំនួស -- ចំពោះសំណួរនេះ ខ្ញុំឃើញថា ប្រហែលគាត់មិនដឹងរឿងនៅគុកបឹងត្របែកចែកជាប៉ុន្មានពួក។ ពីព្រោះមានពួក មានមួយក្រុមៗមានប្រធាន មានអនុប្រធាន មានប្រធាន មានអនុប្រធាន ខាងរដ្ឋការផ្សេង ខាងទូតផ្សេង ខាងនោះផ្សេង។ មិនមែនគាត់ មិនៗត្រួតទាំងអស់ក្នុងបឹងត្របែកទេ អាហ្នឹងខ្ញុំមានឯកសាររបស់លោក ហោ ណាំហុង សរសេរជាដៃ គាត់សរសេរជាបារាំង។

[១៥:៥២:៣០]

**ស៖** ខ្ញុំយល់ហើយ សូម្បីតែនៅក្នុងសារព័ត៌មានថ្ងៃនេះ ក៏គាត់បានបដិសេធចំពោះការចោទប្រកាន់ថា គាត់ជាប្រធានបឹងត្របែកនេះដែរ។ ក៏ប៉ុន្តែខ្ញុំសូមសួរសំណួរលោកចុងក្រោយ ក្នុងនោះគឺយើងមានឯកសារភាពយន្តមួយមកពីខ្សែភាពយន្តអាល្លឺម៉ង់ហៅថា "ស្តាហ្ស៊ី" ដែលបានបញ្ជាក់ថា -- ហើយលោក ហោ ណាំហុង ខ្លួនឯងក៏បានទទួលស្គាល់ថាជាអ្នកទោស និងជាប្រធាននៅទីនោះផង។ ក៏ប៉ុន្តែនៅឆ្នាំ១៩៧៩ គាត់ត្រូវបានគេចោទប្រកាន់ថា ជាជនសមគំនិតជាមួយនឹង អៀង សារី តើលោកបានឮរឿងនេះទេ ឬក៏ក្រោយៗមកទៀតលោកបានឮរឿងនេះដែរទេ?

**ឆ៖** ចំពោះរឿងនេះ ខ្ញុំដូចអត់ៗបានទេ អត់បានដឹងអីទេ។ ដឹងចុងក្រោយគាត់មានការជាមួយ អៀង សារី ហ្នឹងចុងក្រោយបាទ ដឹងពួកទូតប៉ុន្មានស្លាប់ចង់អស់ហើយ ហ្នឹងពេលហ្នឹង។

**ស៖** ខ្ញុំយល់ឃើញថានេះជាសំណួរចុងក្រោយមែនទែនហើយ។ តើលោកដឹងថា លោក ហោ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាំហុង មានចូលរួមពាក់ព័ន្ធអ្វីក្នុងការធ្វើសេចក្ដីសម្រេចបញ្ជូនបងប្រុសរបស់លោកពីបឹងត្របែកមក ស-២១ ដែរទេ?

[១៥:៥៥:០៧]

**ឆ៖** សំណួរនេះ -- សំណួរនេះខ្ញុំថាមិន គាត់អត់ទេមែនទេ ព្រោះគាត់ៗមកក្រោយ គាត់ឡើងក្រោយ ព្រោះកាលដំបូងឡើងគឺថា គាត់បងខ្ញុំលោក ចៅ សេង គាត់ជាប្រធាន, វ៉ាន់ ពីនី -- ជាមួយ វ៉ាន់ ពីនី អនុប្រធាន ហើយទើសតែពួកហ្នឹងចូលពីរនាក់ហ្នឹងចេញបានគាត់ បានឡើង។ ខ្ញុំមិនដឹងច្បាស់អាហ្នឹងខ្ញុំមិនដឹងគាត់មានការលួចលាក់ជាមួយ សារ៉ន នោះ។ អាមួយហ្នឹងថាវាបង្កប់នៅក្នុងៗបឹងត្របែកហ្នឹង។ ខ្ញុំមិនដឹងច្បាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណច្រើនលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកព្រះរាជអាជ្ញា។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែផ្ដល់លេខ ERN ដែលខ្ញុំអត់បានឱ្យអម្បាញ់មិញនេះ ការសម្ភាសជាមួយ អៀង សារី គឺឯកសារ E3/89។ សម្រង់អម្បាញ់មិញដែលខ្ញុំអានហ្នឹង គឺនៅទំព័រ ERN 18 និង 19 ជាភាសាបារាំង 00332698 ដល់ 99, អង់គ្លេសពីទំព័រទី 19 ដល់ 20 ERN 00417617 ទៅដល់ 18, ជាភាសាខ្មែរទំព័រ 24 ដល់ 25 ERN 00062475 ទៅដល់ 76។ ហើយកំណត់ហេតុស្ដាប់ចម្លើយ ឌុច E3/60។ សម្រង់ដែលខ្ញុំអានជាភាសាខ្មែរអម្បាញ់មិញហ្នឹងគឺ 00195 596។ សូមអរគុណលោកប្រធាន។

[១៥:៥៧:១១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារ លោក ខៀវ សំផន លោកមិនមានសំណួរទេឬ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមយើងអត់មានសំណួរទេបាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាចុងក្រោយលោកដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលលោកឆ្លើយសំណួរចំពោះមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញ លោកបានសួរសំណួរទៅជនជាប់ចោទរួចហើយ។ តើនៅពេលនេះលោកមានចង់តាំងសំណួរដដែលនេះ ទៅជនជាប់ចោទទៀតទេ តាមរយៈអង្គជំនុំជម្រះ?

**លោក ចៅ ឃឹម៖**

លោកចៅក្រមខ្ញុំនៅ -- សំណួរដដែល គឺថាចង់ឲ្យលោកៗ ខៀវ សំផន ឬមួយលោក នួន ជា ឆ្លើយចំពោះបញ្ហា ចៅ សេង។ ការស្លាប់របស់ ចៅ សេង នៅកន្លែងណា? នៅទីណា? នៅពេលណា ឲ្យច្បាស់។ ព្រោះ ឌុច វានិយាយហើយ ប៉ុន្តែវាចង់ឲ្យបានបញ្ជាក់ពីខាងលើ។ មួយទៀត ហេតុអ្វីបានគាត់ពួកខ្មែរក្រហមសម្លាប់ពួកបញ្ញវន្ត? អាហ្នឹងមួយ។ សំណួរហ្នឹងមិនដែល -- មនុស្សទាំងអស់គ្នា មិនតែខ្ញុំមួយទេ គឺបងប្អូនដែលគេមានបងស្លាប់ប៉ុន្មានគឺគេចង់សួរកន្លែងហ្នឹង។ តើអាចសាលាជំនុំជម្រះអាចបញ្ជាក់ឲ្យច្បាស់ពីរឿងហ្នឹងបានទេបាទ អានេះសំណួររបស់ខ្ញុំ។ ហើយខ្ញុំចង់សួរ លោក ខៀវ សំផន បើលោកព្រះរាជអាជ្ញាមានៗៗ អនុញ្ញាត សូមសួរលោក ខៀវ សំផន ដែលមានវត្តមាននៅទីនេះ តើខ្ញុំអាចសួរបានទេ? បាទ សូមអរគុណ។

[១៥:៥៨:៥៦]

**ប្រធានអង្គជំនុំ៖**

លោកសួរតាមរយៈអង្គជំនុំជម្រះ ជនជាប់ចោទ -- ចំពោះជនជាប់ចោទ។

**លោក ចៅ ឃឹម៖**

បាទ ព្រះរាជអាជ្ញា។ សូមសួរតាមជំនុំជម្រះជនជាប់ចោទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសំណួរ!

**លោក ចៅ ឃឹម៖**

លោក ខៀវ សំផន សូមជម្រាបសួរ ខ្ញុំចង់ឲ្យលោកបញ្ជាក់ពីបញ្ហា--

**ប្រធានអង្គជំនុំ៖**

សូមលោកដើមបណ្ដឹងរដ្ឋប្បវេណី លោកសួរទៅជនជាប់ចោទតាមរយៈអង្គជំនុំជម្រះ មានន័យថា លោកសួរជនជាប់ចោទតាមរយៈខ្ញុំ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ចៅ ឃឹម៖**

លោក ចៅ សេង ហ្នឹងមិនដឹងគាត់ជាមិត្តភក្តិជិតដិត តើគាត់មានខុសអ្វី គាត់មានក្បត់បដិវត្តន៍ខ្មែរក្រហមឬទេ ឬមួយយ៉ាងម៉េចបានគេយកគាត់ទៅៗសម្លាប់? បាទ អាហ្នឹងមួយ។ ហើយពួក នួន ជា ចំពោះបញ្ហារបស់គាត់ គាត់ត្រូវទទួលខុសត្រូវ ឬគាត់ម៉េចគាត់មានបញ្ហាទៅសម្លាប់ ចៅ សេង ឬមួយមនុស្សមានទោសពៃអី វាចេះតែបញ្ចេញថា គាត់ជាភ្នាក់ងារស៊ី! ភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់អី គឺថាអាហ្នឹងមួយ និងចង់សួរបញ្ជាក់ទៅលោក នួន ជា បាទ។ សូមអរគុណលោកព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

អង្គជំនុំជម្រះសូមជម្រាបដើមបណ្តឹង -- លោកដើមបណ្តឹងរដ្ឋប្បវេណីថា រហូតដល់ពេលនេះជនជាប់ចោទនៅតែអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ ហេតុនេះ សូមលោកដើមបណ្តឹងរដ្ឋប្បវេណីជ្រាប។

អង្គជំនុំជម្រះអរគុណលោក ចៅ ឃឹម សវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនានិងព្យសនកម្ម ដែលលោកអះអាងថា បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខស-២១ បានដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ ហើយលោក លឹម ប៊ុនហួរ លោកសម្រាកបានហើយ។

សវនាការថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះ ត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៦ ខែសីហា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការលើការដាក់បង្ហាញឯកសារបន្តបញ្ចប់ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមការពេលវេលាដែលបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលសវនាការថ្ងៃអង្គារ ទី១៦ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*